# ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក : កាលានុវត្តភាព ឬវិបត្តិ?






អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
United Nations in Cambodia

ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា
ខែវិច្ឆិកា ឆ្នាំ២០០៩

# បុព្វកថា



ប្រទេសកម្ពុជា នៅពុំទាន់បានគេចចេញផុតពីផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកឡើយ ។ ការប៉ាន់ប្រមាណអំពីភាពក្រីក្រ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០០៧ បានបង្ហាញពីអត្រានៃភាពក្រីក្រ ៣០% ដែលជាកំណែលម្អពីអត្រា ៣៥% នៅក្នុងឆ្នាំ២០០៤។ ដោយបានទទួលផលភាគច្រើនពីការរីកចម្រើនខ្ពស់នៃសេដ្ឋកិច្ចតាមអត្រាជាមធ្យម ៩,៥% នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ការរីកចម្រើននេះ គឺជាសមិទ្ធផលមួយគួរឱ្យកត់សំគាល់ ។ ទោះជាយ៉ាងណាក៏ដោយ ការរីកចម្រើនរបស់កម្ពុជាលើការកាត់បន្ថយភាពក្រីក្រ និងការឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) កំពុងស្ថិតក្រោមការគំរាមកំហែងនៃផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ច ។

នៅក្នុងរបាយការណ៍នេះដែលមានចំណងជើងថា *ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក : កាលានុវត្តភាព ឬវិបត្តិ?* អ្នកស្រាវជ្រាវបានពឹងផ្អែកលើការអង្កេត និងឯកសារសិក្សាស្រាវជ្រាវនានាដែលមានស្រាប់ ក៏ដូចជាការសម្ភាសជាមួយអ្នកកសាងគោលនយោបាយ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានផងដែរ ។ របាយការណ៍នេះ ផ្ដោតលើក្រុមប្រជាពលរដ្ឋដែលកំពុងងាយរងគ្រោះ និងក្រុមនានា ដែលអាចនឹងធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះ និងតួនាទីរបស់គោលនយោបាយនៅក្នុងការកាត់បន្ថយភាពងាយរងគ្រោះទាំងនេះ ក៏ដូចជាការរៀបចំស្ដារសេដ្ឋកិច្ចឡើងវិញឱ្យមានចីរភាព និងសមធម៌ផងដែរ ។

ការធ្លាក់ចុះនៃសេដ្ឋកិច្ច បង្ហាញពីឱកាសសម្រាប់ការបង្កើតប្រព័ន្ធជាតិការពារសង្គម និងសម្រាប់ការកែទម្រង់រចនាសម្ព័ន្ធដែលចាំបាច់ត្រូវធ្វើជាបន្ទាន់ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះ វាក៏បង្ហាញពីការប្រឈមផងដែរ នៅក្នុងកិច្ចការពារសមិទ្ធផលដែលមានស្រាប់នានា និងការទ្រទ្រង់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅពេលបច្ចុប្បន្ន និងអនាគត ។

អ.ស.ប នៅកម្ពុជា មានការព្រួយបារម្ភជាចំបងអំពីការអភិវឌ្ឍមនុស្ស និងផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចមកលើប្រជាពលរដ្ឋជាពិសេស ក្រុមអ្នកងាយរងគ្រោះបំផុត ។ និន្នាការសេដ្ឋកិច្ចថ្មីៗនេះ កំពុងមានផលប៉ះពាល់យ៉ាងច្រើនមកលើស្ត្រី ដោយសារតែការបិទទ្វាររោងចក្រកាត់ដេរ ដែលធ្វើឱ្យស្ត្រីកាន់តែងាយរងគ្រោះ ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចក៏កំពុងកើតឡើងផងដែរ នៅក្នុងពេលដែលយុវជនច្រើនជាង ២៥០.០០០ នាក់ ត្រូវបានគេប៉ាន់ប្រមាណថា នឹងត្រូវចូលនៅក្នុងទីផ្សារពលកម្មក្នុងមួយឆ្នាំៗ ។ ការបន្តវិភាគនៅកម្រិតម៉ាក្រូ និងមីក្រូមានគោលដៅពិនិត្យមើលនិន្នាការសព្វថ្ងៃនេះ និងដើម្បីផ្ដល់ជាមូលដ្ឋានសម្រាប់ការពិភាក្សា អំពីគោលនយោបាយទន្ទឹមនឹងការយកចិត្តទុកដាក់ចំពោះក្រុមជនដែលងាយរងគ្រោះបំផុតផងដែរ ។

ឌូក្លាស ប្រូដឺរិក
អ្នកសម្របសម្រួលប្រចាំកម្ពុជា
អង្គការសហប្រជាជាតិនៅកម្ពុជា



# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះត្រូវបានរៀបចំឡើង ក្រោមការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសពី UNDP ដែលជាវិភាគទានចំពោះការឆ្លើយតបរបស់ អ.ស.ប ទៅនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក។ លោកស្រី ឃន ឱនរ៉ាវី នាយកគម្រោងជាតិជាន់ខ្ពស់ បានដឹកនាំក្រុមនេះ។ ការស្រាវជ្រាវបានដឹកនាំដោយលោក ច័ន្ទ សុផល ទីប្រឹក្សានាំមុខលើការស្រាវជ្រាវ ដោយមានការគាំទ្រពីលោក លឹម សុវណ្ណារ៉ា អ្នកជំនាញសេដ្ឋកិច្ចជាតិមកពី UNDP នៅកម្ពុជា លោកស្រី Rosaleen Martin អ្នកជំនាញសេដ្ឋកិច្ចមកពី UNDP នៅកម្ពុជា និងអ្នកស្រី ឆាយ ពិដោរ ជំនួយការស្រាវជ្រាវមកពី UNDP នៅកម្ពុជា។ លោក ប៉ែន រក្សា ជំនួយការកម្មវិធីមកពី UNDP នៅកម្ពុជា បានផ្តល់ការគាំទ្រដ៏មានប្រយោជន៍ខាងផ្នែករដ្ឋបាលសំរាប់រយៈពេលនៃគម្រោងនេះ។

អ.ស.ប នៅកម្ពុជា សូមថ្លែងអំណរគុណចំពោះ UNDP នៅក្រុងកូឡុំបូ ជាពិសេស T. Palanival និង លោកស្រី Yumiko Yamamoto ដែលបានផ្តល់របាយការណ៍របស់ខ្លួន។ វិភាគទានដ៏មានប្រយោជន៍ពី Robert Glofcheski ដែលជាប្រធានក្រុមអ្នកជំនាញការខាងសេដ្ឋកិច្ចមកពីUNDP ប្រចាំនៅប្រទេសឡាវ និងដែលបានផ្តល់ការណែនាំនិងយោបល់នៅទូទាំងដំណើរការទាំងមូលនៃការរៀបចំរបាយការណ៍នេះ។ ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម សុខ សុភ័ក្រ្ត អគ្គនាយកនៃក្រសួងពាណិជ្ជកម្ម ឯកឧត្តម រស់ សីលវ៉ា អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ លោកស្រី Mariana Stirbu ទីប្រឹក្សាផ្នែកគោលនយោបាយសង្គមនៃអង្គការ UNICEF ប្រចាំនៅកម្ពុជា លោក ហ៊ិន វិសាល ឧបការីនាយកអង្គការ UNDP ប្រចាំនៅកម្ពុជា និងជាប្រធានផ្នែកកាត់បន្ថយភាពក្រីក្រ លោក Brooks Evans, ជំនាញការខាងសេដ្ឋកិច្ចនៃ UNDP នៅកម្ពុជា លោក Glenn Kendall ទីប្រឹក្សាខាងផ្នែកឧស្សាហកម្មនីស្សារណកម្មនៃ UNDP នៅកម្ពុជា លោកស្រី Anna Collins-Falk មកពី UNDP នៅកម្ពុជា លោកស្រី Winta Ghebreab ជំនួយការបច្ចេកទេស ប្រចាំនៅក្រសួងកិច្ចការនារី និងលោកស្រី Margaret Lamb អ្នកជំនាញការផ្នែកទំនាក់ទំនងនៃ UNDP នៅកម្ពុជា បានផ្តល់វិភាគទានដ៏មានតម្លៃដល់របាយការណ៍នេះ។

ក្រុមអ្នកស្រាវជ្រាវសូមថ្លែងអំណរគុណ ចំពោះមនុស្សជាច្រើនដែលទទួលយល់ព្រមសម្ភាស និងអ្នកទាំងឡាយ ដែលបានចូលរួមនៅក្នុងការពិភាក្សា និងដែលបានចំណាយពេលវេលា ដើម្បីផ្តល់ទិន្នន័យព័ត៌មាន និងយោបល់នានាដ៏មានតម្លៃនៅក្នុងដំណើរនៃការសិក្សានេះ និងជាពិសេស សូមថ្លែងអំណរគុណចំពោះក្រុមទីភ្នាក់ងារអ.ស.ប ប្រចាំនៅក្នុងប្រទេស និងដៃគូអភិវឌ្ឍន៏ដទៃទៀត ដែលបានផ្តល់គំនិតនិងយោបល់ដ៏មានតម្លៃ។

យើងសូមថ្លែងអំណរគុណផងដែរចំពោះលោក Douglas Broderick អ្នកសម្របសម្រួលអ.ស.ប និងជាតំណាង UNDP ប្រចាំនៅប្រទេសកម្ពុជា លោក Jo Scheuer នាយកអង្គការ UNDP ប្រចាំនៅកម្ពុជា លោកស្រី Sophie Baranes នាយករងនៃអង្គការ UNDP ប្រចាំនៅកម្ពុជា និង Ismael Toorawa នាយករងផ្នែកប្រតិបត្តិការនៃ UNDP ប្រចាំនៅកម្ពុជា ដែលបានផ្តល់ការគាំទ្រ និងការណែនាំជារួមដល់កិច្ចផ្តួចផ្តើមស្រាវជ្រាវនេះ។



# មាតិកា


បុព្វកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ ii

ពាក្យបំព្រួញ ........ vii

សេចក្តីសង្ខេប ........ ១

១. សេចក្តីផ្តើម ........ ៥

២. ផលប៉ះពាល់លើម៉ាក្រូសេដ្ឋកិច្ច ........ ៧
- ២.១ ការព្យាករណ៍អំពីកំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូរទម្រង់នៃកំណើន ........ ៧
- ២.២ ថវិការដ្ឋាភិបាល ........ ១២
- ២.៣ ជំនួយអភិវឌ្ឍន៍ផ្លូវការ ........ ១៦
- ២.៤ ការវិនិយោគដោយផ្ទាល់ពីបរទេស ........ ១៧
- ២.៥ កំណែតម្រូវលើអត្រាប្តូរប្រាក់ ........ ១៩
- ២.៦ ប្រាក់កំចី និងការជាប់បំណុល ........ ២០
- ២.៧ ជញ្ជីងទូទាត់ ........ ២២

៣. ផលប៉ះពាល់លើវិស័យនានា ........ ២៥
- ៣.១ ការនាំចេញសម្លៀកបំពាក់ ........ ២៥
- ៣.២ ទេសចរណ៍ ........ ២៨
- ៣.៣ កសិកម្ម ........ ៣០
- ៣.៤ ទីផ្សារអចលនទ្រព្យ និងវិស័យសំណង់ ........ ៣៣

៤. ផលប៉ះពាល់មកលើប្រជាជន ........ ៣៥
- ៤.១ ជនរងគ្រោះនៅលំដាប់ទីមួយ ........ ៣៦
  - ៤.១.១ កម្មករកាត់ដេរ ........ ៣៦
  - ៤.១.២ កម្មករសំណង់ ........ ៣៨
  - ៤.១.៣ កម្មករឧស្សាហកម្មទេសចរណ៍ ........ ៣៩
  - ៤.១.៤ កសិករ ........ ៤០
  - ៤.១.៥ កម្មករចំណាកស្រុកកម្ពុជា ........ ៤២

៤.២ ជនរងគ្រោះលំដាប់ទីពីរ ..... ៤៣
៤.២.១ គ្រួសារកសិករដែលទទួលប្រាក់ផ្ញើមកផ្ទះតិចជាងមុន និងជនចំណាកស្រុកដែលវិលត្រឡប់មកផ្ទះវិញ ..... ៤៤
៤.២.២ កុមារក្នុងគ្រួសារក្រីក្រ ..... ៤៤
៤.២.៣ ជនក្រីក្រ និងជិតក្រីក្រដែលមានសព្វថ្ងៃនៅតាមទីក្រុង ..... ៤៥
៤.២.៤ គ្រួសារដែលគ្មានដីធ្លី ..... ៤៦

៤.៣ កាត់បន្ថយផលប៉ះពាល់មកលើប្រជាពលរដ្ឋតាមរយៈកិច្ចការពារសង្គម ..... ៤៧
៤.៣.១ វិធានការដែលមានស្រាប់ ..... ៤៧
៤.៣.២ ការចំណាយរបស់រដ្ឋាភិបាលលើបណ្ដាញសុវត្ថិភាពសង្គម ..... ៤៩
៤.៣.៣ ការប្រឈមនៅក្នុងកិច្ចការពារសង្គម ..... ៤៩

៥. កាត់បន្ថយផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ច ..... ៥១
៥.១ ការបង្កើតប្រព័ន្ធចម្រុះមួយរបស់ជាតិសម្រាប់ការពារសង្គម ..... ៥១
៥.២ កម្មវិធីចំណាយប្រកបដោយប្រសិទ្ធភាពសម្រាប់វិស័យសាធារណៈដែលផ្ដោតលើសមធម៌ ..... ៥២
៥.៣ កំណែទម្រង់ជារចនាសម្ព័ន្ធ ..... ៥៣

៦. សេចក្ដីសន្និដ្ឋាន ..... ៥៥

ឧបសម្ព័ន្ធ ..... ៥៧

១. វិធីសាស្ត្រ ..... ៥៧

២. តារាងឈ្មោះអ្នកសម្ភាស និងស្ថាប័នដែលបានពិគ្រោះយោបល់នៅក្នុងការសិក្សានេះ ..... ៥៩

៣. វិធានការការពារខាងសង្គម ..... ៦០

ឯកសារយោង ..... ៦១

# តារាងរូប បញ្ជីតារាង និងប្រអប់



## តារាងរូប


រូបទី ១. និន្នាការនៃកំណើនសេដ្ឋកិច្ចតាមវិស័យ (គិតជាភាគរយពីឆ្នាំ១៩៩៤-២០០៨) .......... ៧

រូបទី ២. ការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា (ភាគរយនៃការប្រែប្រួល គិតតាមថ្លៃសព្វថ្ងៃនេះ) .......... ១០

រូបទី ៣. ផលចំណូលរបស់រដ្ឋាភិបាល ការចំណាយ និងឱនភាព (គិតជាពាន់លានរៀល) .......... ១២

រូបទី ៤. និន្នាការនៃផលចំណូលរបស់ជាតិ ខែមករា ឆ្នាំ២០០៨ ដល់ខែ ឧសភា ឆ្នាំ២០០៩ (គិតជាពាន់លានរៀល) .......... ១៥

រូបទី ៥. ការផ្ទេរសាច់ប្រាក់ដោយស្ថាប័នពហុភាគី និងទ្វេភាគី និងសហភាពអឺរ៉ុប ឆ្នាំ១៩៩២-២០០៨ (ពាន់ដុល្លារ) .......... ១៦

រូបទី ៦. ការលូតលាស់នៃឥណទានក្នុងប្រទេស និងក្នុងវិស័យឯកជន .......... ២១

រូបទី ៧. ចំណូលពីការនាំចេញសម្លៀកបំពាក់ពីកម្ពុជា ឆ្នាំ២០០១-២០០៨ (គិតជាលានដុល្លារ) .......... ២៦

រូបទី ៨. ទំនាក់ទំនងរវាងការនាំចេញសម្លៀកបំពាក់របស់កម្ពុជា និងការលក់រាយនៅស.រ.អា .......... ២៧

រូបទី ៩. និន្នាការថ្មីៗនៃចំនួនភ្ញៀវទេសចរមកទស្សនាកម្ពុជា ខែមករា ឆ្នាំ២០០៨- ខែមិថុនា ឆ្នាំ២០០៩ .......... ២៩

រូបទី ១០. និន្នាការថ្មីៗនៃភ្ញៀវទេសចរមកដល់ព្រលានយន្តហោះខេត្តសៀមរាប ខែមករា ឆ្នាំ២០០៨-មិថុនា ឆ្នាំ២០០៩ .......... ១០

រូបទី ១១. និន្នាការថ្លៃស្រូវ កៅស៊ូ និងពោតនៅក្នុងប្រទេសថៃ (ទីផ្សារមួយសម្រាប់ផលិតផលកសិកម្មពីកម្ពុជា) .......... ៣២

រូបទី ១២. ការអនុម័តឯកភាពលើគម្រោងសាងសង់ .......... ៣៣

រូបទី ១៣. និន្នាការនៃការចំណាយរួមសម្រាប់វិស័យសង្គម (ភាគរយនៃ GDP) .......... ៤៩


## បញ្ជីតារាង


តារាងទី ១. ការព្យាករណ៍អំពី GDP របស់កម្ពុជាសម្រាប់ឆ្នាំ២០០៩ .......... ៨

តារាងទី ២. ថវិកាជាតិឆ្នាំ២០០៨ និងឆ្នាំ២០០៩ (លានដុល្លារ) .......... ១៤

តារាងទី ៣. FDI ដែលបានអនុម័តអចលនទ្រព្យ (គិតជាលានដុល្លារ) .......... ១៨

តារាងទី ៤. និន្នាការនៃអត្រាប្តូរប្រាក់ (ប្រាក់រៀល ធៀបនឹងដុល្លារ ប្រាក់បាត និងប្រាក់ដុង) .......... ១៩

តារាងទី ៥. ជញ្ជីងទូទាត់ (គិតជាលានដុល្លារ) .......... ២៣

តារាងទី ៦. ការនាំចេញសម្លៀកបំពាក់ប្រចាំខែក្នុងរយៈពេលបួនខែដំបូងពីឆ្នាំ២០០៧ ដល់ ២០០៩ (លានដុល្លារ) .......... ២៦

តារាងទី ៧. ការនាំចូលសម្លៀកបំពាក់ដោយ ស.រ.អា ពីប្រទេសនានានៅឆ្នាំ២០០៧, ២០០៨ និងដើមឆ្នាំ២០០៩ .......... ២៨

តារាងទី ៨. សារៈសំខាន់នៃវិស័យទេសចរណ៍នៅក្នុងសេដ្ឋកិច្ចកម្ពុជា ........ ២៩
តារាងទី ៩. ការនាំចេញរបស់កម្ពុជា ឆ្នាំ២០០២-២០០៧........ ៣១
តារាងទី ១០. ការប្រែប្រួលថ្លៃនៃផលិតផលកសិកម្មសំខាន់ៗ (រៀល/គក្រ លើកលែងតែកៅស៊ូ) ........ ៣២
តារាងទី ១១. កម្មករចំណាកស្រុកពីកម្ពុជា ដែលបានបញ្ជូនជាផ្លូវការទៅក្រៅប្រទេសចាប់ពីឆ្នាំ១៩៩៨ ........៤៣
តារាងទី ១២. សារពើភ័ណ្ឌនៃគម្រោងការពារសង្គម........ ៤៨

## ប្រអប់

ប្រអប់ទី ១. មេគុណនៃការចំណាយ ........២២
ប្រអប់ទី ២. កម្មករកាត់ដេរដែលបាត់បង់ការងារ ........ ៣៧
ប្រអប់ទី ៣. កម្មករសំណង់ដែលបាត់បង់ការងារ ........៣៩
ប្រអប់ទី ៤. អ្នកលក់នៅខេត្តសៀមរាប ........ ៤០
ប្រអប់ទី ៥. អ្នកដាំដំឡូងមី ........៤១
ប្រអប់ទី ៦. កម្មករនៅទីក្រុង ........ ៤៦

# ពាក្យបំព្រួញ



| | | |
|---|---|---|
| **ADB** | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **ACLEDA** | Association of Cambodian Local Economic Development Agencies | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន នៅកម្ពុជា |
| **ASEAN** | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CAS** | Cambodia Anthropometric Study | ការសិក្សាមនុស្សមាត្រវិទ្យានៅកម្ពុជា |
| **CDC** | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **CBHI** | Community-based health insurance initiatives | កិច្ចផ្តួចផ្តើមធានារ៉ាប់រងសុខភាព ផ្អែកលើសហគមន៍ |
| **CDCF** | Cambodia Development Cooperation Forum | វេទិកាសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា |
| **CDRI** | Cambodia Development Resource Institute | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា |
| **CMDGs** | Cambodia Millennium Development Goals | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| **EIC** | Economic Institute of Cambodia | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា |
| **FDI** | Foreign direct investment | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| **GDP** | Gross domestic product | ផលិតផលក្នុងស្រុកសរុប |
| **GMAC** | Garment Manufacturers Association in Cambodia | សមាគមរោងចក្រកាត់ដេរ នៅកម្ពុជា |
| **HEFs** | Health equity funds | មូលនិធិសមធម៌សម្រាប់ការថែទាំសុខភាព |
| **IFC** | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| **ILO** | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| **IMF** | International Monetary Fund | មូលនិធិហិរញ្ញវត្ថុអន្តរជាតិ |
| **MAFF** | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MFI** | Micro-finance institution | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |

| | | |
|---|---|---|
| **MoC** | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| **MoEYS** | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoH** | Ministry of Health | ក្រសួងសុខាភិបាល |
| **MoLVT** | Ministry of Labour and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **MoSAVY** | Ministry of Social Affairs, Veteran and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **MoT** | Ministry of Tourism | ក្រសួងទេសចរណ៍ |
| **MoWRAM** | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| **MRD** | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| **NBC** | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |
| **NSSF** | National Social Security Fund | មូលនិធិជាតិសន្តិសុខសង្គម |
| **NGO** | Non-governmental organisation | អង្គការមិនមែនរដ្ឋាភិបាល |
| **NIS** | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| **NPL** | Non-performing loan | ប្រាក់កំចីមិនផ្តល់ការប្រាក់ |
| **ODA** | Official development assistance | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| **PFM** | Public financial management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **SNEC** | Supreme National Economic Council | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| **SEZ** | Special Economic Zone | តំបន់សេដ្ឋកិច្ចពិសេស |
| **UNDP** | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| **UNIAP** | United Nations Inter-Agency Project on Human Trafficking | គម្រោងអន្តរទីភ្នាក់ងារនៃ អ.ស.ប ស្តីពីការជួញដូរមនុស្ស |
| **UNICEF** | United Nations Children’s Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **UNTAC** | United Nations Transitional Authority in Cambodia | អ៊ុនតាក់ : អាជ្ញាធរបណ្តោះអាសន្ន អ.ស.ប ប្រចាំនៅកម្ពុជា |
| **WFP** | World Food Programme | កម្មវិធីស្បៀងអាហារពិភពលោក |

# សេចក្តីសង្ខេប



ប្រទេសកម្ពុជាមិនបានគេចផុតពីផលប៉ះពាល់ជាទូទៅបណ្តាលពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកឡើយ ។ ដោយផ្អែកលើព័ត៌មានដែលមានរហូតមកទល់ និងខែសីហា ឆ្នាំ២០០៩ ធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករណ៍ថា ផលិតផលក្នុងស្រុកសរុប (GDP) នឹងធ្លាក់ចុះ ១,៥ % ចំណែក IMF បានព្យាករណ៍អំពីការធ្លាក់ចុះនេះមានរហូតដល់ ២,៧៥% នៅក្នុងឆ្នាំ ២០០៩ ។ នេះ គឺជាការផ្លាស់ប្តូរយ៉ាងខ្លាំងបន្ទាប់ពីមានកំណើនពីរខ្ទង់នៅក្នុងរយៈពេលស្ទើតែពេញប្រាំឆ្នាំកន្លងមកនេះ ។ ការធ្លាក់ចុះយ៉ាងខ្លាំងពុំធ្លាប់មានពីមុនមកនៃ GDP ដែលបានពីការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) និងផលចំណូលពីការនាំចេញ បានគូសបញ្ជាក់ថា កម្ពុជាត្រូវតែប្រកាន់យកវិធានប្រកបដោយការគិតទុកជាមុន និងតាមរយៈការពិគ្រោះយោបល់ក្នុងការធ្វើចម្រុះកម្មនៃមូលដ្ឋានសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែងខាងសេដ្ឋកិច្ចរបស់ខ្លួនផងដែរ ។ ការដោះស្រាយអាទិភាពទាំងនេះ នឹងពង្រឹងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចរបស់កម្ពុជា និងកាត់បន្ថយភាពងាយរងគ្រោះយ៉ាងខ្លាំងរបស់ប្រទេសនេះ នៅចំពោះមុខការប៉ះទង្គិចពីខាងក្រៅ ។

ផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គម បណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅក្នុងឆ្នាំកន្លងទៅនេះ រួមមាន ការបាត់បង់យ៉ាងច្រើននូវការងារ ការថយចុះនៃប្រាក់ចំណូលក្នុងចំណោមគ្រួសារជាច្រើន និងកំណើនអសន្តិសុខស្បៀងផងដែរ ។ ប្រការនេះភាគច្រើនជះឥទ្ធិពលដល់ប្រជាពលរដ្ឋចំនួន ៣០% ដែលកំពុងតែរស់នៅក្នុងភាពក្រីក្រ និងដែលងាយធ្លាក់ចុះទៅក្នុងភាពក្រីក្ររួចទៅហើយ និងដែលស្ថិតនៅពីលើខ្សែបន្ទាត់នៃភាពក្រីក្រតែបន្តិចប៉ុណ្ណោះ ។ ផលប៉ះពាល់ដោយផ្ទាល់មកលើកម្ពុជាបានកើតឡើង តាមរយៈឥទ្ធិពលរបស់វាមកលើវិស័យចំបងៗ ដែលបច្ចុប្បន្ននេះ ជាវិស័យដែលផ្តល់វិភាគទានយ៉ាងសំខាន់ក្នុងការផ្តល់ប្រាក់ឈ្នួល ការងារធ្វើ និងកំណើនសេដ្ឋកិច្ច ពោលគឺការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) ឧស្សាហកម្មកាត់ដេរ វិស័យទេសចរណ៍ ឧស្សាហកម្មសំណង់ និងកសិកម្ម ។

វិស័យកាត់ដេរ រួមចំណែកច្រើនជាង ៧០% នៃផលចំណូលពីការនាំចេញ និងបង្ហាញយ៉ាងច្បាស់អំពីតម្រូវការជាបន្ទាន់បំផុតរបស់កម្ពុជា ក្នុងការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន ។ ការនាំចេញសម្លៀកបំពាក់ទៅស.រ.អា បានធ្លាក់ចុះ ២២% នៅ ក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។ រោងចក្រកាត់ដេរនៅក្នុងប្រទេសដទៃទៀត ដូចជា នៅប្រទេសបង់ក្លាដែស វៀតណាម និងចិន បានបង្កើនការនាំចេញសម្លៀកបំពាក់របស់ខ្លួនទៅកាន់ទីផ្សារស.រ.អា នៅក្នុងរយៈពេលដូចគ្នានេះ សូម្បីតែនៅក្នុងរយៈពេលនេះ ការនាំចូលសម្លៀកបំពាក់របស់ ស.រ.អា បានធ្លាក់ចុះច្រើនជាង ១២% ក៏ដោយ ។ ការធ្លាក់ចុះនៃបរិមាណសម្លៀកបំពាក់នាំចេញរបស់កម្ពុជា បង្ហាញពីប្រការគួរឱ្យព្រួយបារម្ភ ដែលបណ្តាលពីកង្វះភាពប្រកួតប្រជែងក្នុងសេដ្ឋកិច្ចនៃឧស្សាហកម្មកាត់ដេរនៅប្រទេសកម្ពុជា ។ កង្វះភាពសំបូរបែបនៅក្នុងវិស័យនេះ ក៏បង្ហាញឱ្យឃើញច្បាស់ផងដែរ ដោយមានផលិតផលត្រឹមតែប្រាំមុខប៉ុណ្ណោះនៅក្នុងចំណោម ៦៥% នៃសម្លៀកបំពាក់ដែលនាំចេញនៅក្នុងឆ្នាំ ២០០៥ ហើយ ៩០% នៃផលិតផលនាំចេញ ត្រូវបានបញ្ជូនទៅក្នុងទីផ្សារស.រ.អា និងសហភាពអឺរ៉ុប ។ យោងតាមតួលេខរបស់ក្រសួងពាណិជ្ជកម្ម ការធ្លាក់ចុះចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៨ បាននាំឱ្យមានការបិទទ្វាររោងចក្រចំនួន ៥០ និងការបាត់បង់ការងារធ្វើ ក្នុងចំណោមកម្មកររោងចក្រកាត់ដេរចំនួន ៦៣.០០០ នាក់ មាន ៩០% គឺជាស្ត្រី ដែលភាគច្រើនបំផុតជាអ្នកមកពីជនបទនៃប្រទេសកម្ពុជា ។

វិស័យទេសចរណ៍ ដែលផ្តល់ផលចំណូលប្រមាណ ១៣% នៃ GDP របស់ប្រទេសកម្ពុជា បានចាប់ផ្តើមបង្ហាញអំពីការធ្លាក់ចុះជាលើកដំបូង ឬកំណើនយឺតជាងមុន នៅក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ។ តួលេខស្ថិតិអំពីចំនួនភ្ញៀវទេសចរមកដល់កម្ពុជាបានបង្ហាញពីការផ្លាស់ប្តូរពីភ្ញៀវទេសចរដែលជាអ្នកចំណាយច្រើន ទៅភ្ញៀវទេសចរដែលជាអ្នកចំណាយតិច ដែលនាំឱ្យមានការធ្លាក់ចុះជាច្រើននូវផលចំណូលពីវិស័យទេសចរណ៍។ ប្រជាពលរដ្ឋដែលពឹងផ្អែកលើទេសចរណ៍ ជាពិសេស ទេសចរណ៍នៅក្នុងខេត្តសៀមរាបបានទទួលផលចំណូលតិចជាងយ៉ាងច្រើនធៀបនឹងឆ្នាំទៅ។ អាជីវកម្មជាច្រើននៅក្នុងខេត្តសៀមរាបរាយការណ៍ថា រកបានផលចំណូលតិចជាងពាក់កណ្តាលនៃចំណូលកាលពីមួយឆ្នាំមុន ចំណែកសណ្ឋាគារមួយចំនួនក៏បានបិទទ្វារដែរ។ ស្ថានភាពនេះ ក៏ទំនងជារងឥទ្ធិពលអវិជ្ជមានបណ្តាលពីការផ្ទុះនៃរោគផ្តាសាយ A(H1N1) និងការគំរាមកំហែងពីអស្ថិរភាពនយោបាយនៅក្នុងទីក្រុងបាងកក ដែលជាផ្លូវឆ្លងកាត់ចំបងមួយផងដែរ សម្រាប់អ្នកទេសចរដែលចូលមកក្នុងប្រទេសកម្ពុជា។

នៅក្នុងវិស័យកសិកម្ម ថ្លៃផលិតផលកសិកម្មបានធ្លាក់ចុះជាគំហុក ចំណែកកសិករត្រូវចំណាយកាន់តែច្រើនឡើងនៅក្នុងការផលិតដោយសារតែថ្លៃខ្ពស់នៃធាតុចូល និងជីគីមី បណ្តាលពីអតិផរណាកម្រិតខ្ពស់នៅដើមឆ្នាំ២០០៨។ ប្រការនេះ នាំឱ្យកសិករជាច្រើនបាត់បង់ប្រាក់ចំណូល និងធ្លាក់ខ្លួនជំពាក់បំណុល និងជាប់ផុងក្នុងភាពក្រីក្រ។ បើគិតជាផលប៉ះពាល់នៅក្នុងគ្រួសារ គេឃើញមានសញ្ញាដែលបង្ហាញយ៉ាងច្បាស់ថា គ្រួសារជាច្រើនបានជំពាក់បំណុលកាន់តែច្រើនឡើងៗនិងកាន់តែប្រឈមនឹងការលំបាកក្នុងការសងបំណុលទាំងនោះ។ លើសពីនេះ ប្រាក់ផ្ញើទៅផ្ទះដែលធ្លាប់តែបញ្ជូនទៅឱ្យគ្រួសារនៅជនបទ ដែលផ្តល់ជាវិភាគទានយ៉ាងច្រើនទៅក្នុងសេដ្ឋកិច្ចនៅជនបទក៏បានធ្លាក់ចុះផងដែរ ដោយសារជនចំណាកស្រុកជាច្រើនដែលធ្វើការនៅតាមទីក្រុងនានា ឬនៅក្រៅប្រទេស បានបាត់បង់ការងារ ឬបានទទួលប្រាក់ចំណូលតិចជាងមុន។

គេបានប៉ាន់ប្រមាណថា កម្មករចំនួនប្រមាណ ២០-៣០% នៅក្នុងរោងចក្រកាត់ដេរ ការដ្ឋានសំណង់ និងឧស្សាហកម្មទេសចរណ៍បានបាត់បង់ការងាររបស់ខ្លួនចាប់តាំងពីចុងឆ្នាំ២០០៨ មក។ យោងតាមការគណនានៅក្នុងការសិក្សានេះ ការបាត់បង់ការងារបាននាំឱ្យចំនួនទឹកប្រាក់ផ្ញើទៅផ្ទះដែលធ្លាប់បានផ្ញើទៅឱ្យគ្រួសារនៅតាមជនបទធ្លាក់ចុះពី ៣០ ទៅ ៤៥ លានដុល្លារ។ ប្រការនេះ កើតឡើងនៅក្នុងពេលដែលប្រទេសកម្ពុជាត្រូវបង្កើតការងារថ្មីសម្រាប់កម្លាំងពលកម្មចំនួន ២៥០.០០០ នាក់ ជាបន្ថែមក្នុងមួយឆ្នាំៗ ដោយសារតែកំណើនចំនួនប្រជាពលរដ្ឋ។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក គឺជាការគំរាមកំហែងភ្លាមៗ កម្មករ និងអ្នកនៅក្នុងបន្ទុករបស់ពួកគេ។

របាយការណ៍នេះ បានកំណត់អត្តសញ្ញាណជនរងគ្រោះនៅលំដាប់ទីមួយ ដែលកំពុងរងគ្រោះដោយសារផលវិបាកបណ្តាលពីការធ្លាក់ចុះសេដ្ឋកិច្ច (ដែលរួមទាំងកម្មករនៅក្នុងឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មសាងសង់ ឧស្សាហកម្មទេសចរណ៍ កសិករ និងជនចំណាកស្រុក) និងជនរងគ្រោះនៅលំដាប់ទីពីរ (ដែលរួមទាំងគ្រួសារនានានៅជនបទ ដែលជាអ្នកទទួលបានតិចជាងមុននូវប្រាក់ផ្ញើទៅផ្ទះពីសមាជិកដែលធ្វើការនៅឆ្ងាយពីគ្រួសារ និងជនចំណាកស្រុកដែលធ្វើមាតុភូមិនិវត្តន៍ កុមារក្រីក្រ ក្រុមគ្រួសារ ដែលសព្វថ្ងៃជាអ្នកក្រីក្រនៅក្នុងទីក្រុង និងអ្នកដែលជិតធ្លាក់ខ្លួនក្រ ព្រមទាំងគ្រួសារនានាដែលគ្មានដីធ្លី) ដែលកំពុងរងគ្រោះដោយប្រយោលបណ្តាលពីផលវិបាកនានា ប៉ុន្តែក៏តាមទម្រង់ប្រកបដោយការប្រឈមតិចជាងផងដែរ។

ផលប៉ះពាល់បឋមមួយ ក្នុងចំណោមផលប៉ះពាល់នានាខាងសង្គមបានធ្លាក់ទៅលើស្ត្រីច្រើនជាងបុរសភាគច្រើន ដោយសារឧស្សាហកម្មកាត់ដេរ គឺជាវិស័យមួយដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ។ គម្រោងរបស់អន្តរទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ ស្តីពីការជួញដូរមនុស្ស (UNAIP) បានធ្វើការអង្កេតលើកុមារី និងស្ត្រីចំនួន ៣៥៧ នាក់ ដែលធ្វើការនៅក្នុងឧស្សាហកម្មសេវាកម្មកំសាន្ត នៅក្នុងខែមេសាដល់ខែឧសភា ឆ្នាំ២០០៩ ហើយរកឃើញថា ពួកគេភាគច្រើនចូលធ្វើការនៅក្នុងឧស្សាហកម្មនេះ ក្រោយពេលមានវិបត្តិហិរញ្ញវត្ថុពិភពលោកនៅក្នុងខែកញ្ញា ឆ្នាំ២០០៨។ អ្នកទាំងនោះទំនងជាជ្រើសយកវិបរនេះ ដោយសារតែជម្រើសសំរាប់មុខរបរមានតិចតួច និងកាន់តែលំបាកជ្រើសរើស ដោយសារតែពួកគេមានការអប់រំ និងការបណ្តុះបណ្តាលតិចតួច។ ការសិក្សានេះបានរកឃើញថា ការជាប់បំណុល គឺជាមូលហេតុចំបងមួយដែលធ្វើឱ្យស្ត្រីចូលទៅធ្វើការនៅក្នុងវិស័យសេវាកម្មកំសាន្ត អាស្រ័យហេតុនេះ នាំឱ្យពួកគេកាន់តែងាយរងគ្រោះ។

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានធ្វើការឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងផលប៉ះពាល់អវិជ្ជមានពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ។ ទាក់ទងនឹងគោលនយោបាយសារពើពន្ធ នៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាកំពុងមានឱនភាពថវិកាចំនួន ៤,៨% នៃ GDP ។ រដ្ឋាភិបាលបានព្យួរទុកនូវការប្រមូលយកប្រាក់ពន្ធប្រចាំខែចំនួនមួយភាគរយលើការចំណាយរបស់រោងចក្រកាត់ដេរនិងបានបង្កើនរយៈពេលអនុគ្រោះការយកពន្ធលើផលចំណេញពីរោងចក្រកាត់ដេរដែលបានបង្កើតនៅមុនឆ្នាំ២០០៦ ។ នៅក្នុងខែឧសភា ឆ្នាំ២០០៩ រដ្ឋាភិបាលបានផ្តល់ទឹកប្រាក់សរុបចំនួន ១៨ លានដុល្លាអាមេរិក តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ក្រោមទម្រង់ជាប្រាក់កម្ចីទៅឱ្យរោងម៉ាស៊ីនកិនស្រូវសម្រាប់បង្កើនសមត្ថភាពទិញ និងកិនស្រូវ ។ ផលចំណូលរបស់រដ្ឋាភិបាលបានធ្លាក់ចុះចំនួន ១១% នៅក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ ២០០៩ ធៀបនឹងរយៈពេលប្រាំខែដូចគ្នានេះនៅក្នុងឆ្នាំ២០០៨ ហើយគេនៅមិនទាន់ដឹងនៅឡើយទេថា តើរាជរដ្ឋាភិបាលកម្ពុជាអាចនឹងបំពេញតាមគោលដៅប្រាក់ចំណូលរបស់ខ្លួន នៅចុងឆ្នាំ ២០០៩ ឬយ៉ាងណាឡើយ ។ ប្រាក់ចំណូលកាន់តែតិចជាងមុន នឹងធ្វើឱ្យរដ្ឋាភិបាលមានមូលនិធិកាន់តែតិចជាងមុនសម្រាប់ការចំណាយ ។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះក៏បានធ្វើអត្តសញ្ញាណផងដែរថា រដ្ឋាភិបាលបានសន្សំប្រាក់ប្រមាណជា ៦០០ លានដុល្លារ ដែលអាចផ្តល់ឱ្យរដ្ឋាភិបាលនូវជម្រើស និងលទ្ធភាពក្នុងការពង្រីកសមត្ថភាពខាងសារពើពន្ធ ។

ដូចដែលលើកឡើងដោយអ្នកអភិវឌ្ឍន៍សហគមន៍ជាទូទៅ និងនៅក្នុងការសិក្សានេះ ប្រទេសកម្ពុជាគួរតែប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់ពីវិបត្តិនេះ និងពង្រឹងសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែង តាមរយៈការធ្វើចំរុះកម្ម មូលដ្ឋានសេដ្ឋកិច្ច និងប្រសិទ្ធភាពនៃការចំណាយក្នុងវិស័យសាធារណៈ ។ ការយកចិត្តទុកដាក់គួរតែផ្តោតលើសមធម៌នៃការទទួលបានសេវាពីកម្មវិធីចំណាយថ្មីៗណាមួយ និងគួរតែមានការពិចារណាអំពីសមត្ថភាពដែលមានស្រាប់ខាងស្ថាប័នផងដែរ ។ កម្មវិធីការពារសង្គមដែលមានស្រាប់ ដែលអនុវត្តដោយរដ្ឋាភិបាល និងសង្គមស៊ីវិល កំពុងកាត់បន្ថយឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ច មក លើប្រជាពលរដ្ឋមួយចំនួន ។ ទោះជាយ៉ាងណាក៏ដោយកម្មវិធីនានាទាំងនេះ មានលក្ខណៈដាច់ដោយដុំ និងមិនទៀងទាត់ ដោយមិនគ្របដណ្តប់ក្រុមងាយរងគ្រោះទាំងអស់នោះឡើយ ។ របាយការណ៍នេះគាំទ្រយ៉ាងមុតមាំ ដើម្បីឱ្យបង្កើតប្រព័ន្ធចម្រុះមួយនៅថ្នាក់ជាតិ ដែលមានលក្ខណៈទូលំទូលាយសម្រាប់កិច្ចការពារសង្គម ដូចដែលរដ្ឋាភិបាលបានប្រកាសនៅក្នុងខែធ្នូ ឆ្នាំ២០០៨ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ប្រកបដោយការដឹកនាំច្បាស់លាស់ ការសម្របសម្រួលបានល្អ និងក្របខ័ណ្ឌស្ថាប័នរឹងមាំ ។

លើសពីនេះ ការធ្លាក់ចុះនៃសេដ្ឋកិច្ចបានផ្តល់នូវឱកាសមួយសម្រាប់ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធនៅក្នុងវិស័យ ដូចជា សមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច ការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច និងផលិតភាពកសិកម្ម ដោយផ្តោតលើការរៀបចំស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់រយៈពេលយូរអង្វែងប្រកបដោយចីរភាពនិងសមធម៌ ការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ ព្រមទាំងផ្តោតលើសមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) រហូតដល់ឆ្នាំ២០១៥ ផងដែរ ។



# I សេចក្តីផ្តើម



គេមានការរំពឹងពីដំបូងថា ប្រទេសកម្ពុជានឹងមិនប្រឈមជាមួយវិបត្តិខាងហិរញ្ញវត្ថុឡើយ ដោយសារប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសនេះ នៅពុំសូវមានការរីកចម្រើន។ ការយល់ឃើញបែបនេះ ត្រូវបានបង្ហាញថាមិនត្រឹមត្រូវឡើយ។ ជាក់ស្តែងចាប់តាំងពីឆ្នាំ២០០៨ មក ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលរងការប៉ះទង្គិចខ្លាំងបំផុតនៅក្នុងតំបន់នេះ។ ដោយពុំមានផ្សារភាគហ៊ុន បំណុលបរទេស ចំបង៧សម្រាប់រយៈពេលខ្លី ឬបំណុលអន្តរធនាគារក្រៅប្រទេស និងការវិនិយោគលើផលប័ត្រសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មិនបានរងគ្រោះធ្ងន់ធ្ងរពីបញ្ហាកង្វះសាច់ប្រាក់នៅក្នុងរយៈពេលខ្លីចំពោះមុខ ឬការសងបំណុលជាសាច់ប្រាក់នោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ភាពងាយរងគ្រោះរបស់កម្ពុជានៅក្រោមសម្ពាធនៃការធ្លាក់ចុះសេដ្ឋកិច្ច បានបង្ហាញឱ្យឃើញច្បាស់តាមរយៈការពឹងផ្អែកយ៉ាងខ្លាំងនៃប្រទេសនេះទៅលើការនាំចេញសម្លៀកបំពាក់ ដែលភាគច្រើនទៅកាន់ទីផ្សារស.រ.អា និងសហភាពអឺរ៉ុប និងការពឹងផ្អែកលើវិស័យទេសចរណ៍ ជាពិសេស នៅក្នុងខេត្តសៀមរាប។ ការវិនិយោគដោយផ្ទាល់ពីបរទេស បានផ្តោតតែលើវិស័យទាំងពីរនេះ ក៏ដូចជាលើវិស័យសំណង់ផងដែរ ដែលរងការប៉ះទង្គិចជាបន្ថែម ដោយសារនិន្នាការដើរថយក្រោយនៅក្នុងទីផ្សារអចលនទ្រព្យលើពិភពលោក។ អាស្រ័យហេតុនេះ សេដ្ឋកិច្ចនេះបានរងគ្រោះដោយផ្ទាល់ ដោយសារតែប្រទេសនេះមានមូលដ្ឋានសេដ្ឋកិច្ចតូចចង្អៀត និងសេដ្ឋកិច្ចនៅជនបទមិនទាន់រីកចម្រើន។

ការធ្លាក់ចុះនៃវិស័យផលិតកម្ម និងសេវាកម្ម បាននាំឱ្យមានការបាត់បង់ការងារធ្វើជាច្រើនពាន់ ដែលភាគច្រើនធ្វើឱ្យប្រជាពលរដ្ឋនៅជនបទរងគ្រោះ។ ពលករភាគច្រើនដែលបាត់បង់ការងារ ត្រូវបានគេរំពឹងថានឹងចាកចេញពីទីក្រុងវិលត្រលប់ទៅកាន់គ្រួសាររបស់ខ្លួននៅឯជនបទវិញ។ វិស័យនៅជនបទ ដែលជាកន្លែងប្រជាពលរដ្ឋ ៩០% រស់នៅ បានរងគ្រោះដោយសារមានការវិនិយោគ និងការអភិវឌ្ឍតិចតួច ដែលឆ្លុះបញ្ចាំងតាមរយៈអត្រាទាបបំផុតនៃផលិតភាពកសិកម្មធៀបនឹងប្រទេសនានានៅក្នុងតំបន់នេះ។ ដោយហេតុថាគ្រួសារជាច្រើននឹងលែងបានទទួលប្រាក់ផ្ញើទៅផ្ទះ ដែលសមាជិកគ្រួសារផ្ញើមកដូចពីមុនទៀត ដោយសារតែវិបត្តិសេដ្ឋកិច្ច និងថែមទាំងត្រូវទទួលយកពលករដែលបាត់បង់ការងារថែមទៀតផងនោះ សេដ្ឋកិច្ចនៅជនបទនឹងត្រូវរងសម្ពាធកាន់តែខ្លាំងឡើង ដែលសព្វថ្ងៃនេះ កំពុងតែរងសម្ពាធនៃការធ្លាក់ចុះនៃថ្លៃផលិតផលកសិកម្មរួចទៅហើយនោះ។

ជាជាងការចង្អុលបង្ហាញអំពីមូលហេតុពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ការសិក្សានេះប៉ាន់ប្រមាណអំពីការប្រឈមនានាក្នុងពេលសព្វថ្ងៃ និងឱកាសនានាដែលប្រទេសកម្ពុជាមាន ហើយបន្ទាប់មកព្យាយាមពិនិត្យមើលដំណោះស្រាយ។ បញ្ហាជាច្រើនបានកើតឡើង ដោយសារបង្កុំនៃកត្តាជាច្រើនទាំងពីខាងក្នុង និងពីខាងក្រៅ។ វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក បានធ្វើឱ្យកត្តាទាំងនេះកាន់តែស្មុគស្មាញ និងបានបង្ហាញឱ្យឃើញពីនៃការប្រឈមរចនាសម្ព័ន្ធ ដែលមានសព្វថ្ងៃនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ការដោះស្រាយបញ្ហាទាំងនេះ នឹងអាចធ្វើឱ្យកម្ពុជាមិនត្រឹមតែបង្កើនការស្តារសេដ្ឋកិច្ចឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងការអភិវឌ្ឍដែលកាន់តែមានសមធម៌ជាងមុនផងដែរ នៅក្នុងរយៈពេលមធ្យម និងវែងខាងមុខ។

ផ្នែកទី ២ ចាប់ផ្តើមដោយពិនិត្យមើលឡើងវិញនូវផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកមកលើស្ថានភាពសេដ្ឋកិច្ច-សង្គម ដោយផ្តល់នូវការវិភាគអំពីកំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក របាយការណ៍នេះពិនិត្យមើលបណ្តាញនានានៃការបញ្ជូនសាច់ប្រាក់មកក្នុងប្រទេសកម្ពុជា ដែលរួមទាំងបណ្តាញបញ្ជូនដោយផ្ទាល់ (ប្រភេទផ្សេងៗនៃលំហូរដើមទុន ការបញ្ជូនសាច់ប្រាក់ ជំនួយអភិវឌ្ឍន៍ផ្លូវការ ។ល។) និងបណ្តាញមិនផ្ទាល់ (ថវិការបស់រដ្ឋាភិបាល អត្រាប្តូរប្រាក់ មេគុណនៃការចំណាយ ការវិលត្រឡប់នៃពលករចំណាកស្រុក)។[១] ផ្នែកទី ៣ ពិនិត្យមើលផលប៉ះពាល់នៅតាមវិស័យផងដែរ ដែលរួមទាំងការនាំចេញសម្លៀកបំពាក់

[១] "មេគុណនៃការចំណាយ" មានន័យថា ការចំណាយសាច់ប្រាក់មួយដុល្លារជាបន្ថែមទៅក្នុងសេដ្ឋកិច្ច អាចនាំឱ្យមានកំណើនលទ្ធផលច្រើនជាងមួយដុល្លារ ដោយសារប្រតិកម្មនៅក្នុងខ្សែចង្វាក់នៃការចំណាយ។ ដូចគ្នានេះដែរ ការដកចេញសាច់ប្រាក់មួយដុល្លារចេញពីសេដ្ឋកិច្ច នឹងនាំឱ្យមានការធ្លាក់ចុះច្រើនជាងមួយដុល្លារ។

ទេសចរណ៍ កសិកម្ម ទីផ្សារអចលនទ្រព្យ និងវិស័យសំណង់។ របាយការណ៍នេះ ធ្វើការវិភាគទិន្នន័យដែលមានស្រាប់ និងឯកសារសេដ្ឋកិច្ចសង្គមដែលមានសព្វថ្ងៃ ស្តីពីសេដ្ឋកិច្ចរបស់កម្ពុជា។ ផ្នែកទី៤ ពិនិត្យមើលក្រុមដែលងាយរងគ្រោះជាងគេ បណ្តាលពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និងប្រភេទខុសៗគ្នានៃភាពងាយរងគ្រោះ ដូចជា ការបាត់បង់ការងារ ការថយចុះនៃប្រាក់ចំណូល ការថយចុះប្រាក់ដែលសមាជិកផ្ញើមកឱ្យគ្រួសារ ការធ្លាក់ចុះនៃកម្រិតអាហារូបត្ថម្ភនិងសម្ពាធមកលើការចូលរៀន និងពលកម្មកុមារ។ ប្រជាពលរដ្ឋដែលពឹងផ្អែកលើទីផ្សារបរទេស ឬ FDI ដូចជា កម្មកររោងចក្រ កាត់ដេរ និងកម្មករសំណង់ ទំនងជារងផលប៉ះពាល់អវិជ្ជមានមុនគេ។ ឥទ្ធិពលបន្ទាប់បន្សំ ដែលជាផលប៉ះពាល់បណ្តាលពីវិបត្តិនេះ កំពុងតែបង្កើនសម្ពាធមកលើសេដ្ឋកិច្ចនៅជនបទ ដោយសារថ្លៃផលិតផលកសិកម្មបានធ្លាក់ចុះ ហើយប្រាក់ដែលសមាជិកបញ្ជូនពីទីក្រុងមកឱ្យគ្រួសារលែងមានតទៅទៀត ហើយកម្មករត្រូវវិលត្រឡប់មកផ្ទះវិញ។

របាយការណ៍នេះ លើកស្នើយុទ្ធសាស្ត្រចំនួនបី សំរាប់អ្នកកសាងគោលនយោបាយធ្វើការពិចារណា។ ទីមួយសារៈសំខាន់នៃការបង្កើតប្រព័ន្ធចម្រុះថ្នាក់ជាតិការពារសង្គម ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ច និងដើម្បីឱ្យប្រទេសនេះវិលត្រឡប់ទៅរកកំណើនដែលមានចីរភាព និងសមធម៌នៅក្នុងរយៈពេលវែង។ កិច្ចការពារសង្គម ដែលជាយន្តការដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយឥទ្ធិពលពីការធ្លាក់ចុះនៃសេដ្ឋកិច្ច ត្រូវបានពន្យល់ និងវិភាគនៅក្នុងផ្នែកទី ៤.៣។ បន្ទាប់មក ផ្នែកទី៥ លើកស្នើអនុសាសន៍ជាក់លាក់មួយចំនួនខាងគោលនយោបាយ ដែលរួមទាំងការបង្កើតប្រព័ន្ធចម្រុះមួយរបស់ជាតិសម្រាប់ការពារសង្គម។ សំណាញ់សុវត្ថិភាពសង្គមដែលរួមទាំងការផ្ទេរសាច់ប្រាក់ ការផ្ទេរផលមិនមែនជាសាច់ប្រាក់ និងប្រាក់កម្រៃ បានដាក់ជាចំបងនៅក្នុងរបៀបវារៈនៃគោលនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ គេមានការប្រឈមជាច្រើន ដែលរួមទាំងតម្រូវការឱ្យមាននិរន្តរភាពហិរញ្ញប្បទាននិងធនធាន និងការប្រឈមនានាលើប្រតិបត្តិការ ដែលរួមមាន ១. កម្រិតកំណត់នៃសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើផ្នែកសារពើពន្ធ ២. ការធ្វើអត្តសញ្ញាណនិងផ្តោតការយកចិត្តទុកដាក់លើអ្នកទទួលផល ៣. ការចូលរួមពាក់ព័ន្ធនៃដៃគូនានានៅក្នុងចំណោមមហាជន ៤. ការលេចធ្លាយដែលអាចកើតមាននៅក្នុងប្រព័ន្ធនេះ ៥.ការសម្រេចបានលទ្ធផលនៅទូទាំងប្រទេស ៦. ការតាមដាននិងការវាយតម្លៃលទ្ធផលនានា និង ៧.ការផ្តល់នូវសេវាកម្មប្រកបដោយគុណភាព ដូចជា ការអប់រំ និងសុខភាព។

ជម្រើសយុទ្ធសាស្ត្រទីពីរ គឺគោលនយោបាយសារពើពន្ធ។ ការចំណាយលើគម្រោងដែលជាការជម្រុញលើកទឹកចិត្ត បានក្លាយជាដំណើរការពេញនិយមពីសំណាក់រដ្ឋាភិបាលនានានៅជុំវិញពិភពលោក។ ការសិក្សានេះឱ្យយោបល់ថា ការចំណាយដែលជម្រុញការលើកទឹកចិត្តប្រចាំឆ្នាំ ឬការចំណាយច្រើនជាងមុនលើវិស័យសាធារណៈ គួរធ្វើឡើងតែនៅក្នុងករណីដែលមានការពិចារណាអំពីសមធម៌លើសិទ្ធិទទួលផលរបស់ក្រុមប្រជាពលរដ្ឋងាយរងគ្រោះ និងសមត្ថភាពខាងស្ថាប័នតែប៉ុណ្ណោះ។ ការសិក្សានេះ បានពិនិត្យមើលចំណងទាក់ទងសេដ្ឋកិច្ចដែលមិនសូវមានការរីកចម្រើន រវាងទីក្រុង និងទីជនបទ ក៏ដូចជាហានិភ័យដែលទាក់ទងនឹងប្រភេទនៃការចំណាយមួយចំនួនដែលអាចបង្កើនការនាំចូល ប៉ុន្តែមានការជម្រុញលើកទឹកចិត្តត្រឹមតិចតួចនៅមូលដ្ឋាន ឬដែលនាំឱ្យមានកំណើនថ្លៃដី និងកំណើនការប្រមូលយកដីធ្លីជាកម្មសិទ្ធិពីសំណាក់អ្នកមានធនធានច្រើន។ ការចំណាយដែលជម្រុញឱ្យមានការលើកទឹកចិត្ត គួរតែផ្តោតទៅលើផ្នែកនានាដែលពិតជាត្រូវការជាចាំបាច់ឱ្យមានការចំណាយបែបនោះ។

យុទ្ធសាស្ត្រទីបីសម្រាប់ការពិចារណា គឺកំណែទំរង់រចនាសម្ព័ន្ធទៅលើភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច ការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច និងកសិកម្ម ដោយផ្តោតលើការស្តារឡើងវិញសម្រាប់រយៈពេលវែង និងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ។ កាលៈទេសៈនៃសេដ្ឋកិច្ចសព្វថ្ងៃនេះ ផ្តល់ឱ្យរដ្ឋាភិបាលនូវឱកាស ដើម្បីបង្កើនកំនែទំរង់រចនាសម្ព័ន្ធនានា។ កំណែទម្រង់នេះ អាចផ្តល់ជាផលប្រយោជន៍ទាំងនៅក្នុងរយៈពេលខ្លីចំពោះមុខ និងរយៈពេលវែងសម្រាប់សេដ្ឋកិច្ច ដែលមានមូលដ្ឋានតូចចង្អៀត និងដែលមានចំណងទាក់ទងនៅក្នុងស្រុកក្នុងកម្រិតកំណត់។ តម្រូវការឱ្យមានកំណែលម្អសមត្ថភាពប្រកួតប្រជែង ការការធ្វើចម្រុះនៃមូលដ្ឋានសេដ្ឋកិច្ច និងកំណើនផលិតភាពកសិកម្ម មិនមែនបណ្តាលមកតែពីការធ្លាក់ចុះនៃសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែកាលៈទេសៈខាងសេដ្ឋកិច្ចបានជម្រុញបន្ថែមអោយមានតម្រូវការជាបន្ទាន់ក្នុងការបង្កើនល្បឿនកំណែទម្រង់ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងដើម្បីរៀបចំខ្លួនសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញផងដែរ។



# II ផលប៉ះពាល់លើម៉ាក្រូសេដ្ឋកិច្ច

## ២.១ ការព្យាករណ៍ និងការផ្លាស់ប្តូរទម្រង់នៃកំណើនសេដ្ឋកិច្ច

មុននឹងពិភាក្សាអំពីផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចទៅលើកំណើនសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០០៩ ប្រការសំខាន់ គឺត្រូវពិនិត្យមើលសមិទ្ធផល ដែលសម្រេចបាននៅក្នុងរយៈពេល ១៥ ឆ្នាំកន្លងទៅ ។ ក្រោយមានកំណើនជាមធ្យម ៨,៤% នៅក្នុងរយៈពេល ១៥ ឆ្នាំកន្លងមកនេះ និងមានកំណើនលេខពីរខ្ទង់គិតពីឆ្នាំ២០០៤ ដល់ ២០០៧ សេដ្ឋកិច្ចកម្ពុជាបានចុះខ្សោយមកនៅត្រឹមកំណើនដែលមានកម្រិតទាប ៦,៧% នៅក្នុងឆ្នាំ២០០៨ ដោយសកម្មភាពសេដ្ឋកិច្ចបានបន្ថយល្បឿននៅក្នុងត្រីមាសទីបួននៃឆ្នាំ២០០៨ ។[២] ដូចមានបង្ហាញនៅក្នុងរូបទី ១ កំណើនសេដ្ឋកិច្ចបានកើតឡើង ដោយសារការលូតលាស់នៃវិស័យឧស្សាហកម្ម ជាពិសេស វិស័យកាត់ដេរ ។ លើសពីនេះ សេវាកម្មក្នុងវិស័យទេសចរណ៍ បានរួមចំណែកយ៉ាងច្រើនទៅក្នុងវិស័យសេវាកម្ម ដែលបានជួយបង្កើនល្បឿនដល់កំណើន GDP ។ កសិកម្ម ដែលជាសកម្មភាពទ្រទ្រង់ការចិញ្ចឹមជីវិតជាបឋមសម្រាប់ប្រជាពលរដ្ឋចំនួន ៧០% នៅក្នុងទសវត្សរ៍កន្លងមកនេះ ទទួលបានកំណើនតិចតួចជាងគេ និងមានការប្រែប្រួលចុះឡើងខ្លាំងក្លាបំផុត ។

*រូបទី ១ : និន្នាការនៃកំណើនសេដ្ឋកិច្ចតាមវិស័យ (គិតជាភាគរយ ឆ្នាំ១៩៩៤-២០០៨)*




*ប្រភព : គណនីជាតិ ដែលរៀបចំដោយ NIS, ២០០៧ និង ២០០៩*

[២] វិទ្យាស្ថានជាតិស្ថិតិ (NIS) បានប៉ាន់ប្រមាណថាមានកំណើន ៦.៨% សម្រាប់ឆ្នាំ ២០០៨ ។ តួលេខចុងក្រោយ នៅពុំទាន់បានចេញផ្សាយនៅឡើយទេ ។

នៅខែធ្នូ ឆ្នាំ២០០៨ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករណ៍ថា GDP របស់កម្ពុជានៅឆ្នាំ២០០៩ អាចកើនឡើងក្នុងអត្រា ៤,៧% ចំណែកមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ព្យាករណ៍ថាមានកំណើន ៤,៨% និងធនាគារពិភពលោកថា មានកំណើន ៤,៩%។ ប៉ុន្តែតួលេខទាំងនេះ ត្រូវបានកែតម្រូវឡើងវិញដោយកាត់បន្ថយជាច្រើនមកត្រឹម -១,៥% សម្រាប់ការព្យាករណ៍របស់ ADB, -២,៧៥% សម្រាប់ការព្យាករណ៍របស់ IMF និង -១,0% សម្រាប់ការព្យាករណ៍របស់ធនាគារពិភពលោក (សូមមើលតារាងទី ១)។ នៅខែធ្នូ ឆ្នាំ ២០០៨ រដ្ឋាភិបាលកម្ពុជាបានព្យាករណ៍អំពីកំណើន ៦% សំរាប់ឆ្នាំ២០០៩ ហើយនៅក្នុងខែកក្កដា ឆ្នាំ២០០៩ បានកែតម្រូវការព្យាករណ៍របស់ខ្លួនមកនៅត្រឹម ២,១% វិញ។[៣]

*តារាងទី ១. ការព្យាករណ៍អំពី GDP របស់កម្ពុជា សម្រាប់ឆ្នាំ២០០៩*

| | GDP ដែលបានព្យាករណ៍ នៅខែធ្នូ ឆ្នាំ២០០៨ | ការព្យាករណ៍ចុងក្រោយ | | | | |
|---|---|---|---|---|---|---|
| | | GDP | កាត់ដេរ | ទេសចរណ៍ | ការសាងសង់ | កសិកម្ម |
| (វិភាគទានទៅក្នុង GDP នៅឆ្នាំ ២០០៨) | | (១00%) | (១៥%) | (១៣%) | (៦%) | (៣២%) |
| ADB | ៤,៧% | -១,៥% (កញ្ញា) | -៥% | -២% | -១,៥% | ៥-៦% |
| IMF | ៤,៨% | -២,៧៥% (កញ្ញា) | -៥% | -៦% | -២% | ១,៥% |
| WB | ៤,៩% | -១,0% (មីនា) | មិនបានព្យាករណ៍ | | | |
| រដ្ឋាភិបាលកម្ពុជា | ៦,0% | ២,១%[៤] | | | | |

*ប្រភព: ADB, IMF, World Bank and MEF*

គេមានការឯកភាពគ្នាថា វិស័យកាត់ដេរ ទេសចរណ៍និងការសាងសង់ នឹងត្រូវធ្លាក់ចុះ។ ទោះជាយ៉ាងណាក៏ដោយ គេនៅពុំទាន់ឯកភាពគ្នាលើកម្រិតនៃការធ្លាក់ចុះនេះឡើយ។ ទិន្នន័យដែលមានសម្រាប់រយៈពេលប្រាំខែដំបូងបង្ហាញថា មានការធ្លាក់ចុះច្រើនជាងការព្យាករណ៍នៅចុងឆ្នាំ២០០៨។ ជាក់ស្តែង ការនាំចេញសម្លៀកបំពាក់បានធ្លាក់ចុះ ២២% នៅក្នុងរយៈពេលប្រាំខែដើមឆ្នាំ២០០៩ ធៀបនឹងរយៈពេលប្រាំខែដូចគ្នានៅក្នុងឆ្នាំទៅ។ ផលចំណូលពីវិស័យទេសចរណ៍បានធ្លាក់ចុះជាច្រើន ដោយការចំណាយរបស់អ្នកទេសចរបានថយចុះយ៉ាងខ្លាំងនៅក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ២០០៩ ធៀបនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០០៨។[៥] វិស័យសាងសង់ដែលពឹងផ្អែកជាខ្លាំងលើ FDI បាន និងកំពុងធ្លាក់ចុះយ៉ាងខ្លាំង បន្ទាប់ពីមានការធ្លាក់ចុះនៃការផ្តល់ឥណទាននៅក្នុងប្រទេសរបស់វិនិយោគិនផ្ទាល់ រួមផ្សំជាមួយការធ្លាក់ចុះនៃតម្លៃអចលនទ្រព្យ។ ការងើបឡើងវិញនៃវិស័យទាំងនេះ មានការពាក់ព័ន្ធដោយផ្ទាល់ជាមួយការងើបឡើងវិញនៃទីផ្សារនៅលើពិភពលោក។

កម្រិតនៃការនាំចេញសម្លៀកបំពាក់ ពឹងផ្អែកជាខ្លាំងលើកត្តាចំនួនពីរ ពោល គឺទីផ្សាររបស់ស.រ.អា និងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។ ការនាំចូលសម្លៀកបំពាក់របស់ស.រ.អា នៅក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ មាន ១២,0៤% តិចជាងរយៈពេលដូចគ្នានេះនៅក្នុងឆ្នាំ២០០៨។ ជាការគួរឱ្យចាប់អារម្មណ៍ ការនាំចេញសម្លៀកបំពាក់របស់ប្រទេសបង់ក្លាដែស វៀតណាម និងចិន ទៅទីផ្សារ ស.រ.អា នៅក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ បានកើនឡើង ចំណែកការនាំចេញចម្លៀកបំពាក់របស់កម្ពុជាទៅស.រ.អា បានថយចុះ ២២%។ ការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជាធៀបនឹងប្រទេសដទៃ បង្ហាញអំពីតម្រូវការឱ្យប្រទេសកម្ពុជាឆាប់ធ្វើការបង្កើនឱ្យបានឆាប់រហ័សនូវសមត្ថភាពប្រកួតប្រជែងក្នុងវិស័យនេះ។

---

[៣] ការប្រាស្រ័យឆ្លើយឆ្លងជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។

[៤] ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងក្នុងបទបង្ហាញនៅក្នុងវេទិកាសាធារណៈ ស្តីពីផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក និងតម្រូវការអោយមានការឆ្លើយតបខាងគោលនយោបាយនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន នាថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩។

[៥] ចំនួនភ្ញៀវមកដល់កម្ពុជា បានធ្លាក់ចុះត្រឹមតែ ១\u17e2០៧5 នៅក្នុងរយៈពេលប្រាំមួយខែដំបូង ឆ្នាំ២០០៩ ធៀបនឹងរយៈពេលដូចគ្នានេះនៅក្នុងឆ្នាំ២០០៨ ប៉ុន្តែចំនួនភ្ញៀវមកដល់តាមយន្តហោះ បានធ្លាក់ចុះ ១៦\u17e2២១៥។ ចំនួនភ្ញៀវដែលធ្វើដំណើរតាមយន្តហោះមកដល់ក្រុងសៀមរាបបានធ្លាក់ចុះ ១៨\u17e2៤៥5 និងភ្នំពេញ ១៣\u17e2៣៧5 នៅក្នុងរយៈពេលដូចគ្នា។ តួលេខនេះបានបំពេញមកវិញតាមរយៈភ្ញៀវដែលធ្វើដំណើរតាមផ្លូវគោក និងផ្លូវទឹក។ ភ្ញៀវមកពី ប្រទេសវៀតណាម និងឡាវ បានជួយបង្កើនចំនួនភ្ញៀវ ប៉ុន្តែជាទូទៅ ការចំណាយមានកម្រិតទាបជាងខ្លាំងណាស់។

កសិកម្ម គឺជាវិស័យតែមួយគត់ ដែលមិនត្រូវបានព្យាករណ៍ថាធ្លាក់ចុះឡើយនៅក្នុងឆ្នាំ២០០៩ ដោយមានការសន្មតថា នឹងពុំមានភាពរាំងស្ងួត ឬទឹកជំនន់ខ្លាំងឡើយនៅចុងឆ្នាំនេះ។ ដោយសារកំណើននេះផ្អែកលើការដាំដំណាំជាក់ស្តែង រួមជាមួយការសន្មតថាថ្លៃផលិតផលកសិកម្មមានស្ថិរភាពផងដែរនោះADB បានព្យាករណ៍ថាវិស័យនេះទំនងជានឹងកើនឡើងប្រមាណ៥% ។ទោះជាយ៉ាងណាក៏ដោយ បើគិតពីផលចំណូល កសិករអាចកាន់តែធ្លាក់ខ្លួនលំបាកជាងមុនធៀបនឹងឆ្នាំ២០០៨ ដោយសារតែផលដំណាំជាច្រើន សព្វថ្ងៃនេះ លក់បានក្នុងតម្លៃទាបជាងមុន។ កសិករនានាក៏ប្រឈមផងដែរ ទៅនឹងកំណើនខ្ពស់នៃថ្លៃផលិត ជាពិសេស ថ្លៃចំណាយលើពលកម្ម គ្រឿងយន្ត និងជី នៅក្នុងឆ្នាំ២០០៨ បើទោះជាថ្លៃផលដំណាំបានចាប់ផ្តើមធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩ ក៏ដោយ ។[៦] កសិករជាច្រើនបានខាតបង់ដោយសារភាពមិនស្របគ្នារវាងថ្លៃចំណាយ និងផលចំណូល ។

ផ្អែកតាមការរកឃើញនេះ សេដ្ឋកិច្ចនៅក្នុងឆ្នាំ២០០៩ ទំនងជានឹងធ្លាក់ចុះ។ ការប្រព្រឹត្តទៅជាក់ស្តែងនៃសេដ្ឋកិច្ច ជាពិសេសនៅក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងការសាងសង់ រហូតមកទល់សព្វថ្ងៃនេះ កាន់តែទន់ខ្សោយជាងអ្វីដែលបានព្យាករណ៍ទៅទៀត។ បើទោះជាបរិមាណផលិតផលកសិកម្ម ទំនងជានឹងកើនឡើងក៏ដោយ ផលិតភាពទាបនៃកសិកម្ម និងកម្រិតកំណត់នៃចំណងទាក់ទងខាងសេដ្ឋកិច្ច មានន័យថា ការរួមចំណែកនៃវិស័យនេះទៅក្នុង GDP មានកម្រិតទាបខ្លាំងណាស់ធៀបនឹងសក្តានុពលរបស់វា។

បើទោះការអភិវឌ្ឍមានលក្ខណៈអវិជ្ជមានដូចថែងខាងលើក៏ដោយ គេឃើញមានសញ្ញាវិជ្ជមានមួយចំនួននៃកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់រយៈពេលមធ្យម។ ប្រព័ន្ធធនាគារបានពង្រីក ដោយមានការវិនិយោគយ៉ាងច្រើនពីធនាគារកូរ៉េថ្មីមួយ ដែលមានឈ្មោះថា Kookmin និងធនាគារវៀតណាមមួយ ដែលមានឈ្មោះថា Sacom[៧]។ បើទោះជាប្រាក់សន្សំនៅប្រទេសកម្ពុជា មានកម្រិតទាបជាងគេបំផុតនៅក្នុងតំបន់នេះក៏ដោយ ប្រាក់បញ្ញើកំពុងកើនឡើងដែលឆ្លុះបញ្ចាំងអំពីកំណើន ទំនុកចិត្តមកលើវិស័យធនាគារនៃប្រទេសកម្ពុជា។ ការចូលមកវិនិយោគនៃធនាគារទាំងពីរនេះ បាននាំឱ្យចំនួនធនាគារពាណិជ្ជនៅកម្ពុជាបានឡើងដល់ ២៩។ ចំនួនដ៏ច្រើននៃធនាគារអាចធ្វើឱ្យមានការប្រឈមកាន់តែខ្លាំងឡើងក្នុងការគ្រប់គ្រងធនាគារឱ្យមានប្រសិទ្ធភាព។ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលរួមទាំងការពង្រីកព្រលានយន្តហោះនៅសៀមរាប និងគម្រោងកសាង កន្លែងសម្រាកកាយខ្នាតធំ នៅក្នុងខេត្តដូចគ្នានេះ ក៏កំពុងពង្រីក និងកំពុងទាក់ទាញ FDI ផងដែរ។

## កំណែទម្រង់រចនាសម្ព័ន្ធ

ដូចនៅក្នុងករណីនៃប្រទេសជាច្រើនផងដែរ រចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជាបានផ្លាស់ប្តូរនៅក្នុងបណ្តាឆ្នាំកន្លងទៅនេះ ដោយមានការថយចុះខ្លះៗនៃវិស័យកសិកម្ម និងមានកំណើននៅក្នុងវិស័យឧស្សាហកម្មវិញ។ ភាគចំណែកនៃវិស័យកសិកម្មទៅក្នុង GDP បានធ្លាក់ចុះជាបន្តបន្ទាប់ពី ៤៥% នៅក្នុងឆ្នាំ១៩៩៣ មកត្រឹម ៣០% នៅក្នុងឆ្នាំ២០០៧ មុននឹងកើនឡើងវិញបន្តិចបន្តួចដល់ ៣២,៤% នៅក្នុងឆ្នាំ២០០៨ (សូមមើលរូបទី ២)។ ភាគចំណែកនៃកម្លាំងពលកម្មបានធ្លាក់ចុះពី ៧៥% មកត្រឹម ៥៦% នៅក្នុងរយៈពេលដូចគ្នានេះ។ វិស័យឧស្សាហកម្មបានកើនឡើងពី ១៣% នៃ GDP នៅក្នុងឆ្នាំ១៩៩៣ ដល់ ២២,៤% នៅក្នុងឆ្នាំ២០០៨ រីឯភាគចំណែកនៃកម្លាំងពលកម្មបានកើនឡើងពី ៥% ដល់ ១៥,៤% ។ តួលេខត្រូវគ្នានេះសម្រាប់កំណើននៃវិស័យសេវាកម្មមាន ៣៩% និង ៣៨,៨% ដែលជាការជម្រុញឱ្យភាគចំណែកនៃកម្លាំងពលកម្មកើនឡើងពី ២០% ដល់ ២៨,៧% ។

---

៦ Chan, Sophal. "The Impact of High Food Prices". Annual Development Review 2008-09. Phnom Penh: Cambodia Development Resource Institute (CDRI), 2009.

៧ Sovann, Nguon. "Sacombank launches with eye on VN trade". Phnom Penh Post 24 June 2009: 13.

*រូបទី ២.  ការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា (ភាគរយនៃការប្រែប្រួល គិតតាមថ្លៃបច្ចុប្បន្ន)*




*ប្រភព : គណនីជាតិចេញផ្សាយដោយ NIS នៅឆ្នាំ២០០៧ និង ២០០៩*

កំណើនគួរឱ្យកត់សំគាល់នៃសេដ្ឋកិច្ចនៅក្នុងទសវត្សរ៍កន្លងមកនេះ បានមកពីកំណើននៃវិស័យចំបង១ ដូចជា ទេសចរណ៍ កាត់ដេរ ការសាងសង់ និងកសិកម្ម។ ហេតុផលមួយដែលនាំឱ្យមានកំណើនខ្ពស់បែបនេះ និងការប្រែប្រួលភាគរយនៅក្នុងភាគចំណែកនៃសេដ្ឋកិច្ច គឺដោយសារលក្ខណៈអំណោយផលនៃទីផ្សារនាំចេញសម្លៀកបំពាក់ ដែលផ្តល់ដោយស.រ.អា និងសហភាពអឺរ៉ុប ដែលនាំឱ្យចំនួននៃរោងចក្រកាត់ដេរកើនឡើយយ៉ាងច្រើន។ កំណើនក្នុងវិស័យទេសចរណ៍ មានការទាក់ទងជាសំខាន់ទៅនឹងកម្រិតទាបនៃភាគរយពីដើមដំបូងនៅក្នុងភាគចំណែកសេដ្ឋកិច្ច និងភាពទាក់ទាញនៃប្រាសាទបូរាណ ដូចជា អង្គរវត្ត។ កំណើនជារួមដែលទទួលបាននេះ គឺដោយសារសន្តិភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលរដ្ឋាភិបាលកម្ពុជាខិតខំសម្រេចបាន ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ជាច្រើន។

វិស័យសេដ្ឋកិច្ចចំបង១នៃកម្ពុជា បានពង្រីកខ្លួនយ៉ាងឆាប់រហ័សចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ មក។ ភ្ញៀវទេសចរបរទេស បានចាប់ផ្តើមចូលមកក្នុងប្រទេសនេះនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ក្រោយពេលកម្ពុជាសម្រេចបានសន្តិភាពនិងស្ថិរភាពនយោបាយ។ នៅក្នុងឆ្នាំ១៩៩២ ចំនួនភ្ញៀវទេសចរបរទេសមកទស្សនាកម្ពុជាមានត្រឹមតែ ២០.០០០ នាក់ប៉ុណ្ណោះ ប៉ុន្តែចំនួននេះបានកើនឡើងយ៉ាងឆាប់រហ័សរហូតដល់ ២.១២៥.០០០ នាក់ នៅឆ្នាំ២០០៨។ ផលចំណូលពីវិស័យទេសចរណ៍ បានរួមចំណែកច្រើនជាង ១៣% ទៅក្នុងសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០០៨[៨]។ ឧស្សាហកម្មកាត់ដេរ ដែលរីកចម្រើនដល់កម្រិតកំពូលនៅចុងឆ្នាំ២០០៨ បានប្រើប្រាស់កម្លាំងពលកម្មចំនួន ៣៦០.០០០ នាក់ ដែលភាគច្រើនជាយុវតីក្មេងៗមកពីភូមិនានានៅជនបទ ដោយរោងចក្រកាត់ដេរមានចំនួនជិត ៣០០ នៅក្នុងឆ្នាំ២០០៨ ក្រោយពីបានចាប់ផ្តើមពីចំនួនត្រឹមប្រាំពីរប៉ុណ្ណោះនៅក្នុងឆ្នាំ១៩៩៤។ តាមរយៈកំណើនការវិនិយោគពីប្រទេសកូរ៉េ និងចិន វិស័យសំណង់នៅកម្ពុជាបានរីកចម្រើនជាខ្លាំង នៅក្នុងរយៈពេលភាគច្រើននៃទសវត្សរ៍កន្លងមកនេះ។ រីឯវិស័យកសិកម្ម វានៅតែជាមូលដ្ឋានដ៏សំខាន់សម្រាប់ទីជនបទក្នុងប្រទេសកម្ពុជា និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងទសវត្សរ៍កន្លងមកនេះ។ កំណើនក្នុងវិស័យកសិកម្ម ត្រូវបានរំពឹងថានឹងមានជាបន្ត ចំណែកវិស័យផ្សេងទៀតចំនួនបី ត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះ ឬនៅនឹងថ្កល់នៅក្នុងឆ្នាំ២០០៩ នេះ។

[៨] ក្រសួងទេសចរណ៍ ឆ្នាំ២០០៨

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក បានចាប់ផ្តើមមានឥទ្ធិពលនៅកម្ពុជានៅក្នុងត្រីមាសទីបួននៃឆ្នាំ២០០៨។ កង្វះការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច ត្រូវបានធ្វើអត្តសញ្ញាណជាបន្តបន្ទាប់ថាជាភាពទន់ខ្សោយធ្ងន់ធ្ងរមួយ។[៩] វិបត្តិពិភពលោក បានធ្វើឱ្យភាពងាយរងគ្រោះទាំងនេះកាន់តែស្មុគស្មាញ ដោយសារវាបានបង្កើតនូវភាពពឹងផ្អែកធ្ងន់ធ្ងរខ្លាំងពេកមកលើឧស្សាហកម្មកាត់ដេរ សេវាកម្មទេសចរណ៍ និងការសាងសង់ ដែលវិស័យទាំងនេះ សុទ្ធតែមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទីផ្សារ និងដើមទុនពីបរទេស។ នៅពេលដែលតម្រូវការសម្លៀកបំពាក់ និងឧស្សាហកម្មទេសចរណ៍លើពិភពលោកបានធ្លាក់ចុះ សេដ្ឋកិច្ចកម្ពុជា ទទួលបានចំណូលពីការនាំចេញក្នុងកម្រិតទាបជាខ្លាំង ព្រមទាំងប្រឈមនឹងការបាត់បង់ការងារជាច្រើនទៀតផង។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ខ្លួនគួរតែបង្កើនការយកចិត្តទុកដាក់ និងវិនិយោគបន្ថែមទៅលើវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ។ អាទិភាពជាបន្ទាន់ គឺការរៀបចំឱ្យវិស័យនេះអាចស្រូបយកពលករដែលបាត់បង់ការងារនៅទីក្រុង។ វិស័យនៅជនបទមានសក្តានុពលជាច្រើនសម្រាប់ការអភិវឌ្ឍ ដោយមានសក្តានុពលទូលំទូលាយសម្រាប់បង្កើនផលិតភាពកសិកម្ម ការពង្រីកវិសាលភាពដីដាំដំណាំ និងការកែលម្អសមត្ថភាពកែច្នៃផល។

របាយការណ៍ថ្មីមួយរបស់ធនាគារពិភពលោក បានរកឃើញដូចតទៅ : (i) កំណើនសេដ្ឋកិច្ចនៅក្នុងទសវត្សរ៍មុននេះ មិនទំនងជាបន្តដំណើរការនៅក្នុងទម្រង់បច្ចុប្បន្ននេះទេ (ii) តាមរយៈយុទ្ធសាស្ត្រដែលផ្តោតលើការបង្កើនសមត្ថភាពប្រកួតប្រជែង និងការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច កម្ពុជាអាចសម្រេចបាននូវកំណើនប្រកបដោយចីរភាព និង (iii) កម្ពុជាមានឱកាស ដើម្បីពង្រឹងសមាហរណកម្មក្នុងតំបន់ គ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព និងវិនិយោគសម្រាប់អនាគតរបស់ខ្លួន (តាមរយៈកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងការសន្សំបានច្រើនជាងមុន)។[១០]

របាយការណ៍ថ្មីមួយរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានឱ្យដឹងថា សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាស្ថិតក្នុងលំដាប់ទាបបំផុតនៅក្នុងតំបន់នេះ នៅលើវិស័យជាច្រើន ដែលរួមទាំង ជំនាញ និងធនធានមនុស្ស បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ បទប្បញ្ញត្តិ និងស្ថាប័ន។[១១] ការសិក្សានេះលើកស្នើថា បន្ថែមលើការកែលម្អទិដ្ឋភាពទាំងនេះ គេទាមទារឱ្យមានគោលនយោបាយថ្មីមួយឈុត ដើម្បីពង្រឹងការលូតលាស់នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ និងសហគ្រាសផលិតកម្មធុនស្រាល ទេសចរណ៍ ការសាងសង់ និង ICT។ គោលនយោបាយទាំងនេះ រួមមាន ការចាប់ផ្តើមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សដែលមានការគិតទុកបានល្អជាងមុន ដើម្បីបង្កើនចំនួនកម្មករជំនាញនៅក្នុងគ្រប់វិស័យ ដែលជាវិធានចំគោលដៅជាងមុននៅក្នុងគោលនយោបាយឧស្សាហកម្ម និងវិនិយោគ (គិតគូរឡើងវិញអំពីតំបន់សេដ្ឋកិច្ចពិសេស ឬ SEZs), ការអនុវត្តគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធចំគោលដៅ និងការកែលម្អលើការអនុវត្តក្របខ័ណ្ឌច្បាប់ឱ្យបានទៀងទាត់ជាងមុន។

ប្រការសំខាន់ គឺត្រូវកាត់បន្ថយការចំណាយលើមុខជំនួញ តាមរយៈការបង្កើនអត្រានៃក្រុមហ៊ុនដែលបានចុះបញ្ជីជាផ្លូវការនៅក្នុងប្រទេសកម្ពុជា។ វិស័យឯកជននៅតែតំណាងដោយវត្តមានយ៉ាងសន្ធឹកសន្ធាប់នៃសហគ្រាសខ្នាតតូច ដែលភាគច្រើនជាសហគ្រាសក្នុងវិស័យមិនផ្លូវការ។ សហគ្រាសខ្នាតតូចដែលប្រើប្រាស់ពលករពីមួយទៅដប់នាក់ មានចំនួន ៩៧% នៃក្រុមហ៊ុនសរុបចំនួន ៦៣.៥០៧ ដែលបានរាប់ឃើញនៅក្នុងជំរឿនធ្វើឡើងដោយសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងអង្គការមូលនិធិអាស៊ីនៅក្នុងឆ្នាំ២០០៨។ រីឯទិន្នន័យផ្លូវការទូទាំងប្រទេស ដែលបានពីវិទ្យាស្ថានជាតិស្ថិតិ (NIS) ស្តីពី "ការចុះបញ្ជីសហគ្រាស នៅកម្ពុជា ពីថ្ងៃទី ០៩ ខែកុម្ភៈ ដល់ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០០៩"[១២] បានរកឃើញថា នៅក្នុងប្រទេសកម្ពុជាមានសហគ្រាសចំនួន ៣៧៥.០៩៥។ កម្មករដែលមានប្រាក់កម្រៃមានត្រឹមប្រមាណ ២០% នៃចំនួនពលករសរុបប៉ុណ្ណោះ។ ក្នុងចំណោមក្រុមហ៊ុនទាំង ៦៣.៥០៧ មានក្រុមហ៊ុនត្រឹមតែប្រមាណ ២០.០០០ ដែលបានចុះបញ្ជីជាផ្លូវការនៅឯក្រសួងពាណិជ្ជកម្ម (MoC) និងមានតែក្រុមហ៊ុនមួយចំនួនតូចប៉ុណ្ណោះ ដែលបានបង់ពន្ធ និងមានរបាយការណ៍ជាផ្លូវការអំពីការចំណាយប្រចាំឆ្នាំ។ កង្វះការចុះបញ្ជីជាផ្លូវការ អាចនាំឱ្យមានកំណើនថ្លៃចំណាយលើការធ្វើជំនួញ។

---

៩ សូមអាន *Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction* (Discussion Paper No. 7). Phnom Penh: UNDP, 2009; *Sustaining Rapid Growth in a Challenging Environment* (Cambodia Country Economic Memorandum). Phnom Penh: World Bank, 2009; *Cambodia Human Development Report 2007: Expanding Choices for Rural People*. Phnom Penh: UNDP, 2007; *Cambodia: Halving Poverty by 2015?* (Cambodia Poverty Assessment 2006). Phnom Penh: World Bank, 2006.

១០ *Sustaining Rapid Growth in a Challenging Environment* (Cambodia Country Economic Memorandum). Phnom Penh: World Bank, 2009.

១១ *Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction* (Discussion Paper No. 7). Phnom Penh: UNDP, 2009.

១២ "The Preliminary Results of Nation-wide Establishment Listing of Cambodia 2009". National Institute of Statistics/Ministry of Planning, 2009. http://www.nis.gov.kh/index.php/statistics/surveys/el2009, accessed 7 June 2009.

## ២.២ ថវិការដ្ឋាភិបាល

បើគិតជាតួលេខសន្មតផលចំណូលរបស់រដ្ឋាភិបាលបានកើនឡើងជាបណ្តើរៗ ដោយសារកំណើនយ៉ាងខ្ពស់នៃ GDP និងការកែលម្អយន្តការប្រមូលប្រាក់ពន្ធ។ ចំណូលពន្ធ ក៏ដូចជាចំណូលមិនមែនពន្ធជារួមបានកើនឡើង។ ចំណូលសរុបបានកើនឡើង ១៩% នៅក្នុងឆ្នាំ២០០៥ កើន ១០% នៅឆ្នាំ២០០៦ កើន ២៧% នៅឆ្នាំ២០០៧ និង ២៤% នៅឆ្នាំ២០០៨។ បើទោះជាមានជោគជ័យនៅក្នុងដំណាក់កាលដំបូងនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ (PRM) ក៏ដោយ ចំណូលជាមធ្យមរបស់រដ្ឋាភិបាលមានត្រឹមតែ ១២% នៃ GDP ប៉ុណ្ណោះ នៅទសវត្សរ៍មុននេះ ធៀបនឹងអត្រាមធ្យម ១៦% នៅក្នុងប្រទេសផ្សេងទៀត នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ ពន្ធ គឺជាប្រភពចំបងនៃចំណូលរបស់រដ្ឋាភិបាល ដែលត្រូវជា ៧២% ដល់ ៨៤% នៃចំណូលសរុបសម្រាប់រយៈពេលប្រាំឆ្នាំមុននេះ។

កំណើនចំណូលរបស់រដ្ឋាភិបាល បានធ្វើឱ្យមានកំណើនការចំណាយ។ ការចំណាយសរុបរបស់រដ្ឋាភិបាលបានកើនឡើងជាច្រើនក្នុងអត្រា ៧% នៅក្នុងឆ្នាំ២០០៥ កើន ២២% នៅឆ្នាំ២០០៦ កើន ១៨% នៅឆ្នាំ២០០៧ និង ២០% នៅឆ្នាំ២០០៨។ ការចំណាយនៅឆ្នាំ២០០៩ ត្រូវបានព្យាករណ៍ថាមាន ៧.២៥៩ ពាន់លានរៀល (១,៨ ពាន់លានដុល្លារ) ដែលត្រូវជា ២៨% ច្រើនជាងការចំណាយនៅឆ្នាំ២០០៨។ ការបង្កើនថវិកាបានធ្វើឡើងនៅក្នុងពាក់កណ្តាលឆ្នាំ២០០៨ មុននឹងប្រទេសនេះបានរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានពិចារណាអំពីការបង្កើនថវិកានេះថា ជាកញ្ចប់ថវិកាជាក់ស្តែង បន្ថែមលើកំណើនការចំណាយលើវិស័យនានាផ្សេងទៀតដែលជាចំណុចដៅ។

បើគិតជាតួលេខសន្មត[១៣] ឱនភាពថវិកាបានកើនឡើងចាប់ពី ៨៣៥ ពាន់លានរៀល នៅក្នុងឆ្នាំ២០០៧ ដល់ ១.០៤៧ ពាន់លានរៀល នៅក្នុងឆ្នាំ២០០៨។ បើគិតពីអត្រាធៀបឱនភាពបានធ្លាក់ចុះពី ២៨% នៃការចំណាយសរុប ឬ ៤% នៃ GDP មកត្រឹម ១៧% នៃការចំណាយសរុប ឬ ៣% នៃ GDP ពីឆ្នាំ២០០៥ ដល់ ២០០៨ (សូមមើលរូបទី ៣)។ ឱនភាពដែលបានគ្រោងសម្រាប់ ឆ្នាំ២០០៩ គឺ ៤,៨% នៃ GDP។ ហិរញ្ញប្បទានបរទេសរួមចំណែកបំពេញលើឱនភាពថវិកា ក៏ដូចជាសម្រាប់ប្រើប្រាស់ជាប្រាក់សន្សំរបស់រដ្ឋាភិបាលផងដែរ។ ជាលទ្ធផល នៅចុងឆ្នាំ២០០៨ រដ្ឋាភិបាលសន្សំបានប្រមាណ ៦០០ លានដុល្លារ (ឬ ៦% នៃ GDP នៅក្នុងឆ្នាំ២០០៨) ដាក់តំកល់ទុកនៅក្នុងធនាគារកណ្តាល។ ទឹកប្រាក់នេះ ត្រូវបានត្រៀមបម្រុងទុក ដើម្បីផ្តល់លទ្ធភាពខាងសារពើពន្ធសម្រាប់ជាវិធានការបន្ថែមនៅក្នុងពេលមានវិបត្តិ។ គេអាចប្រើប្រាស់ប្រាក់សន្សំនេះ សម្រាប់កាត់បន្ថយផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចមកលើអ្នកក្រីក្រ ក៏ដូចជាធ្វើការកែលម្អមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា ដើម្បីទទួលបានការអភិវឌ្ឍប្រកបដោយចីរភាពរយៈពេលវែងផងដែរ។

*រូបទី ៣. ផលចំណូលរបស់រដ្ឋាភិបាល ការចំណាយ និងឱនភាព (គិតជាពាន់លានរៀល)*




*ប្រភព: MEF*

[១៣] "តួលេខសន្មត" មានន័យថា ផ្អែកលើថ្លៃទំនិញបច្ចុប្បន្ន ឬមិនបានគិតបញ្ចូលអតិផរណាឡើយ។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ដោយសារវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក និងការធ្លាក់ចុះជាបន្តនូវផលចំណូលរដ្ឋាភិបាលត្រូវប្រឹងប្រែងបន្ថែមទៀត ទើបអាចសម្រេចបានចំណុចដៅដែលមានចែងនៅក្នុងថវិកាឆ្នាំ២០០៩។ តួលេខអំពីថវិកា ត្រូវបានប៉ាន់ស្មានក្នុងកម្រិតទាបសម្រាប់រយៈពេលប្រាំឆ្នាំចុងក្រោយនេះ ជាពិសេស ចាប់តាំងពីមានការអនុវត្តកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFM) ។ផលចំណូលជាក់ស្តែងដែលទទួលបាន មានកម្រិតខ្ពស់ជាខ្លាំងធៀបនឹងចំណុចដៅខាងថវិកា ។ផលចំណូលរបស់រដ្ឋាភិបាលត្រូវបានរំពឹងថា នឹងថយចុះពី ១២% នៃ GDP មកត្រឹម ១១% នៅឆ្នាំ២០០៩។ ប៉ុន្តែ ការចំណាយសរុបត្រូវបានព្យាករណ៍ថាកើនឡើង បើគិតជាតួលេខសន្មត ពោល គឺចាប់ពី ១៤% នៃ GDP នៅឆ្នាំ២០០៨ ដល់ ១៥,៨% នៅឆ្នាំ២០០៩។

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ការចំណាយនៅឆ្នាំ២០០៩ អាចនឹងកើនឡើងបាន តែក្នុងករណីដែលការព្យាករណ៍ដូចខាងក្រោមនេះមានសុក្រឹត្យភាព :

- ការធ្លាក់ចុះនៃផលចំណូល គិតជាតួលេខជាក់ស្តែង[១៤] មានត្រឹមតែ ១%នៃ GDP
- ចំណាយចរន្ត កើនឡើងពី ៨,៥% នៃ GDP ដល់ ៩,៥%
- ចំណាយមូលធន កើនឡើងពី ៥,៨% នៃ GDP ដល់ ៦,៣%
- ការចំណាយហិរញ្ញវត្ថុមានប្រភពនៅក្នុងប្រទេសកើនឡើង ២៣% បើគិតជាតួលេខសន្មត
- ការចំណាយហិរញ្ញវត្ថុបានពីក្រៅប្រទេសកើនឡើង ១១,៥% បើគិតជាតួលេខសន្មត
- អតិរេកថវិកាចរន្ត ថយចុះពី ៣,២% នៃ GDP មកត្រឹម ១,២%
- ឱនភាពថវិកាជារួម កើនឡើងពី -២.២% នៃ GDP ដល់ -៤,៨%
- ហិរញ្ញប្បទានពីបរទេស មាន ៤,៧% នៃ GDP (មិនមែនជំនួយអភិវឌ្ឍន៍ផ្លូវការ “ODA” ទាំងអស់ សុទ្ធតែបានរួមបញ្ចូលនៅក្នុងថវិកានេះទេ។ មានតែជំនួយបច្ចេកទេសដែលទាក់ទងនឹងការវិនិយោគ និងការចំណាយលើការវិនិយោគទេ ដែលបានបញ្ចូលនៅក្នុងថវិកានេះ។ សម្រាប់ឆ្នាំ២០០៩ មានតែ ៤៦២ លានដុល្លារ ក្នុងចំណោមទឹកប្រាក់ ៩៥០ លានដុល្លារប៉ុណ្ណោះ ដែលត្រូវបានបញ្ចូលទៅក្នុងថវិកានេះ។ មិនមែនគ្រប់ការសន្យាទាំងអស់ នឹងត្រូវបើកផ្តល់ជាសាច់ប្រាក់នោះឡើយ ដោយត្រូវគិតផងដែរ អំពីសមត្ថភាពអតិបរមាដែលអាចទទួលយកនូវការចំណាយ ប្រាក់បៀវត្សរ៍ និងជំនួយបច្ចេកទេស ។ល ។)
- ហិរញ្ញប្បទានក្នុងស្រុក កើនឡើងបាន ៣% នៃ GDP ។[១៥] នៅឆ្នាំ២០០៨ ប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅក្នុងធនាគារកណ្តាលបានកើនឡើង ៣% នៃ GDP ដែលធ្វើឱ្យមានកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។ នៅឆ្នាំ២០០៩ ពុំមានហិរញ្ញប្បទានក្នុងស្រុកឡើយ ដែលមានន័យថា ប្រាក់បញ្ញើរបស់រដ្ឋាភិបាលពុំមានការកើនឡើងឡើយ) ។ប្រការនេះបានសេចក្តីថា ផលចំណូលដែលទទួលបាននៅក្នុងឆ្នាំ២០០៨ នឹងត្រូវប្រើប្រាស់សម្រាប់បំពេញឱ្យការចំណាយនៅឆ្នាំ២០០៩។

[១៤] "ជាតួលេខជាក់ស្តែង" មានន័យថា វាផ្អែកលើថ្លៃថេរ តែមិនមែនផ្អែកលើអតិផរណាឡើយ ។
[១៥] តាមការគណនានៅក្នុងគណនេយ្យ សញ្ញា [-] មានន័យថា កំណើនការប្រមូលផ្តុំធនធាន ចំណែក [+] មានន័យថា ការចំណាយ ។

*តារាងទី ២. ថវិកាជាតិឆ្នាំ២០០៨ និងឆ្នាំ២០០៩ (លានដុល្លារ)*

| | ថវិកាឆ្នាំ ២០០៨ | ថវិកាឆ្នាំ ២០០៩ | កំណើន % ពីឆ្នាំ ២០០៨ ដល់ ២០០៩ | ថវិកាឆ្នាំ២០០៩ គិតជា % នៃ GDP |
|---|---|---|---|---|
| ចំណូលសរុប | ១.០០២ | ១.៣១៦ | ៣១,៣ | ១១,១ |
| ចំណូលពន្ធ | ៧៩០ | ១.០៥៩ | ៣៤,០ | ៩,១ |
| ចំណូលពន្ធគយ | ៤៩៨ | ៥៨៥ | ១៧,៦ | ៤,៩ |
| ប្រាក់បញ្ញើដែលបានពីពន្ធ | | ៤១៥ | ៥៤,៥ | ៣,៥ |
| ចំណូលមិនមែនពន្ធ | ១៧៣ | ២១២ | ២២,៧ | ១,៥ |
| ចំណូលមូលធន | ៣៨ | ៤៥ | ១៦,៦ | ០,៤ |
| ការចំណាយសរុប | ១.៣៨៥ | ១.៧៨៧ | ២៩,០ | ១៥,៨ |
| ការចំណាយចរន្ត | ៨៧០ | ១.១៣៦ | ៣០,៥ | ៩,៥ |
| រដ្ឋបាលទូទៅ | ១១៩ | ១៤៩ | ២៥,៥ | ១,៣ |
| ការពារជាតិ និងសន្តិសុខ | ១៣៣ | ២១៩ | ៦៤,១ | ១,៨ |
| វិស័យសង្គម | ៣១៩ | ៣៩០ | ២២,៥ | ៣,៣ |
| សុខាភិបាល | ៩៩ | ១២៣ | ២៤,៤ | ១,០ |
| ការអប់រំ | ១៥២ | ១៨១ | ១៩,៥ | ១,៥ |
| វិស័យសេដ្ឋកិច្ច | ៧៣ | ៨៨ | ២១,១ | ០,៧ |
| កសិកម្ម | ១៦ | ១៩ | ១៦,៧ | ០,២ |
| ការអភិវឌ្ឍជនបទ | ១១ | ១៦ | ៣៦,២ | ០,១ |
| ធនធានទឹក | ៦ | ៨ | ២៩,២ | ០,១ |
| វិស័យរងសេដ្ឋកិច្ច និងកិច្ចការពារសង្គម | ៣៦ | ១១៥ | ២២៤,០ | ១,០ |
| ការចំណាយមូលធន | ៥១៥ | ៦៤៩ | ២៦,១ | ៥,៣ |
| ប្រភពមូលធនក្នុងស្រុក | ១៧៣ | ២១៣ | ២៣,៣ | ១,៨ |
| ប្រភពមូលធនពីក្រៅប្រទេស | ៣៤១ | ៤១៥ | ២១,៤ | ៣,៥ |
| សមតុល្យចរន្ត | ៩៣ | ១៣៥ | ៤៤,៩ | ១,២ |
| សមតុល្យសរុប (មិនគិតជំនួយឥតសំណង) | -៣៨៣ | -៤៧០ | ២២,៧ | -៤,៨ |
| ហិរញ្ញប្បទាន | ៣៨៣ | ៤៧០ | ២២,៧ | ៤,៨ |
| ពីបរទេស (ជាក់ស្តែង) | ៣៦៦ | ៤៦២ | ២៦,២ | ៤,៧ |
| ក្នុងស្រុក (ជាក់ស្តែង) | ១៧ | ៨ | -៥២,៩ | ០ |
| ហិរញ្ញប្បទានពីធនាគារ (ជាក់ស្តែង) | ២៩ | ១៥ | -៤៧,៥ | ០,១ |

*ប្រភព : MEF*

បើគិតពីផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចកត្តាសំខាន់បំផុតគឺការប្រមូលផលចំណូលបានចុះទាបជាងការរំពឹងទុក ។ដូចមានបង្ហាញក្នុងរូបទី ៤ នៅក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ ផលចំណូលបានថយចុះ ១១% ធៀបនឹងរយៈពេលប្រាំខែដូចគ្នានៃឆ្នាំ២០០៨។ គេនៅពុំទាន់ដឹងនៅឡើយទេថា តើរដ្ឋាភិបាលនឹងអាចសម្រេចបាននូវចំណុចដៅរបស់ខ្លួនឬទេ រហូតដល់ចុង ឆ្នាំ២០០៩។ ដោយសារការថយចុះនៃពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ច ដោយពុំមានសញ្ញាច្បាស់លាស់អំពីថា តើនៅពេលណា ទើបសេដ្ឋកិច្ចនឹងរីកចម្រើនឡើងវិញនោះ ឱកាសដែលអាចសម្រេចតាមចំណុចដៅមិនមានច្រើនឡើយ ។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលកម្ពុជាមានលទ្ធភាពយ៉ាងច្រើនខាងសារពើពន្ធ ដើម្បីបង្កើនការចំណាយសាធារណៈ ដោយសារមានប្រាក់បញ្ញើដែលសន្សំបានប្រមាណ ៦០០ លានដុល្លារ ដែលរកបាននៅក្នុងទស្សវត្សរ៍កន្លងមកនេះ។ គេមានកង្វល់ជាក់ស្តែងដែលថា កំណើនយ៉ាងច្រើននៃការចំណាយរបស់រដ្ឋាភិបាល អាចបង្កឱ្យមានការចុះថ្លៃនៃប្រាក់រៀល និងអាចនាំឱ្យមានកំណើនអតិផរណាយ៉ាងខ្លាំង។ រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅរក្សាតុល្យភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះត្រឹម -៤%

នៅក្នុងខែមេសា ឆ្នាំ២០០៩ និង -៥,៧% នៅក្នុងខែឧសភា ឆ្នាំ២០០៩។[១៦] ប្រសិនបើត្រូវបង្កើនការចំណាយសាធារណៈ គេត្រូវតែមានការប្រុងប្រយ័ត្ន និងធ្វើវាឱ្យមានប្រសិទ្ធភាព។ មានសំណើមួយចំនួន ដែលអាចគ្មាន ឬមានឥទ្ធិពលតិចតួចមកលើអតិផរណា មានបង្ហាញនៅក្នុងផ្នែកទី ៥ ខាងក្រោមនេះ។

ការផ្គត់ផ្គង់ប្រាក់រៀលមានត្រឹមតែប្រមាណ១០% នៃសាច់ប្រាក់ក្នុងចរាចរសរុបនៅក្នុងប្រទេសកម្ពុជា។ការគ្រប់គ្រងអត្រាប្តូរប្រាក់មិនសូវលំបាកពេកនោះទេ នៅក្រោមកាលៈទេសៈទាំងនេះ។ ធនាគារជាតិនៃកម្ពុជា (NBC) ច្រើនតែទិញទាំងអស់នូវប្រាក់រៀលដែលលើសពីតម្រូវការទីផ្សារ ដើម្បីកាត់បន្ថយការប្រែប្រួលនៃអត្រាប្តូរប្រាក់។ ដោយសារប្រាក់បញ្ញើរបស់រដ្ឋាភិបាល មានទាំងជាប្រាក់រៀល និងដុល្លារ ការចំណាយអាចធ្វើឡើងទាំងជារូបិយប័ណ្ណទាំងពីរបែប ដើម្បីកាត់បន្ថយសម្ពាធនៃការធ្លាក់ថ្លៃ ដែលអាចកើតមានមកលើតម្លៃនៃប្រាក់រៀល។

## និន្នាការនៃផលចំណូលរបស់ជាតិ

*រូបទី៤. និន្នាការនៃផលចំណូលរបស់ជាតិ ខែមករា ២០០៨ ដល់ខែឧសភា ២០០៩ (គិតជាពាន់លានរៀល)*




*ប្រភព: MEF*

ផលចំណូលអាចកើនឡើង តាមរយៈការពង្រឹងជាបន្ថែមនូវវិធានការប្រមូលប្រាក់ពន្ធ និងកាត់បន្ថយអំពើពុករលួយ។ការថយចុះនៃអំពើពុករលួយ មានន័យថា មិនត្រឹមតែបង្កើនផលចំណូលសម្រាប់រដ្ឋាភិបាលនោះទេ ប៉ុន្តែថែមទាំងកែលម្អបរិយាកាសវិនិយោគផងដែរ។ នៅក្នុងការវាយតម្លៃលើកទីពីររបស់ធនាគារពិភពលោក និង IFC អំពីបរិយាកាសវិនិយោគ គេរកឃើញថា អំពើពុករលួយ គឺឧបសគ្គទីមួយចំបងជាងគេនៅក្នុងការប្រកបរបរអាជីវកម្ម។[១៧]

រដ្ឋាភិបាលនៅមានឱកាសយ៉ាងច្រើន ដើម្បីបង្កើនផលចំណូលតាមរយៈការធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូ។ នៅពេលថ្មីៗនេះ កម្ពុជាបានធ្វើឯកជនភាវូបនីយកម្មចំការកៅស៊ូចំនួនប្រាំពីររបស់រដ្ឋ ដែលមានផ្ទៃដីសរុបទំហំ ៧០.០០០ ហិកតា និងឧបករណ៍កែច្នៃកៅស៊ូផងដែរ។ ការធ្វើឯកជនភាវូបនីយកម្មភាគច្រើន បានធ្វើឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលក្នុងនោះ ការធ្វើឯកជនភាវូបនីយកម្មចុងក្រោយបានប្រព្រឹត្តទៅចប់សព្វគ្រប់នៅក្នុងដើមឆ្នាំ២០០៩។ ចំការកៅស៊ូឯកជនមួយ អាចលក់ក្នុងតម្លៃ ៥.០០០-

[១៦] "Consumer Price Index". Phnom Penh: National Institute of Statistics/Ministry of Planning, 2008. http://www.nis.gov.kh/index.php/statistics/cpi-cost-price-index. July 2009. Web. 29 July 2009.

[១៧] Second Investment Climate Assessment: A Better Investment Climate to Sustain Growth in Cambodia. Phnom Penh: World Bank and International Finance Corporation, 2009.

១០.០០០ ដុល្លារ ក្នុងមួយហិកតា។ ប្រសិនបើធ្វើឯកជនភាវូបនីយកម្មបានត្រឹមត្រូវ ផលចំណូលសម្រាប់រដ្ឋអាចមានចំនួនក្រាស់ក្រៃល។ ដោយសារក្រុមហ៊ុនដែលបានបន្តគ្រប់គ្រងចំការកៅស៊ូ ត្រូវបានរដ្ឋាភិបាលពន្យារពេលឱ្យអាចធ្វើការបង់ប្រាក់ ដែលនៅជំពាក់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត ការប្រមូលប្រាក់ជំពាក់ទាំងនេះមានសារៈសំខាន់ណាស់ សម្រាប់បញ្ចូលជាថវិកាជាតិ។ នៅពេលពិចារណាអំពីការធ្វើឯកជនភាវូបនីយកម្ម គេត្រូវតែមានកិច្ចការពារសមស្រប ដើម្បីចៀសវាងការប្រើប្រាស់មិនត្រឹមត្រូវនូវមូលនិធិសាធារណៈទាំងនេះ។

## ២.៣ ជំនួយអភិវឌ្ឍន៍ផ្លូវការ

ក្រោយពេលរងគ្រោះដោយសារសង្គ្រាមស៊ីវិលដ៏មហន្តរាយរយៈពេល ៣០ ឆ្នាំ កម្ពុជាបានចាត់ចែងឱ្យមានការបោះឆ្នោតជាសកលលើកដំបូងរបស់ខ្លួននៅឆ្នាំ១៩៩៣ ក្រោមការគាំទ្រពីអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)។ ចាប់តាំងពីពេលនោះមក ប្រទេសនេះ សម្រេចបាននូវការបម្លែងមួយគួរឱ្យកត់សំគាល់ពីប្រទេសមួយ ដែលហែកហួរដោយសង្គ្រាម ទៅរកសង្គមមួយនៅដំណាក់កាលក្រោយជម្លោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាធិបតេយ្យដ៏ក្មេងខ្ចីនេះ នៅតែពឹងផ្អែកយ៉ាងខ្លាំងលើជំនួយពីបរទេសក្រោមទម្រង់ជា ODA ដែលផ្សំដោយជំនួយឥតសំណង និងប្រាក់កំចី។ តាមធម្មតា ប្រាក់កំចីមានពី ២០-៣០% នៃទឹកប្រាក់ដែលបានបើកផ្តល់សរុប និងសាច់ប្រាក់ដែលនៅសល់បានមកពីជំនួយឥតសំណង។

ទីភ្នាក់ងារអភិវឌ្ឍន៍នាំមុខនានា រួមមាន ADB ទីភ្នាក់ងារ អ.ស.ប ដែលរួមទាំងធនាគារពិភពលោក IMF និងមូលនិធិពិភពលោក ដៃគូអភិវឌ្ឍន៍សហភាពអឺរ៉ុប ដែលរួមទាំង ចក្រភពអង់គ្លេស បារាំង អាល្លឺម៉ង់ ស៊ុយអែដ ដាណឺម៉ាក់ អេស្ប៉ាញ ហ្វាំង ឡង់ និងបែលហ្ស៊ិក។ ជំនួយទ្វេភាគី ភាគច្រើនបានមកពីប្រទេសជប៉ុន ចិន ស.រ.អា អូស្រ្តាលី សាធារណរដ្ឋកូរ៉េ ស្វីស និងនូវែលហ្សេឡង់។[១៨]

និន្នាការរបស់ ODA មានចែងនៅក្នុងរូបទី ៥ ខាងក្រោម។

*រូបទី ៥. ការបើកផ្តល់សាច់ប្រាក់ដោយស្ថាប័នពហុភាគី និងទ្វេភាគី និងសហភាពអឺរ៉ុប ឆ្នាំ១៩៩២-២០០៨ (ពាន់ដុល្លារ)*




*ប្រភព: CDC*

[១៨] The Cambodia Aid Effectiveness Report 2008. Phnom Penh: Council for the Development of Cambodia-Cambodian Rehabilitation and Development Board, 2008. ii.

បរិមាណជំនួយ ODA ដែលបានផ្តល់មកឱ្យកម្ពុជា បានកើនឡើងជាបណ្តើរៗនៅក្នុងទសវត្សរ៍កន្លងមកនេះ (ពី ២៥០ លានដុល្លារ នៅឆ្នាំ១៩៩២ ដល់ជិត ៩០០ លានដុល្លារ នៅឆ្នាំ២០០៨ បើទោះជាទឹកប្រាក់នេះ នៅតែស្ថិតក្នុងអត្រា ៨-៩% នៃ GDP ក៏ដោយ)។ ទឹកប្រាក់នេះបានធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ១៩៩៧ នៅពេលដែលប្រទេសនេះ បានធ្លាក់ក្នុងស្ថានភាពមិនប្រាកដប្រជាខាងនយោបាយ។ នៅក្នុងវេទិកាសម្របសម្រួលការអភិវឌ្ឍកម្ពុជាចុងក្រោយនេះ (CDCF) ក្នុងខែធ្នូ ឆ្នាំ២០០៨ សហគមន៍អន្តរជាតិបានសន្យាផ្តល់ជំនួយឥតសំណង និងប្រាក់កម្ចីយ៉ាងច្រើនបំផុតដល់ ៩៥០ លានដុល្លារ (ឬប្រមាណ 10% នៃ GDP) ដល់ព្រះរាជាណាចក្រកម្ពុជានៅក្នុងពេលមានវិបត្តិ ដែលគេរំពឹងថា ODA នឹងធ្លាក់ចុះជាគំហុក។ ទោះជាយ៉ាងណាក៏ដោយ ការសន្យាអាចមានហានិភ័យនៅត្រង់ថា ការផ្ទេរសាច់ប្រាក់ជាក់ស្តែងអាចខុសពីការសន្យា។ គេនៅរង់ចាំមើលថាតើដៃគូអភិវឌ្ឍន៍នានានឹងឆ្លើយតបបែបណា ទៅនឹងការស្នើសុំរបស់រដ្ឋាភិបាលឱ្យផ្តល់ជំនួយនៅក្នុងឆ្នាំសារពើភ័ណ្ឌ ២០១០ ខាងមុខនេះ។ ការថយចុះ នៃ ODA ដែលរួមចំណែកប្រមាណ ៤០% នៃថវិកាជាតិ អាចមានផលវិបាកធ្ងន់ធ្ងរមកលើការអភិវឌ្ឍប្រទេសនេះ ជាពិសេស នៅក្នុងវិស័យសង្គម (សុខភាព និងការអប់រំ) វិស័យសេដ្ឋកិច្ច (កសិកម្ម និងអភិវឌ្ឍន៍ជនបទ) និងហេដ្ឋារចនាសម្ព័ន្ធ (ការដឹកជញ្ជូន)។

លំហូរ ODA មក កម្ពុជាបានរងគ្រោះដោយសារការធ្លាក់ថ្លៃរូបិយប័ណ្ណនៅក្នុងប្រទេសមួយចំនួន ដូចជា ចក្រភពអង់គ្លេស ប្រទេសជាសមាជិកនៃសហភាពអឺរ៉ុប កាណាដា អូស្ត្រាលី និងកូរ៉េខាងត្បូង ការធ្លាក់ចុះនៃតម្លៃរូបិយប័ណ្ណក្នុងប្រទេសជាម្ចាស់ជំនួយ ចាប់តាំងពីចុងឆ្នាំ២០០៨ មក មានន័យថា កម្ពុជាបានទទួលតិចជាងមុន បើគិតជាដុល្លារ ដែលជាមធ្យោបាយចំបងសម្រាប់ការទូទាត់ និងជាឯកត្តាប្រើប្រាស់នៅក្នុងប្រព័ន្ធគណនេយ្យនៅក្នុងប្រទេសកម្ពុជា។ វិសាលភាពនៃការធ្លាក់ថ្លៃមានប្រមាណ ២០-៣០% ចាប់តាំងពីខែតុលា ឆ្នាំ២០០៨ មក បើទោះជាតម្លៃដុល្លារធៀបនឹងរូបិយប័ណ្ណចំបងៗមួយចំនួនបានកើនឡើងបន្តិចម្តងៗមកវិញ ចាប់តាំងពីខែមីនា ឆ្នាំ២០០៩ មកក៏ដោយ។ នេះជាប្រការសំខាន់ណាស់ សម្រាប់គម្រោងអភិវឌ្ឍន៍នានា ដែលមានន័យថា ការផ្តល់មូលនិធិមាន ២០-៣០% តិចជាងការសន្យា បើគិតជាដុល្លារ។[១៩]

រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំឱ្យដៃគូអភិវឌ្ឍន៍នានា បង្កើនល្បឿននៃការបើកផ្តល់ប្រាក់ ODA ដែលជាវិធីមួយ ដើម្បីបន្ថែមចំណូលសម្រាប់ឆ្លើយតបទៅនឹងការធ្លាក់ចុះនៃការវិនិយោគនៅក្នុងវិស័យឯកជន ការធ្លាក់ចុះផលចំណូល និងការខាតបង់ចំណូលប្រចាំគ្រួសារនៅក្នុងអំឡុងពេលមានវិបត្តិ។[២០] ប្រសិនបើការអនុវត្តគម្រោង ODA អាចបង្កើនល្បឿនទៅបាន វាអាចរួមចំណែកទៅក្នុងការពង្រីកសកម្មភាពសេដ្ឋកិច្ច និងជួយកាត់បន្ថយផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ច។ លើសពីនេះ ជាទូទៅ អាជីវកម្មនានានឹងទទួលផលពីកំណែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទ្រទ្រង់ ដែលបង្កើតឡើងដោយគម្រោង ODA។ ទោះជាយ៉ាងណាក៏ដោយ គេមានកង្វល់អំពីសមត្ថភាពស្រូបយកជំនួយនេះ។ បុគ្គល និងស្ថាប័ននានា ត្រូវតែមានសមត្ថភាព ដើម្បីអាចអនុវត្តគម្រោង ODA ស្របតាមលក្ខខណ្ឌលទ្ធកម្ម និងនីតិវិធីសមស្របរបស់ពួកគេ។ បើពុំនោះទេ ប្រទេសនេះអាចប្រឈមនឹងហានិភ័យលើការធានាតម្លាភាពសាច់ប្រាក់កាន់តែខ្លាំងឡើង។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តគម្រោង ODA អាចនៅតែកើនឡើងនៅក្នុងវិស័យ ដែលគេបានគ្រប់គ្រងប្រាក់ជំនួយប្រកបដោយប្រសិទ្ធភាពរួចមកហើយ និងដែលមានប្រយោជន៍សម្រាប់អ្នកក្រ ដូចដែលមានពិភាក្សានៅក្នុងផ្នែក ៥ ខាងក្រោម។

## ២.៤ ការវិនិយោគដោយផ្ទាល់ពីបរទេស

កម្ពុជាបានរងគ្រោះ ដោយសារឥទ្ធិពលដោយផ្ទាល់មកលើវិស័យហិរញ្ញវត្ថុ និងធនាគារ ដែលរង្គោះរង្គើនៅក្នុងប្រទេសជាច្រើន និងដោយសារកម្ពុជាមានការវិនិយោគទ្រង់ទ្រាយតូច កម្ចីពាណិជ្ជកម្មពីបរទេស និងបំណុលពាណិជ្ជកម្មក្នុងបរិមាណតិច។ ទីផ្សារភាគហ៊ុនក្នុងប្រទេសកម្ពុជា នៅពុំទាន់បានបើកទ្វារនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ វិបត្តិហិរញ្ញវត្ថុពិភពលោកមានឥទ្ធិពលដោយប្រយោលមកលើកម្ពុជាតាមរយៈ FDI។ វិនិយោគិន និងអ្នកដែលអាចមកធ្វើវិនិយោគ បានមើលឃើញថា ទ្រព្យសកម្មរបស់ខ្លួនបានថយចុះយ៉ាងច្រើនដោយសារតែវិបត្តិខាងឥណទាន ការដួលរលំនៃទីផ្សារភាគហ៊ុន និងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ។ ការធ្លាក់ចុះនៃ FDI និងការរឹតបន្តឹងលើហិរញ្ញប្បទានសម្រាប់ពាណិជ្ជកម្មនៅលើពិភពលោក ក៏មានឥទ្ធិពលមកលើកម្ពុជាយ៉ាងច្រើនផងដែរ។

---

[១៩] ការអនុវត្តគម្រោងនៅក្នុងប្រទេសកម្ពុជា ក៏ភាគច្រើនប្រើប្រាស់ប្រាក់ដុល្លារផងដែរ។

[២០] សម្តេច ហ៊ុន សែន បានលើកឡើងនៅក្នុង "សុន្ទរកថាគន្លឹះ" ក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទីបី នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ក្រុងភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០០៩។

យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) FDI ដែលបានប្រើប្រាស់បានកើនឡើងពី ១៣៩ លានដុល្លារ នៅក្នុងឆ្នាំ២០០២ រហូតដល់ប្រមាណ ៨០០ លានដុល្លារ នៅក្នុងឆ្នាំ២០០៨ ដែលបង្ហាញពីកំណើនយ៉ាងច្រើននូវឆន្ទៈមកវិនិយោគនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ នៅឆ្នាំ២០០៨ មានការអនុម័តឯកភាព និងចេញអាជ្ញាប័ណ្ណសម្រាប់ទឹកប្រាក់ជិត ១១ ពាន់លានដុល្លារ។ ជាទូទៅ ការប្រើប្រាស់ FDI ជាក់ស្តែង មានកម្រិតទាបជាងជាខ្លាំងធៀបនឹងបរិមាណដែលបានអនុម័ត ដោយសារតែភាពខុសគ្នានៃពេលវេលា។ ជាក់ស្តែង FDI ដែលបានប្រើប្រាស់មានតិចជាង ៨% នៃបរិមាណដែលបានអនុម័តនៅក្នុងឆ្នាំ២០០៨។ ដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក FDI ជាក់ស្តែងនៅឆ្នាំ២០០៩ ការព្យាករណ៍ដោយធនាគារពិភពលោកថា មានត្រឹមតែ ៣៩០ លានដុល្លារប៉ុណ្ណោះ។

*តារាងទី ៣. FDI ដែលបានអនុម័តអចលនទ្រព្យ (គិតជាលានដុល្លារ)*

| | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ (S1*) |
|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | ៦ | ៣៩ | ៤ | ១២ | ២៧ | ៤៩៨ | ១៣៦ | ៩២ | ៣២៤ |
| ឧស្សាហកម្ម | ១០០ | ៥៧ | ១៤៣ | ១៧១ | ៩១៣ | ៣៦៥ | ៧០៩ | ៧២៥ | ៣០៤ |
| សេវាកម្ម | ១១១ | ១៤៣ | ១៦៨ | ៩២ | ១៥៥ | ២.៩៣៩ | ១.៧៤៣ | ១០.០០៣ | ៥៩៦ |
| **សរុប** | ២១៧ | ២៤០ | ៣១៤ | ២៧៥ | ១.០៩៥ | ៣.៨០២ | ២.៥៨៧ | ១០.៨២០ | ១.២២៣ |

*ប្រភព: CDC*
**S1= Q1 និង Q2*

នៅក្នុងឆមាសទីមួយ ឆ្នាំ២០០៩ ទឹកប្រាក់ FDI ដែលបានអនុម័ត បានថយចុះមកត្រឹមតែ ១១% នៃបរិមាណសរុបដែលបានអនុម័តនៅក្នុងឆមាសទីមួយ ឆ្នាំ២០០៨ (សូមមើលតារាងទី ៣)។ ទោះជាយ៉ាងណាក៏ដោយ គេមិនឃើញមានការផ្លាស់ប្តូរច្រើនឡើយ ធៀបនឹងឆ្នាំមុនៗ ដោយបរិមាណដែលមានអនុម័តមានប្រមាណ ៥០% នៃ FDI សរុប ដែលបានអនុម័តសរុបសម្រាប់ឆ្នាំ២០០៧។ ក្រៅពីនេះ គេឃើញមានកំណើនជាច្រើននៃ FDI ដែលមានអាជ្ញាប័ណ្ណ ដើម្បីវិនិយោគនៅក្នុងវិស័យកសិកម្ម ចំណែកការផ្តល់អាជ្ញាប័ណ្ណសម្រាប់វិស័យឧស្សាហកម្ម និងសេវាកម្ម បានធ្លាក់ចុះយ៉ាងច្រើននៅក្នុងឆមាសទីមួយ ឆ្នាំ២០០៩។ តួលេខនេះស្របគ្នាជាមួយការអះអាងដែលថា កម្ពុជាមានសក្តានុពលយ៉ាងច្រើនក្នុងការអភិវឌ្ឍកសិកម្ម ដើម្បីទប់ទល់នឹងការធ្លាក់ចុះនៃឧស្សាហកម្មកាត់ដេរ និងទេសចរណ៍។ ប៉ុន្តែ គេគួរតែកត់សំគាល់ថា FDI ដែលបានអនុម័ត គឺជាតួលេខ ដែលគ្រាន់តែបង្ហាញពីឆន្ទៈលើការវិនិយោគតែប៉ុណ្ណោះ។ ពេលវេលាដែលចាំបាច់សម្រាប់ឈានពីដំណាក់កាលលើកសំណើ រហូតដល់ការអនុវត្តជាក់ស្តែង អាចជារយៈពេលយូរ។ វាទាមទារពេលវេលាជាច្រើនឆ្នាំ ដើម្បីឱ្យគម្រោងនានាដែលមានទឹកប្រាក់រហូតដល់ជាច្រើនលានដុល្លារ អាចអនុវត្តបានចប់សព្វគ្រប់ ប្រសិនបើវិនិយោគិនមិនបោះបង់ចោលគម្រោងនោះទេ។

វិបត្តិខាងឥណទាននៅក្នុងទីផ្សារអន្តរជាតិ និងការបាត់បង់ទ្រព្យសកម្ម និងដើមទុន ក្នុងចំណោមវិនិយោគិនដែលមានធនធានច្រើន និងក្រុមហ៊ុននានានៅជុំវិញពិភពលោក បានធ្វើឱ្យមានការថយចុះនូវដើមទុនសម្រាប់ការវិនិយោគនៅកម្ពុជា បើទោះជាក្រុមហ៊ុនទាំងនោះនៅតែចាត់ទុកកម្ពុជាថា ជាសេដ្ឋកិច្ចដែលទើបលេចឡើងដោយជោគជ័យក៏ដោយ។ គេឃើញមានបញ្ហានៃការដកខ្លួន ដើម្បីសុវត្ថិភាព ដោយសារតែកំណើនហានិភ័យ។

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សាធារណរដ្ឋកូរ៉េ និងចិន គឺជាវិនិយោគិនធំជាងគេនៅកម្ពុជា។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកបានប៉ះទង្គិចប្រទេសទាំងពីរនេះយ៉ាងធ្ងន់ធ្ងរ ហើយបន្ទាប់មក ប្រទេសកម្ពុជាក៏បានមើលឃើញថាមានការថយចុះ ឬការព្យួរយ៉ាងច្រើននូវគម្រោងវិនិយោគពីប្រទេសកូរ៉េ និងចិន ផងដែរ។ គម្រោងអចលនវត្ថុធំៗមួយចំនួនរបស់កូរ៉េ ត្រូវបានព្យួរទុក ដែលបានធ្វើឱ្យឧស្សាហកម្មសំណង់របស់កម្ពុជាដើរថយក្រោយ។ ក្រុមហ៊ុនម៉ៅការបានប្រាប់អ្នកសម្ភាសនៅក្នុងខែឧសភា ឆ្នាំ២០០៩ ថា តម្រូវការទិញផ្ទះមានត្រឹមតែ ៣០% នៃកម្រិតតម្រូវការកាលពីឆ្នាំទៅតែប៉ុណ្ណោះ។ គេឃើញមានក្រុមហ៊ុនម៉ៅការខ្លះបន្ថយល្បឿនគម្រោងសាងសង់ ប៉ុន្តែវាមិនមែនកើតឡើងសម្រាប់គម្រោងទាំងអស់ ដែលមិនទាន់សាងសង់ហើយនោះទេ។

## ២.៥ កំណែតម្រូវលើអត្រាប្តូរប្រាក់

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងពេលដែលប្រទេសកម្ពុជាពុំមានស្ថិរភាពខាងនយោបាយ និងសេដ្ឋកិច្ច អត្រាប្តូរប្រាក់ រវាងប្រាក់រៀល និងដុល្លារអាមេរិក បានប្រែប្រួលជាខ្លាំង។ ក្រោយពីនោះមក តម្លៃប្រាក់រៀលចាប់ផ្តើមមានស្ថិរភាពជាបណ្តើរៗ ហើយនៅក្នុងទសវត្សរ៍កន្លងមកនេះ បានប្រែប្រួលបន្តិចបន្តួច រវាង ៣.៩០០-៤.២០០ រៀល ក្នុងមួយដុល្លារ។ ប្រាក់រៀលមានធ្លាក់ចុះបន្តិចបន្តួចដល់ខ្ពស់ជាង ៤.២០០ រៀល ក្នុងមួយដុល្លារ នៅក្នុងខែកក្កដា ឆ្នាំ២០០៩។

ការប្រើប្រាស់យ៉ាងទូលំទូលាយនូវប្រាក់ដុល្លារក្នុងប្រទេសកម្ពុជា បានធ្វើឱ្យការនាំចេញរបស់ប្រទេសនេះត្រូវចំណាយខ្ពស់ និងពុំមានសមត្ថភាពប្រកួតប្រជែងនៅពេលដែលប្រាក់ដុល្លារកើនតម្លៃ និងមានសមត្ថភាពប្រកួតប្រជែង នៅពេលដែលប្រាក់ដុល្លារចុះថោក។ ការចរចាអំពី "ការឈប់ប្រើប្រាក់ដុល្លារ" អាចនឹងមានឥទ្ធិពលខ្លាំងជាងមុនដោយសារតែផលវិបាកដោយផ្ទាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក។ ក្នុងខណៈដែលការរក្សាតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារឱ្យស្ថិតក្នុងរង្វង់តម្លៃណា គឺជារឿងមួយដ៏ល្អសម្រាប់ពង្រឹងទំនុកចិត្តក្នុងចំណោមសាធារណជនលើប្រាក់រៀល វាក៏អាចធ្វើឱ្យប្រាក់រៀលមានតម្លៃខ្ពស់ខ្លាំងពេកធៀបនឹងរូបិយប័ណ្ណដទៃទៀត នៅពេលដែលប្រាក់ដុល្លារមានតម្លៃខ្ពស់ ធៀបនឹងរូបិយប័ណ្ណទាំងនោះ ដែលជាករណីកើតឡើងនៅក្នុងរយៈពេលប៉ុន្មានខែមុននេះ។ សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាលើការនាំចេញ ទំនងជាត្រូវចុះខ្សោយ ដោយសារតែកំណើនថ្លៃនៃប្រាក់ដុល្លារធៀបនឹងរូបិយប័ណ្ណមួយចំនួន។

អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងដុល្លារ មានស្ថិរភាពជាបន្តរក្នុងរយៈពេល ១០ ឆ្នាំ នៅក្រោមរបបគ្រប់គ្រងតាមអត្រាអណ្តែត។ ក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ តម្លៃប្រាក់រៀលបានធ្លាក់ចុះមួយកម្រិតធៀបនឹងតម្លៃប្រាក់ដុល្លារ។ ភាគច្រើន ប្រការនេះកើតឡើងដោយសារការថយចុះនៃការចរាចរប្រាក់ដុល្លារដែលជាលទ្ធផលនៃការថយចុះយ៉ាងច្រើននូវប្រាក់ចំណូលជាដុល្លារតាមរយៈវិស័យទេសចរណ៍ ការនាំចេញសម្លៀកបំពាក់ និងចំណូលពី FDI។ រដ្ឋាភិបាលបានសំដែងការព្រួយបារម្ភអំពីការធ្លាក់ថ្លៃនៃតម្លៃប្រាក់រៀល នៅពេលដែលរដ្ឋាភិបាលបន្ថែមការចំណាយលើវិស័យសាធារណៈ ដែលត្រូវគណនាជាប្រាក់រៀលទាំងអស់។ ការធ្លាក់ចុះនៃតម្លៃរូបិយប័ណ្ណក្នុងស្រុក ទំនងជាបណ្តាលឱ្យមានអតិផរណាថ្លៃទំនិញធៀបនឹងប្រាក់រៀល ដែលកំពុងមានប្រើប្រាស់ទូលំទូលាយដោយប្រជាពលរដ្ឋនៅជនបទ ដោយសារតែបរិមាណយ៉ាងច្រើននៃផលិតផលសម្រាប់ប្រើប្រាស់ និងផលិតផលសម្រាប់ការផលិត ត្រូវបាននាំចូលពីបរទេស និងមានតម្លៃខ្ពស់ បើគិតជាប្រាក់រៀល។ ប្រការនេះ នាំឱ្យមានការថយចុះនូវអំណាចទិញរបស់ប្រជាពលរដ្ឋនៅជនបទ ដែលមានចំណូលជាប្រាក់រៀល។ ប៉ុន្តែស្ថានភាពនេះ អាចបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ផលិតផលកម្ពុជា ជាពិសេស ផលិតផលកសិកម្ម ពីព្រោះផលិតផលទាំងនេះភាគច្រើន ត្រូវបានជួញដូរជាប្រាក់រៀល។

*តារាងទី ៤. និន្នាការនៃអត្រាប្តូរប្រាក់ (រៀលធៀបនឹង ដុល្លារ ប្រាក់បាត និងប្រាក់ដុង)*

| | សីហា-០៨ | តុលា-០៨ | វិច្ឆិកា-០៨ | ធ្នូ-០៨ | មករា-០៩ | កុម្ភៈ-០៩ | មីនា-០៩ | មេសា-០៩ | ឧសភា-០៩ | មិថុនា-០៩ |
|---|---|---|---|---|---|---|---|---|---|---|
| រៀលក្នុងមួយដុល្លារ | ៤.១១៩ | ៤.១១៨ | ៤.០៩៣ | ៤.០៥៨ | ៤.១០៥ | ៤.១១៨ | ៤.១១២ | ៤.១០៤ | ៤.១៣២ | ៤.១៥១ |
| រៀលក្នុងមួយបាត | ១២០ | ១២០ | ១១៧ | ១១៦ | ១១៨ | ១១៦ | ១១៥ | ១១៦ | ១២០ | ១២២ |
| រៀលក្នុង ១០០ ដុង | ២៥ | ២៥ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | ២៣ | ២៣ | ២៣ |

*ប្រភព: NBC*

## ២.៦ ប្រាក់កំចី និងការជាប់បំណុល

វិស័យហិរញ្ញវត្ថុរបស់កម្ពុជាមានសេរីភាពខ្លាំងណាស់ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសមានភាគហ៊ុនដល់ ១00%។ គេពុំមានការកំហិតលើការផ្ទេរផលចំណេញទៅប្រទេសដើមវិញឡើយ ។ទោះជាយ៉ាងណាក៏ដោយ វិស័យធនាគារ និងវិស័យហិរញ្ញវត្ថុរបស់កម្ពុជានៅតែពុំសូវអភិវឌ្ឍន៍ ហើយជាលទ្ធផល វិស័យទាំងនេះបានរងគ្រោះពីផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ពីវិបត្តិហិរញ្ញវត្ថុពិភពលោក។ គ្មានធនាគារណាមួយក្នុងចំណោមធនាគារពាណិជ្ជកម្មទាំង ២៩ បានរាយការណ៍ថា កង្វះសាច់ប្រាក់ ឬក្ស័យធនឡើយ ។[២១] ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធធនាគារមិនទាន់ខូចខាតទាំងស្រុងដោយសារវិបត្តិនេះទេ។ មានសេចក្តីរាយការណ៍អំពីកំណើនយឺតជាងមុននៃការផ្តល់ប្រាក់កំចី និងការផ្ញើប្រាក់នៅក្នុងធនាគារពាណិជ្ជកម្មភាគច្រើន ។[២២] យោងតាមតំណាងជាន់ខ្ពស់មួយរូបនៃធនាគារពាណិជ្ជកម្ម ការផ្តល់ប្រាក់កំចី និងការផ្ញើប្រាក់នៅតែមានកំណើន ប៉ុន្តែតាមអត្រាទាបជាងមុន ។

នៅក្នុងដំណាក់កាលរីកចម្រើនខ្ពស់បំផុតនាឆ្នាំ២00៧ និងនៅឆមាសទីមួយ ឆ្នាំ២00៨ ឥណទានក្នុងវិស័យឯកជនបានកើនឡើងខ្ពស់ជាង ១00% ធៀបនឹងឆ្នាំមុន។ ប្រការនេះបានកើនឡើងដោយសារការរីកចម្រើននៃទីផ្សារអចលនទ្រព្យ និងទំនុកចិត្ត និងវត្តមាននៃប្រព័ន្ធធនាគារ។ មនុស្សជាច្រើនបានប្រើប្រាស់អចលនទ្រព្យ ឬដីធ្លី សម្រាប់ជាវត្ថុបញ្ចាំដើម្បីខ្ចីប្រាក់។ ដោយសារថ្លៃអចលនទ្រព្យ និងដីធ្លីបានកើនឡើងយ៉ាងខ្លាំង ប្រជាពលរដ្ឋអាចខ្ចីប្រាក់បានដោយងាយស្រួល។ ការផ្តល់ឥណទានដល់វិស័យឯកជន បានកើនឡើងពីរដងនៅក្នុងឆមាសទីមួយ ឆ្នាំ២00៨។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) ក៏បានផ្តល់ប្រាក់កំចីច្រើនជាងពេលណាៗទាំងអស់។ ជាលទ្ធផល នៃស្ថានភាពមិនល្អនៃសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចក្នុងប្រទេស លក្ខខណ្ឌនានានៃការសុំខ្ចីប្រាក់ ត្រូវបានរឹតបន្តឹងចាប់តាំងពីពេលនោះមក។[២៣] ក្រោយពីមានការរីកចម្រើនជាច្រើននៅក្នុងឆ្នាំមុននេះ ការផ្តល់ឥណទានបានចាប់ផ្តើមយឺតយ៉ាវមកវិញ នៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២00៨ ដោយសារផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកមកលើកម្ពុជា (សូមមើលរូបទី ៦)។ មានសញ្ញាមួយផ្សេងទៀតដែលថាប្រព័ន្ធធនាគារនៅក្នុងប្រទេសនេះ កំពុងរងការប៉ះទង្គិច ធនាគារជាតិនៃកម្ពុជាបានពោលថា របាយការណ៍ត្រួតពិនិត្យចុងក្រោយបង្អស់បានបង្ហាញថា ប្រាក់កំចីដែលមិនផ្តល់ការប្រាក់ (NPL) បានកើនឡើងពី ៥៨ លានដុល្លារ នៅក្នុងខែមិថុនា ឆ្នាំ២00៨ ដល់ជិត ៨៨ លានដុល្លារ រហូតដល់ចុងឆ្នាំនេះ។ តួលេខនេះត្រូវជា ៣,៦៨% នៃប្រាក់កំចីសរុបរបស់ធនាគារពាណិជ្ជកម្មទាំងអស់ ដែលមានជិត ២,៤ ពាន់លានដុល្លារ រហូតដល់ចុងឆ្នាំ២00៨។ នៅក្នុងឆមាសទីមួយ ឆ្នាំ២00៩ ស្ថាប័ន MFIs បានរាយការណ៍អំពីកំណើន NPLs និងចំនួនអ្នកខ្ចីប្រាក់ ដែលបានស្នើសុំពន្យារពេលសងប្រាក់។ នេះជាសញ្ញាមួយនៃផលប៉ះពាល់អវិជ្ជមានមកលើវិស័យធនាគារ ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ច។

អត្រាខ្ពស់បំផុតនៃគ្រួសារដែលមានបំណុលមិនទាន់សង គឺជាលទ្ធផលមួយនៃការរកឃើញ ដែលគួរឱ្យភ្ញាក់ផ្អើលនៅក្នុងការអង្កេតនាខែកក្កដា ដោយសមាគមសេដ្ឋកិច្ចកម្ពុជា ដោយជ្រើសសម្ភាស ១.0៧0 គ្រួសារ មកពីភូមិចំនួន ១៥ ដែលតំណាងឱ្យសំណុំលក្ខណៈខុសៗគ្នានៃគ្រួសារកសិករ។ នៅក្នុងសំណាកទាំងមូល គ្រួសារចំនួន ៧0% បានរាយការណ៍ថា ជាប់បំណុលមិនទាន់សង ដែលខ្លួនបានខ្ចីពីអ្នករកស៊ីចងការប្រាក់ ធនាគារអេស៊ីលីដា MFIs និងពីសាច់ញាតិ។ ការខ្ចីប្រាក់ភាគច្រើនបានធ្វើឡើងនៅក្នុងឆ្នាំ២00៩។ កង្វះលទ្ធភាពក្នុងការសងប្រាក់ គឺជាកង្វល់ចំបងមួយក្នុងចំណោមកង្វល់នានា ដែលត្រូវបានរាយការណ៍ដោយគ្រួសារទាំងនោះ។ ធៀបនឹងមួយឆ្នាំមុនដែលពេលនោះ មានតែ ៦0% នៃគ្រួសារនៅក្នុងសហគមន៍ដូចគ្នានេះ ដែលបានរាយការណ៍ថា ពួកគេមានបំណុលនៅពុំទាន់សង។ កំណើនចំនួនករណីជាប់បំណុល ជាសញ្ញាជាក់ស្តែងមួយនៃផលប៉ះពាល់អវិជ្ជមានពីការធ្លាក់ចុះនៃសេដ្ឋកិច្ច។[២៤]

---

[២១] ការបើកធនាគារថ្មីចំនួនពីរបន្ថែមនៅពេលថ្មីៗនេះ បាននាំឱ្យចំនួនធនាគារសរុបឡើងដល់ ២៩។

[២២] *Sovann, Nguon. "Bank deposits and loans drop". Phnom Penh Post, 27 April 2009: 15.*

[២៣] *Nelmes, John. "Global Crisis: Impact, Outlook and Policy Options for Cambodia." Cambodia Outlook Conference. Phnom Penh Hotel, Phnom Penh. 12 March 2009. Presentation.*

[២៤] The Impact of the Global Economic Downturn on Communities in Cambodia: Special Study Report of the Cambodian Economic Association. Phnom Penh: Cambodian Economic Association, 2009 (forthcoming).

*រូបទី ៦. ការលូតលាស់នៃឥណទានក្នុងប្រទេស និងក្នុងវិស័យឯកជន*




*ប្រភព: NBC*

សាច់ប្រាក់នៅក្នុងចរាចរ និងប្រាក់បញ្ញើក្នុងធនាគារ បានឈប់កើនឡើងនៅក្នុងខែឧសភា ឆ្នាំ២០០៨ ក្រោយពេល NBC បានដាក់ឱ្យអនុវត្តគោលនយោបាយ ដើម្បីបង្កើនអត្រាទុនបម្រុងពី ៨ ទៅ ១៦% ។ ប្រការនេះបានធ្វើឡើងនៅក្នុងការប៉ុនប៉ងមួយ ដើម្បីកាត់បន្ថយកំណើនអតិផរណា ដែលមួយផ្នែកបង្កដោយកត្តាខាងក្រៅនានា (កំណើនថ្លៃប្រេង ជី និងស្បៀង ដែលជាមូលហេតុចំបងធ្វើឱ្យមានកំណើនអតិផរណា)។ ការធ្លាក់ចុះបន្តិចបន្តួចនៃវត្តមានសាច់ប្រាក់សរុប បានបង្ហាញឱ្យឃើញច្បាស់នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ បន្ទាប់មកមានការធ្លាក់ចុះជាខ្លាំងរយៈពេលពីរខែក្រោយមក មុននឹងមាននិន្នាការថេរក្នុងខែធ្នូ។ NBC បានកាត់បន្ថយអត្រាទុនបម្រុងពី ១៦ មក ១២% វិញ ដើម្បីអាចផ្តល់លទ្ធភាពដល់ធនាគារក្នុងការផ្តល់ប្រាក់កំចី ជាពិសេស ឱ្យដល់វិស័យកសិកម្ម។ ម្ចាស់ធនាគារជាច្រើនបានលើកស្នើឱ្យបញ្ចុះលក្ខខណ្ឌទុនបម្រុងមកនៅត្រឹម ៨% វិញ។

## ប្រអប់ទី ១.   មេគុណនៃការចំណាយ

ការធ្លាក់ចុះនៃសេដ្ឋកិច្ចទំនងជាបានធ្វើឱ្យបាត់បង់ទំនុកចិត្តក្នុងចំណោមអ្នកប្រើប្រាស់ និងក្រុមហ៊ុននានា។ ពួកគេទំនងជាខិតខំសន្សំប្រាក់បន្ថែមទៀត បើទោះជាប្រាក់ចំណូលរបស់ខ្លួនធ្លាក់ចុះបន្តិចក្តី។ ប្រការនេះបាននាំឱ្យមានកំណើនមេគុណនៃការចំណាយដោយសារមានការប្តូរពីការចំណាយទៅជាការសន្សំ។ នៅក្នុងពេលសេដ្ឋកិច្ចរីកចម្រើនដល់កំពូល ប្រជាពលរដ្ឋបានចំណាយកាន់តែច្រើន។ ផ្ទុយមកវិញ នៅក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ វិនិយោគិន និងគ្រួសារនានាបានចំណាយតិច ដែលមានន័យថាមានទឹកប្រាក់កាន់តែតិច ដែលធ្វើចរាចរពីមនុស្សម្នាក់ទៅម្នាក់ទៀត ដែលនាំឱ្យបាត់បង់ការងារ ឬការថយចុះនៃប្រាក់ចំណូល។

សណ្ឋាគារមួយចំនួននៅក្រុងសៀមរាប បានបិទទ្វារ ហើយសណ្ឋាគារជាច្រើននៅដំណើរការដោយមានភ្ញៀវក្នុងចំនួនតិចបំផុត ដោយសារតែការធ្លាក់ចុះនៃសេដ្ឋកិច្ច និងការភ័យខ្លាចរោគផ្តាសាយ A(H1N1)។ ហាងម៉ាស្សាមួយ បានរាយការណ៍ថា ពួកគេលែងឃើញមានអតិថិជនកូរ៉េ ដែលធ្លាប់តែមកទទួលសេវាម៉ាស្សាជាទៀងទាត់ទៀតហើយ។ ម្ចាស់ហាងនេះបានបញ្ជាក់ថា គាត់ជឿថាជំនួញនានា មានដំណើរការយឺតយ៉ាវដោយសារតែវិបត្តិសេដ្ឋកិច្ច។ ហាងនេះរកចំណូលបានត្រឹមតែមួយភាគប្រាំនៃប្រាក់ចំណូលដែលគាត់ធ្លាប់រកបានកាលពីឆ្នាំមុន។

ម្ចាស់ភោជនីយដ្ឋានមួយបានរាយការណ៍ដោយឡែក អំពីការថយចុះផលចំណូលយ៉ាងច្រើន រហូតដល់ចំណុចមួយដែលកំពុងគំរាមកំហែងចំពោះដំណើរការអាជីវកម្មនៃភោជនីយដ្ឋាននេះ។ពួកគេលែងមានភ្ញៀវជាបុគ្គលិកការិយាល័យចំនួនច្រើនមកបរិភោគអាហារថ្ងៃត្រង់ជាទៀងទាត់ដូចមុនទៀតឡើយ។

ហាងលក់វត្ថុអនុស្សាវរីយ៍នានា មានអតិថិជនក្នុងចំនួនតិចតួច និងហាងខ្លះត្រូវបិទទ្វារ។ ស្ថានភាពដូចគ្នានេះ បានកើតឡើងចំពោះអ្នករត់រ៉ឺម៉ក និងម៉ូតូឌុប ដែលបានរាយការណ៍អំពីការចំណាយប្រាក់តិចជាងមុន ដោយសារសព្វថ្ងៃនេះ ពួកគេរកប្រាក់បានតិចជាងមុន។ ប្រការនេះមានឥទ្ធិពលមកលើអ្នកលក់ផ្លែឈើ និងម្ចាស់តូបលក់អាហារចល័ត ដែលភាគច្រើនជាអ្នកក្រ។ ពួកគេរាយការណ៍ថា ពួកគេលក់បានត្រឹមតែមួយភាគបួននៃបរិមាណដែលធ្លាប់លក់បានកាលពីមួយឆ្នាំមុន។ នៅក្នុងអំឡុងពេលលំបាក មេគុណនៃការចំណាយនៅក្នុងខេត្តសៀមរាប បានធ្លាក់ចុះទាបជាងមុន។

ការសម្ភាសផ្សេងទៀតជាមួយគ្រួសារនានា ដែលរងគ្រោះដោយសារវិបត្តិនេះ បានរកឃើញថា ពួកគេភាគច្រើនបានកាត់បន្ថយការចំណាយ ជាពិសេស លើវត្ថុដែលមិនចាំបាច់ ដូចជាការបរិភោគនៅក្រៅផ្ទះ។ ភោជនីយដ្ឋាន និងអ្នកលក់អាហារផ្សេងៗទៀត បានរាយការណ៍ថា ពួកគេរកប្រាក់ចំណូលបានតិចជាង ៥០% នៃចំនួនដែលពួកគេធ្លាប់រកបានកាលពីមួយឆ្នាំមុន។ អ្នកលក់អាហារឆៅ ក៏បានរាយការណ៍ផងដែរថា ពួកគេរកបានតែ ៥០% នៃប្រាក់ចំណូលដែលពួកគេរកបានកាលពីឆ្នាំមុន។

*ប្រភព: ការសម្ភាសដោយ UNDP ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៩*

## ២.៧   ជញ្ជីងទូទាត់

ជញ្ជីងទូទាត់ គឺជាឧបករណ៍ល្អបំផុតមួយសម្រាប់បញ្ជាក់អំពីលំហូរចូល និងលំហូរចេញនៃដើមទុននៅក្នុងសេដ្ឋកិច្ចមួយ។ ការប៉ាន់ប្រមាណចុងក្រោយអំពីជញ្ជីងទូទាត់ ទាមទារនូវពេលវេលាជាច្រើន ដោយសារវាពាក់ព័ន្ធជាមួយទិន្នន័យ អំពីពាណិជ្ជកម្មចុងក្រោយ ការវិនិយោគ និងដើមទុន និងការផ្ទេរប្រាក់ចំណូល។ ការពិនិត្យមើលអំពីការអភិវឌ្ឍថ្មីៗនៃជញ្ជីងទូទាត់ បានពឹងផ្អែកលើការព្យាករណ៍ដែលផ្អែកលើទិន្នន័យបឋម។ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) បានចេញផ្សាយការព្យាករណ៍របស់ខ្លួនសម្រាប់ ឆ្នាំ២០០៧, ២០០៨ និង ២០០៩។ ដូចមានបង្ហាញជូននៅក្នុងតារាងទី ៥ ការព្យាករណ៍ទាំងនេះបង្ហាញថា តុល្យភាពរួមបានផ្លាស់ប្តូរពីស្ថានភាពវិជ្ជមាននៅក្នុងរយៈពេលពីរឆ្នាំមុន មកអវិជ្ជមាននៅក្នុងឆ្នាំ២០០៨ និង ២០០៩ នៅពេលដែលវិបត្តិសេដ្ឋកិច្ចពិភពលោក បានប៉ះទង្គិចមកលើប្រទេសកម្ពុជា។ ឱនភាពពាណិជ្ជកម្ម បានឈានដល់ដំណាក់កាលធ្ងន់ធ្ងរនៅក្នុងឆ្នាំ២០០៨ ក្នុងពេលដែលការនាំចូលទំនិញបានកើនឡើង ១.០០០ លានដុល្លារ។ ការនាំចេញបានកើនឡើងត្រឹមតែ ៣០០ លានដុល្លារ ដែលបានបង្កើតឱ្យមានឱនភាពគណនីចរន្ត[២៥] ចំនួន ៧៤៨ លានដុល្លារ។

---

[២៥] "សេចក្តីថ្លែងការណ៍មួយអំពីពាណិជ្ជកម្មលើទំនិញ និងសេវាកម្មរបស់ប្រទេសមួយ ជាមួយប្រទេសដទៃទៀតនៅក្នុងពិភពលោក នៅក្នុងរយៈពេលមួយជាក់លាក់។
" (Pass, Christopher, Bryan Lowes, Leslie Davis, Sidney J. Kronish. The Harper Collins Dictionary of Economics. New York: Harper Perennial, 1991. 110).

ជញ្ជីងទូទាត់រួមនៅក្នុងឆ្នាំ២០០៩ ត្រូវបានព្យាករណ៍ថាមានឱនភាព ១១៨ លានដុល្លារ ដែលជាការធ្លាក់ចុះពី ៧៥ លានដុល្លារ នៅក្នុងឆ្នាំ២០០៨។ មូលធនបម្រុងរបស់ជាតិ ដែលបានពីអតិរេកនៃតុល្យភាពជារួមមកទល់ពេលនេះ មានក្នុងរង្វង់ ២.០០០ លានដុល្លារ អាស្រ័យហេតុនេះ វាស្ថិតនៅក្នុងស្ថានភាពល្អបង្គួរ ។តួលេខនេះស្មើនឹងប្រមាណបីខែនៃតម្លៃការនាំចូលដែលមិនមែនជាចំនួនដ៏ច្រើនឡើយ ។ ក្នុងចំណោមមូលធនបម្រុងសរុប សាច់ប្រាក់ប្រមាណ ១.៥០០ លានដុល្លារ គឺជារបស់រដ្ឋ ដែលផ្នែកខ្លះស្ថិតក្រោមរូបភាពជាការវិនិយោគក្រៅប្រទេស ចំណែកទឹកប្រាក់ប្រមាណ ៥០០ លានដុល្លារទៀត ស្ថិតក្រោមទម្រង់ជាប្រាក់បញ្ញើនៅក្នុងធនាគារវិស័យឯកជន ។[២៦] យោងតាមការព្យាករណ៍ដូចនៅក្នុងតារាងទី ៥ ឱនភាពពាណិជ្ជកម្មនឹងធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩ ធៀបនឹងរយៈពេលពីរឆ្នាំមុន ដោយសារការនាំចូលត្រូវបានប៉ាន់ប្រមាណថាធ្លាក់ចុះគំហុក ចំណែកការនាំចេញ ត្រូវបានព្យាករណ៍ថានៅថេរ ។ មូលធនបម្រុងនៅក្រៅស្រុកនឹងរួមតូចអស់ច្រើនជាង ១០០ លានដុល្លារ នៅក្នុងឆ្នាំ២០០៩ ដែលមិនមែនជាការអភិវឌ្ឍដែលផ្តល់អំណោយផលនោះឡើយ ។ លទ្ធផលជាក់ស្តែងអាចកាន់តែអាក្រក់ជាងនេះ ដោយសារនិន្នាការអវិជ្ជមាននៃការនាំចេញសម្លៀកបំពាក់ និងផលចំណូលពីវិស័យទេសចរណ៍នៅក្នុងឆ្នាំ២០០៩ ។

*តារាងទី ៥. ជញ្ជីងទូទាត់ (គិតជាលានដុល្លារ)*

| បរិយាយ | ឆ្នាំ ២០០៦ | ការព្យាករណ៍ ឆ្នាំ២០០៨ | ការព្យាករណ៍ ឆ្នាំ២០០៨ | ការព្យាករណ៍ ឆ្នាំ២០០៩ |
|---|---|---|---|---|
| ការនាំចេញទំនិញ | ៣.៦៩៣ | ៤.០៨៨ | ៤.៧០៨ | ៤.៧៣៧ |
| ការនាំចូលទំនិញ | ៤.៧២៧ | ៥.៤១៩ | ៦.៤៥៦ | ៥.៩៦៩ |
| ជញ្ជីងពាណិជ្ជកម្ម | -១.០៣៤ | -១.៣៣១ | -១.៧៤៨ | -១.២៣២ |
| កសិកម្ម | ៤០១ | ៥៧៨ | ៨៥១ | ៩៨៩ |
| វាយនភណ្ឌ និងសម្លៀកបំពាក់ | ១.៤៣០ | ១.៥៦៦ | ១.៦០២ | ១.៤៤៦ |
| ប្រេង និងឧស្ម័ន | -១.១២៣ | -១.៣០៦ | -១.៥៥៥ | -៨០៥ |
| ផលិតផលដទៃទៀត | -១.៧៤១ | -២.១៦៨ | -២.៦៤៦ | -២.៨៦២ |
| តុល្យភាពនៃ | ៥១៦ | ៦៤៣ | ៦១៧ | ៦៣៣ |
| ការដឹកជញ្ជូន | -២៧០ | -៣០០ | -៣៧៣ | -៤១១ |
| ការធ្វើដំណើរ (ទេសចរណ៍) | ៨៤១ | ១.០១២ | ១.១១៣ | ១.១៦៧ |
| ផ្សេងទៀត | -៥៦ | -៦៩ | -១២៤ | -១២២ |
| តុល្យភាពនៃចំណូល | -៣១៩ | -៣៨៥ | -៤៦៨ | -៥២៦ |
| តុល្យភាពនៃការផ្ទេរ និងគណនីមូលធនចរន្ត | ៧៩០ | ៨៥៥ | ៨៥១ | ៨៦៣ |
| ផលចំណូលផ្ទេរពីវិស័យឯកជន | ៣១៥ | ៣៧៧ | ៣៦៥ | ៣៦៧ |
| ផលចំណូលផ្ទេរពីរដ្ឋាភិបាល | ៤៧៥ | ៤៧៨ | ៤៨៦ | ៤៩៦ |
| គណនីចរន្ត | -៤៧ | -២១៨ | -៧៤៨ | -២៦២ |
| គណនីហិរញ្ញវត្ថុ | ២៨២ | ៦៦១ | ៦៧៣ | ១៤៤ |
| ប្រាក់កម្ចីផ្លូវការ | ១១៨ | ១៨៤ | ២២០ | ១៨៤ |
| ការវិនិយោគដោយផ្ទាល់ពីបរទេស | ៤៧៥ | ៨៦៦ | ៨០៦ | ៣៦២ |
| ផ្សេងទៀត (សុទ្ធ) | -៣១១ | -៥១ | -៥២ | -៥២ |
| តុល្យភាពសរុប | ២៣៥ | ៤៤៤ | -៧៥ | -១១៨ |

*ប្រភព: ការព្យាករណ៍តាមម៉ូដែលរបស់ NBC និង EIC (យោងតាម Economics Today, Special Issue July 2009, Volume ២, Number 42: 57)*

[២៦] ការសម្ភាសជាមួយ ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC), ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០០៩



# III ផលប៉ះពាល់ តាមវិស័យ



ផ្នែកនេះ គូសបញ្ជាក់ពីច្រកដែលការធ្លាក់ចុះនៃសេដ្ឋកិច្ច មានផលប៉ះពាល់ដោយផ្ទាល់មកលើវិស័យសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជា។ ផ្នែកនេះ ពិនិត្យមើលការនាំចេញសម្លៀកបំពាក់ ផលចំណូលពីវិស័យទេសចរណ៍ អចលនទ្រព្យ ការសាងសង់ និងកសិកម្ម។ ការពិភាក្សាអំពីផលប៉ះពាល់មកលើប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនៅក្នុងវិស័យទាំងនេះ នឹងធ្វើឡើងនៅក្នុងផ្នែកទី ៤។

## ៣.១ ការនាំចេញសម្លៀកបំពាក់

ការនាំចេញរបស់កម្ពុជា ភាគច្រើនបំផុតបានមកពីការនាំចេញសម្លៀកបំពាក់ ដែលមានរហូតដល់ ៧៥% នៃការនាំចេញសរុប នៅក្នុងឆ្នាំ២០០២ និង ៦៥% នៅក្នុងឆ្នាំ២០០៨។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកបាននាំឱ្យមានការថយចុះជាគំហុកនូវតម្រូវការទំនិញ និងសេវាជាទូទៅ។ យោងតាមទិន្នន័យពីក្រសួងពាណិជ្ជកម្ម ការនាំចេញសម្លៀកបំពាក់នៅក្នុងរយៈពេលបួនខែដំបូងនៃឆ្នាំ២០០៩ បានធ្លាក់ចុះ ២៧% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំទៅ។[២៧] យោងតាមតំណាងមួយរូបពីសមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) រោងចក្រមួយចំនួនតូចអាចនៅបន្តដំណើរការបាន ដោយសារទំនាក់ទំនងយ៉ាងរឹងមាំជាមួយអ្នកទិញនៅអឺរ៉ុប។ និន្នាការធ្លាក់ចុះនេះ ទំនងជាបន្តទៅក្នុងឆមាសទីពីរនៃឆ្នាំនេះទៀត ដោយរោងចក្រកាត់ដេរភាគច្រើនបានរាយការណ៍ អំពីប្រតិបត្តិការក្នុងកម្រិត ៦០-៧០% នៃសមត្ថភាពរបស់ខ្លួន និងបានកាត់បន្ថយចំនួនកិច្ចសន្យាម៉ៅការបន្តទៅឱ្យរោងចក្រតូចៗ។GMAC បានរាយការណ៍នៅក្នុងការសម្ភាសមួយជាមួយ UNDP ថា ការបញ្ជាទិញបានធ្លាក់ចុះជិត ៤០% ហើយប្រការដែលគួរឱ្យព្រួយបារម្ភជាងនេះ គឺមានការបញ្ជាទិញសម្រាប់តែរយៈពេលប៉ុន្មានខែខាងមុខតែប៉ុណ្ណោះ ដែលផ្ទុយពីរយៈច្រើនឆ្នាំមុន ដែលតាមធម្មតា ការបញ្ជាទិញបានធ្វើឡើងសម្រាប់រយៈពេលប្រាំមួយខែ។ ក្នុងពេលដែល ៩០% នៃផលិតផលសម្លៀកបំពាក់ ត្រូវបាននាំចេញទៅទីផ្សារ ស.រ.អា និងសហភាពអឺរ៉ុប ការស្តារឡើងវិញនៃសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងនេះ មានឥទ្ធិពលដោយផ្ទាល់មកលើការស្តារឡើងវិញនៃវិស័យកាត់ដេរនៅកម្ពុជា។ សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងកិច្ចការឧស្សាហកម្ម ពិតជាមានសារៈសំខាន់មែន។ ប្រទេសបង់ក្លាដែស និងវៀតណាម បាននាំចេញសម្លៀកបំពាក់កាន់តែច្រើនជាងកាលពីឆ្នាំមុន ចំណែកការនាំចេញរបស់កម្ពុជាបានធ្លាក់ចុះ ដែលជាការបង្ហាញអំពីតម្រូវការជាក់ស្តែងឱ្យកែលម្អសមត្ថភាពប្រកួតប្រជែងនៅក្នុងវិស័យនេះ។

ចំណូលសរុបពីការនាំចេញសម្លៀកបំពាក់របស់កម្ពុជា មាន ២,៩ ពាន់លានដុល្លារ នៅក្នុងឆ្នាំ២០០៨។ ធៀបនឹងការនាំចេញនៅឆ្នាំ២០០៧ ដែលមានចំនួន ២,៨ ពាន់លានដុល្លារ ការនាំចេញនៅតែកើនឡើង ប៉ុន្តែតាមអត្រាទាបជាងជាច្រើនបើប្រៀបធៀបនឹងរយៈពេល ១០ ឆ្នាំមុន ទោះជាត្រូវរងការប៉ះទង្គិចពីការថយចុះនៃតម្រូវការនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០០៨ ក៏ដោយ (សូមមើលរូបទី ៧)។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលភស្តុតាងបានបង្ហាញឱ្យឃើញ តាមរយៈតម្រូវការទាបជាងមុននៃការនាំចេញសម្លៀកបំពាក់នៅក្នុងរយៈពេលបួនខែដំបូងនៃឆ្នាំ២០០៩ ការថយចុះធ្ងន់ធ្ងរនៃការនាំចេញសម្លៀកបំពាក់ ត្រូវបានព្យាករណ៍សម្រាប់ឆ្នាំនេះ។ យោងតាមក្រសួងពាណិជ្ជកម្ម តួលេខសរុបនៃការនាំចេញសម្លៀកបំពាក់សម្រាប់រយៈពេលបួនខែដំបូងក្នុងឆ្នាំ២០០៩ មាន ៦៥៥ លានដុល្លារ។ ប្រសិនបើនិន្នាការនេះនៅតែបន្ត តួលេខសរុបសម្រាប់ឆ្នាំ២០០៩ ត្រូវបានប៉ាន់ប្រមាណថាមាន ២.០០០ លានដុល្លារ ឬការព្យាករណ៍ប្រកបដោយមោទនភាពជាងមុន អាចមាន ២.៥០០ លានដុល្លារ។ តួលេខនេះមានប្រមាណ ១៦% តិចជាងតួលេខ ដែលបានឃើញនៅក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ និងមិនមែន ៥% ដូចដែលបានព្យាករណ៍ដោយស្ថាប័នជាច្រើននោះឡើយ។ ការសិក្សានេះ បានព្យាករណ៍អំពីការថយចុះរវាង ១៥ និង ២០%។[២៨]

[២៧] តួលេខសម្រាប់ខែឧសភា និងមិថុនា នៅពុំទាន់បានបូកសរុបនៅឡើយទេ ប៉ុន្តែត្រូវបានរាយការណ៍ថា មិនបង្ហាញពីការកែលម្អឡើយ។

[២៨] Sophal, Chun. "Garment exports plummet 18 pc over first half of year". Phnom Penh Post, 17 August 2009: 13, បានរាយការណ៍ថា ទិន្នន័យចុងក្រោយពីក្រសួងពាណិជ្ជកម្ម បង្ហាញថាការនាំចេញសម្លៀកបំពាក់បានធ្លាក់ចុះ ១៥% រវាងឆមាសទីមួយ ឆ្នាំ២០០៩ និងឆមាសទីមួយ ឆ្នាំ២០០៨។ ប្រធានសមាគមរោងចក្រកាត់ដេរកម្ពុជា ត្រូវបានស្រង់សំដី ដែលពោលថា គាត់រំពឹងថា មានការធ្លាក់ចុះ ៤០% សម្រាប់រយៈពេលនៃឆ្នាំ២០០៩ ទាំងមូល ធៀបនឹងឆ្នាំ២០០៨។

*រូបទី ៧. ចំណូលពីការនាំចេញសម្លៀកបំពាក់ពីកម្ពុជា ឆ្នាំ២០០១-២០០៩ (គិតជាលានដុល្លារ)*




*សំគាល់ : ទិន្នន័យសម្រាប់ឆ្នាំ២០០៩ ត្រូវបានព្យាករណ៍ដោយផ្អែកលើតម្លៃនាំចេញ ៦៥៥ លានដុល្លារ នៅក្នុងរយៈពេលបួនខែដំបូង ឆ្នាំ២០០៩*
*ប្រភព : MoC*

តារាងទី ៦ ផ្តល់ការពន្យល់លំអិតអំពីការនាំចេញសម្លៀកបំពាក់ប្រចាំខែ សម្រាប់រយៈពេលបួនខែដូចគ្នានៅក្នុងរយៈពេលបីឆ្នាំចុងក្រោយ។ បើប្រៀបធៀបក្នុងខែដូចគ្នានៅឆ្នាំ២០០៧, ២០០៨ និង ២០០៩ តួលេខនេះបង្ហាញអំពីការធ្លាក់ចុះគំហុកនៃការនាំចេញសម្លៀកបំពាក់នៅក្នុង ខែមករា កុម្ភៈ មីនា និងមេសា ឆ្នាំ២០០៩។ ទិន្នន័យដំបូងសម្រាប់ខែឧសភា និងមិថុនា ឆ្នាំ២០០៩ មិនបានបង្ហាញពីកំណែលម្អឡើយ។ លើកលែងតែនិន្នាការនេះ នឹងប្តូរទិសនៅក្នុងឆមាសទីពីរនៃឆ្នាំ២០០៩ បើមិនដូច្នោះទេ ការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់ទំនងជានឹងកើនលើសពី ១៥% ធៀបនឹងឆ្នាំ២០០៨។ ប្រការនេះនឹងមានឥទ្ធិពលមកលើកំណើនសេដ្ឋកិច្ច ពីព្រោះវិស័យកាត់ដេរផ្តល់ ១៥% នៃ GDP ។

*តារាងទី ៦. ការនាំចេញសម្លៀកបំពាក់ប្រចាំខែ ក្នុងរយៈពេលបួនខែដំបូងពីឆ្នាំ២០០៧ ដល់ ២០០៩ (លានដុល្លារ)*

| | មករា | | | កុម្ភៈ | | | មីនា | | | មេសា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០០៧ | ២០០៨ | ២០០៩ | ២០០៧ | ២០០៨ | ២០០៩ | ២០០៧ | ២០០៨ | ២០០៩ | ២០០៧ | ២០០៨ | ២០០៩ |
| ស.រ.អា | ១៦៣,៧ | ១៦៦,០ | ១១៨,៨ | ១៦៣,១ | ១៧៣,៤ | ១២៧,៤ | ១៨០,២ | ១៩២,៦ | ១០២,៤ | ១២៦,៩ | ១១២,៤ | ៦៧,៨ |
| សហភាពអឺរ៉ុប | ៣៧,៩ | ៤១,៣ | ៣៨,៦ | ៣១,៩ | ៣៨,៤ | ៣៤,៩ | ២៨,១ | ៥០,៧ | ៣៥,៨ | ៣១,៧ | ២៩,២ | ៣៣,៤ |
| កាណាដា | ១០,៤ | ១៦,៦ | ១៣,១ | ១៦,៥ | ១៥,៥ | ១៧,៧ | ៨,២ | ១៦,៥ | ១២,៩ | ៦,២ | ៨,៥ | ៨,៣ |
| ផ្សេងទៀត | ៦,៨ | ៨,៥ | ១២,៥ | ៥,១ | ៩,២ | ១០,៣ | ៤,១ | ៨,១ | ១៣,៧ | ២,៧ | ៥,៩ | ៧,៥ |
| សរុប | ២១៨,៧ | ២៣២,៤ | ១៨៣,០ | ២១៦,៧ | ២៣៦,៥ | ១៩០,៤ | ២២០,៦ | ២៦៧,៩ | ១៦៤,៧ | ១៦៧,៥ | ១៥៦,០ | ១១៧,០ |
| ប្រែប្រួល | | ៦% | -២១% | | ៩% | -១៩% | | ២១% | -៣៩% | | -៧% | -២៥% |

*ប្រភព : MoC*

រូបទី ៨ បង្ហាញពីការពាក់ព័ន្ធជិតស្និទ្ធបំផុតរវាងការនាំចេញរបស់កម្ពុជា និងការលក់រាយនៅ ស.រ.អា។ ប្រការនេះបង្ហាញជារួមថា ការស្តារឡើងវិញនៃឧស្សាហកម្មកាត់ដេរនៅកម្ពុជាពឹងផ្អែកជាខ្លាំងលើការងើបឡើងវិញនៃសេដ្ឋកិច្ចនៅស.រ.អា។ទោះជាយ៉ាងណាក៏ដោយ នេះមិនសុទ្ធតែពិតនោះទេ។ ដូចដែលបង្ហាញនៅក្នុងតារាងទី ៧ ខាងក្រោម ប្រទេសមួយចំនួន ដែលជាគូប្រជែងជិតបំផុតជាមួយកម្ពុជា អនុវត្តបានល្អជាងមុននៅក្នុងអំឡុងពេលដូចគ្នានេះ សូម្បីតែការនាំចូលរបស់ ស.រ.អា នូវសម្លៀកបំពាក់បានថយចុះ ១២,០៤% ក៏ដោយ ។

*រូបទី ៨. ទំនាក់ទំនងរវាងការនាំចេញសម្លៀកបំពាក់របស់កម្ពុជា និងការលក់រាយនៅស.រ.អា*




*ប្រភព : Hang, Saing Chan. "Impacts of global economic crisis on garment workers and remittances in Cambodia". Public Forum on the Impact of the Global Economic Downturn and the Need for Policy Responses. Cambodia-Japan Cooperation Center. 14 July 2009. Presentation.*

ទិន្នន័យពីក្រសួងពាណិជ្ជកម្មរបស់ ស.រ.អា បង្ហាញថា ការនាំចេញសម្លៀកបំពាក់ពីកម្ពុជាទៅ ស.រ.អា បានធ្លាក់ចុះរហូតដល់ ២២% នៅក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ ធៀបនឹងរយៈពេលដូចគ្នានេះនៅក្នុងឆ្នាំ២០០៨។ តួលេខនេះស្របគ្នាភាគច្រើនជាមួយទិន្នន័យមកពីក្រសួងពាណិជ្ជកម្មរបស់កម្ពុជា។ នៅក្នុងរយៈពេលដូចគ្នានេះ ការនាំចូលរបស់ ស.រ.អា បានធ្លាក់ចុះអស់ ១២,០៤% ដែលមានន័យថា ប្រទេសកម្ពុជាបានប្រទះនឹងការធ្លាក់ចុះដ៏អាក្រក់មួយ លើការនាំចេញធៀបនឹងគូប្រជែងរបស់ខ្លួន។គូប្រជែងដោយផ្ទាល់របស់កម្ពុជា ដូចជា ប្រទេសចិន បានចាត់ចែងឱ្យមានកំណើនការនាំចេញរបស់គេទៅ ស.រ.អា បាន ៣,២៣% វៀតណាម ១,៤៧% និងបង់ក្លាដែស ៩,៥១%។ នេះជាការបង្ហាញអំពីការធ្លាក់ចុះនៃសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា និងបង្ហាញពីការចាំបាច់ឱ្យចាត់វិធានការជាបន្ទាន់ ដើម្បីស្តារវិស័យនេះឡើងវិញ។ អនុសាសន៍ខាងគោលនយោបាយមានផ្តល់ក្នុងផ្នែកទី ៥។

*តារាងទី ៧. ការនាំចូលសម្លៀកបំពាក់ដោយ ស.រ.អា ពីប្រទេសនានានៅឆ្នាំ២០០៧, ២០០៨ និងដើមឆ្នាំ២០០៩*

| ប្រទេស | តម្លៃ (លានដុល្លារ) | | % ប្រែប្រួល | តម្លៃ (លានដុល្លារ) | | % ប្រែប្រួល |
|---|---|---|---|---|---|---|
| | ២០០៧ | ២០០៨ | | មករា-ឧសភា ២០០៨ | មករា-ឧសភា ២០០៩ | |
| ពិភពលោក | ៧៣.៩២២ | ៧១.៥៦៩ | -៣,២៩% | ២៦.៩៩៤ | ២៣.៧៤៣ | -១២,០៤% |
| ចិន | ២២.៧៤៥ | ២២.៩២៣ | ០,៧៧% | ៧.២៥៩ | ៧.៤៩៤ | ៣,២៣% |
| អាស៊ាន | ១៥.២០៤ | ១៥.៥២០ | ២,០៣% | ៦.១៨៥ | ៥.៥៦១ | -១០,០៨% |
| វៀតណាម | ៤.៣៥៨ | ៥.២២៣ | ១៦,៥៥% | ១.៩០៥ | ១.៩៣៣ | ១,៤៧% |
| ឥណ្ឌូនេស៊ី | ៣.៩៨១ | ៤.០២៨ | ១,១៧% | ១.៦៧៧ | ១.៦៤៨ | -១,៧៣% |
| កម្ពុជា | ២.៤២៥ | ២.៣៧៦ | -២,០៦% | ៩៦៤ | ៧៥២ | -២២,០០% |
| ឥណ្ឌា | ៣.១៧០ | ៣.០៧៣ | -៣,១៤% | ១.៥០១ | ១.៣៧១ | -៨,៦៦% |
| បង់ក្លាដែស | ៣.១០៣ | ៣.៤៤២ | ៩,៨៣% | ១.៣៤៥ | ១.៤៧៣ | ៩,៥១% |
| ស្រីឡាំងកា | ១.៥៧៣ | ១.៤៦៧ | -៧,២៥% | ៦០៣ | ៥៤៦ | -៩,៤៥% |
| ប៉ាគីស្ថង់ | ១.៤៩៨ | ១.៤៨៩ | -០,៦០% | ៥៥៩ | ៤៨១ | -១៣,៩៥% |

*ប្រភព : ក្រសួងពាណិជ្ជកម្មអាមេរិក រដ្ឋបាលពាណិជ្ជកម្មអន្តរជាតិ ការិយាល័យវាយនភ័ណ្ឌ និងគ្រឿងតែងកាយ (http://otexa.ita.doc.gov/MSRCTRY.htm). Last updated 10 July 2009, accessed 20 July 2009.*

## ៣.២ ទេសចរណ៍

ទន្ទឹមនឹងវិស័យកាត់ដេរ វិស័យទេសចរណ៍បានដើរតួនាទីដ៏សំខាន់នៅក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចកម្ពុជា និងកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ។ ដោយប្រើប្រាស់និយមន័យចង្អៀតអំពីទេសចរណ៍ វិស័យទេសចរណ៍កម្ពុជារួមចំណែកប្រមាណ ១៣% នៃ GDP ដែលផ្តល់ផលចំណូល ១.៥៩៥ លានដុល្លារ នៅក្នុងឆ្នាំ២០០៨ (សូមមើលតារាងទី ៨) ។ ទោះជាយ៉ាងណាក៏ដោយ វិភាគទានពីវិស័យនេះអាចមានជិតដល់ ២០% នៅពេលដែលប្រើប្រាស់និយមន័យទូលាយជាងនេះ និងគិតបញ្ចូលសកម្មភាពដែលពាក់ព័ន្ធ ។[២៩] ការធ្លាក់ចុះនៃវិស័យនេះ មានឥទ្ធិពលយ៉ាងខ្លាំងមកលើខ្សែចង្វាក់សេដ្ឋកិច្ចទាំងមូល ទាំងមកលើសណ្ឋាគារផ្កាយប្រាំ រហូតដល់ភោជនីយដ្ឋាននៅក្នុងស្រុក និងអ្នកបើកបររថយន្តតាក់ស៊ីផងដែរ ។

វិស័យទេសចរណ៍នៅកម្ពុជា បានរីកចម្រើនយ៉ាងឆាប់រហ័ស ដោយសារវត្តមានយ៉ាងច្រើននៃប្រាសាទនានា ដូចជា ប្រាសាទអង្គរវត្តជាដើម ។ នេះក៏ជាលទ្ធផលរបស់កម្ពុជា ដែលបានចាប់ផ្តើមជាដំបូងដោយមានមូលដ្ឋានទេសចរណ៍ក្នុងអត្រាទាបផងដែរ ។ នៅឆ្នាំ១៩៩២ ប្រទេសនេះបានទទួលភ្ញៀវទេសចរត្រឹមតែ ២០.០០០ នាក់ប៉ុណ្ណោះ ។ មកដល់ឆ្នាំ២០០៧ ចំនួនភ្ញៀវទេសចរបរទេសបានកើនដល់កម្រិត ២ លាននាក់ (សូមមើលរូបទី ៩) ។ ទោះជាយ៉ាងណាក៏ដោយ តួលេខនេះ "តំណាងឱ្យត្រឹមតែប្រមាណ ៣ ភាគរយ នៃចំនួនសរុបនៃលំហូរភ្ញៀវទេសចរអន្តរជាតិនៅក្នុងប្រទេសអាស៊ានតែប៉ុណ្ណោះ" ។[៣០]

[២៩] ដែលរួមទាំង ការមកដល់កម្ពុជាក្នុងគោលបំណងពាណិជ្ជកម្ម និងគោលបំណងនានាផ្សេងទៀត ។

[៣០] Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction (Discussion Paper No. 7). Phnom Penh: UNDP, 2009, 43.

### *តារាងទី ៨. សារៈសំខាន់នៃវិស័យទេសចរណ៍នៅក្នុងសេដ្ឋកិច្ចកម្ពុជា*

| | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|
| ចំនួនភ្ញៀវមកដល់ (ពាន់នាក់) | ៧៨៧ | ៧០១ | ១.០៥៥ | ១.៤២២ | ១.៧០០ | ២.០១៥ | ២.១២៦ |
| ផលចំណូលពីទេសចរណ៍ (លានដុល្លារ)[៣១] | ៤៥៤ | ៣៨៩ | ៥៧៨ | ៨៣២ | ១.០៤៩ | ១.៤០០ | ១.៥៩៥ |
| គិតជាភាគរយនៃ GDP | ១០,៦ | ៨,៥ | ១១,៥ | ១៣,៤ | ១៣,៣ | ១៣,១ | ១៣,២ |
| ផលចំណូលជាមធ្យមពីទេសចរម្នាក់ (គិតជាដុល្លារ) | ៥៧៧ | ៥៥៥ | ៥៧២ | ៥៩១ | ៥៦៦ | ៥៦៣ | ៧៥០ |

*ប្រភព : MoT*

ចំនួនភ្ញៀវទេសចរ បានកើនឡើងជាលំដាប់រហូតដល់ឆ្នាំ២០០៨ បើទោះជាតាមអត្រាយឺតៗត្រឹម ៥,១៩% ក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ ការគណនាលំអិតបង្ហាញថា ចំនួនភ្ញៀវក្នុងត្រីមាសទីមួយ ទីពីរ និងទីបី បានកើនឡើង ១៤,៥%, ៦,៥% និង ៤% ដែលជាការបង្ហាញអំពីការថយចុះជាបណ្តើរៗ ។ ជាលើកដំបូងចាប់តាំងពីឆ្នាំ២០០៣ មក ចំនួនភ្ញៀវទេសចរមកដល់កម្ពុជាបានធ្លាក់ចុះ ៥,២៥% នៅក្នុងត្រីមាសទីបួន ឆ្នាំ២០០៨ ។[៣២] ចំនួននេះមិនមែនជាការប្រកាសអាសន្នឡើយ ប៉ុន្តែវាពិតជាបង្ហាញពីការធ្លាក់ចុះជាលើកដំបូងនៅក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ និងពិតជាបង្កឱ្យមានការព្រួយបារម្ភក្នុងចំណោមអ្នកពាក់ព័ន្ធនានា ។

និន្នាការធ្លាក់ចុះ បានបន្តទៅក្នុងឆ្នាំ២០០៩ ។ ចំនួនភ្ញៀវទេសចរ ដែលមកទស្សនាប្រទេសនេះ បានធ្លាក់ចុះបន្តិចប្រមាណ ២,២៨% នៅក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ ធៀបនឹងឆ្នាំទៅ ។[៣៣] ទោះជាយ៉ាងណាក៏ដោយ ចំនួននេះនៅតែមានកម្រិតខ្ពស់ជាងច្រើននៅឡើយ បើធៀបនឹងតួលេខសម្រាប់រដូវកាលដែលមានភ្ញៀវតិច នៅពាក់កណ្តាលឆ្នាំ២០០៨ ។ យោងតាមស្ថិតិពីក្រសួងទេសចរណ៍ (MoT) គេឃើញថា ប្រភពនៃភ្ញៀវទេសចរបានផ្លាស់ប្តូរ ។ ចាប់តាំងពីមានវិបត្តិហិរញ្ញវត្ថុពិភពលោក កម្ពុជាបានទទួលទេសចរក្នុងចំនួនតិចជាងមុនមកពីប្រទេសកូរ៉េ និងជប៉ុន ក៏ដូចជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ដទៃទៀតផងដែរ ប៉ុន្តែទេសចរមានចំនួនច្រើនជាងមុនមកពីប្រទេសដែលមានប្រាក់ចំណូលទាប ដូចជា វៀតណាម ចិន និងឡាវ ។ ប្រការនេះមានឥទ្ធិពលមកលើផលចំណូលពីវិស័យទេសចរណ៍របស់កម្ពុជា ។ ឧទាហរណ៍ : អ្នកទេសចរមកពីប្រទេសវៀតណាម ជាទូទៅ ធ្វើដំណើរតាមរថយន្តបីស ដែលចំណាយទាបជាង ហើយពួកគេចំណាយប្រាក់តិចជាងនៅក្នុងប្រទេសកម្ពុជា ។ ឥទ្ធិពលអវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចពិភពលោក ភាពមិនប្រាកដប្រជាខាងនយោបាយនៅក្នុងប្រទេសថៃ និងការផ្ទុះសាយភាយនៃជម្ងឺផ្តាសាយ A(H1N1) អាចនឹងនាំឱ្យមាននិន្នាការធ្លាក់ចុះជាបន្តបន្ទាប់ទៀត ។

### *រូបទី ៩. និន្នាការថ្មីៗនៃចំនួនភ្ញៀវទេសចរមកទស្សនាកម្ពុជា ខែមករា ឆ្នាំ២០០៨-ខែមិថុនា ឆ្នាំ២០០៩*




*ប្រភព : របាយការណ៍ស្ថិតិវិស័យទេសចរណ៍ ខែឧសភា ឆ្នាំ២០០៩, MoT*

---

[៣១] ដែលរួមទាំងអាជីវកម្ម និងគោលបំណងនានាផ្សេងទៀត

[៣២] ក្រសួងទេសចរណ៍

[៣៣] ក្រសួងទេសចរណ៍

ផលប៉ះពាល់បណ្ដាលពីការធ្លាក់ចុះនៃវិស័យទេសចរណ៍ មានភាពធ្ងន់ធ្ងរខ្លាំងបំផុតនៅក្នុងខេត្តសៀមរាប ដែលជាកន្លែងសំខាន់មួយសម្រាប់ទាក់ទាញភ្ញៀវទេសចរបរទេសមកកម្ពុជា។ នៅក្នុងពេលធ្វើការនៅតាមមូលដ្ឋានក្នុងខែឧសភា ឆ្នាំ២០០៩ អ្នកផ្ដល់ការសម្ភាសមួយចំនួន បានពោលថា អាជីវកម្មនៅក្នុងទីរួមខេត្ត កំពុងប្រតិបត្តិការប្រហែលទាបជាង ៤0% នៃកម្រិតដែលពួកគេបានឃើញនៅក្នុងពេលមួយឆ្នាំមុន។ ចំនួនភ្ញៀវទេសចរ ដែលមកខេត្តសៀមរាបនៅក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ២០០៩ បានធ្លាក់ចុះជាច្រើនធៀបនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០០៨ (សូមមើលរូបទី១០)។ ប្រការនេះមានឥទ្ធិពលធ្ងន់ធ្ងរមកលើសេដ្ឋកិច្ចនៃខេត្តនេះ។ គួរកត់សំគាល់ផងដែរថា ការធ្លាក់ចុះនេះ មានហេតុផលមួយផ្នែកបណ្ដាលមកពីរដូវកាល ដូចមានបង្ហាញក្នុងរូបទី ១០។ ចំពោះអាជីវកម្មដែលមានភាពរឹងប៉ឹង ការធ្លាក់ចុះនេះប៉ះពាល់មិនសូវធ្ងន់ធ្ងរទេ ប៉ុន្តែសម្រាប់ក្រុមដែលងាយរងគ្រោះ ដូចជា កម្មករគ្មានជំនាញ និងអ្នកលក់នៅតាមផ្លូវ ផលប៉ះពាល់នេះមានសភាពធ្ងន់ធ្ងរជាង។

*រូបទី ១០. និន្នាការថ្មីៗនៃភ្ញៀវទេសចរមកដល់ព្រលានយន្តហោះខេត្តសៀមរាប ខែមករា ឆ្នាំ២០០៨-មិថុនា ឆ្នាំ២០០៩*




*ប្រភព : ព្រលានយន្តហោះសៀមរាប*

## ៣.៣ កសិកម្ម

ក្រៅពីសម្លៀកបំពាក់ ប្រទេសកម្ពុជានាំចេញផលិតផលកសិកម្មមួយចំនួន ប៉ុន្តែភាគច្រើនជាការនាំចេញមិនផ្លូវការ និងមិនមានកំណត់ត្រាឡើយ។ ការនាំចេញផលិតផលសំខាន់ៗ ដូចជា ស្រូវ កៅស៊ូ និងត្រី ត្រូវបានប៉ាន់ប្រមាណ ឬកត់ត្រាខ្លះៗ ប៉ុន្តែការនាំចេញផលិតផលនានា ដូចជា ដំឡូងមី សណ្ដែកសៀង ពោត សណ្ដែកបាយ ល្ង និងគ្រាប់ស្វាយចន្ទី មានកំណត់ត្រាត្រឹមតិចតួចតែប៉ុណ្ណោះ (សូមមើលតារាងទី ៩)។ ការនាំចេញកសិកម្មផល ត្រូវបានរំពឹងថានឹងកើនឡើងនៅក្នុងឆ្នាំ២០០៩។ ទោះជាយ៉ាងណាក៏ដោយ ផលចំណូលពីការនាំចេញទំនងជាមានកម្រិតទាបជាង ដោយសារការធ្លាក់ថ្លៃ ដែលកើតចេញពីវិបត្តិនៃសេដ្ឋកិច្ចពិភពលោក។ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមលើកសិកម្មក្នុងការនាំយកប្រទេសនេះឆ្លងកាត់វិបត្តិនេះ។ ក្នុងន័យនេះ រដ្ឋាភិបាលបានបង្កើនការយកចិត្តទុកដាក់ជាបន្ថែមទៀតលើកសិកម្ម ដោយធ្វើវិសោធនកម្មលើច្បាប់ថវិកាឆ្នាំ២០០៩ ដើម្បីអនុញ្ញាតឱ្យមានការបន្ថែមទឹកប្រាក់ចំនួន ១៨ លានដុល្លារ ជាប្រាក់កំចីទៅឱ្យរោងម៉ាស៊ីនស្រូវ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ។ គេសង្ឃឹមថា ការធ្វើបែបនេះនឹងពង្រីកសមត្ថភាពក្នុងការទិញស្រូវ និងការកិនស្រូវសម្រាប់នាំចេញ ដែលជាផ្នែកមួយត្រូវការសាច់ប្រាក់ជាច្រើនរយលានដុល្លារ។

អាស្រ័យលើកម្រិតកំពស់ទឹកភ្លៀង ការប្រមូលផលបានល្អនឹងនាំឱ្យមាននៅសល់ផលស្រូវសម្រាប់ការនាំចេញ។ ក្នុងពេលដែលដីចំការកៅស៊ូកំពុងត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ប្រទេសនេះបាននាំចេញកៅស៊ូស្ងួតចំនួន ៤០.០០០ តោននៅក្នុងឆ្នាំ២០០៨ ហើយត្រូវបានរំពឹងថានឹងអាចនាំចេញ ៥០.០០០ តោន នៅឆ្នាំ២០០៩។ កំណើនការនាំចេញអង្ករ និងកៅស៊ូ ទំនងជាអាចទូទាត់នឹងការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់ ប្រសិនបើនិន្នាការធ្លាក់ចុះនៅក្នុងវិស័យកាត់ដេរ នៅតែបន្តនៅក្នុងរយៈពេលនៅសល់នៃឆ្នាំនេះ។ ការថយចុះ ១៥-២៥% នៃការនាំចេញសម្លៀកបំពាក់ អាចមានន័យថាជាការខាតបង់ជិត ៥០០-៦០០ លានដុល្លារអាមេរិក ចំណែកកំណើន ៥% នៃការរំពឹងទុកពីការនាំចេញអង្ករ និងកៅស៊ូ អាចនឹងទទួលបានត្រឹមតែ ៣០ លានដុល្លារ តែប៉ុណ្ណោះ (សូមមើលតារាងទី ៩)។ បើគិតជាតម្លៃបន្ថែម ការនាំចេញកៅស៊ូមានសារៈសំខាន់ខ្លាំងជាង បើទោះជានៅទាបជាងជាខ្លាំងធៀបនឹងតម្លៃ ដែលបានពីការនាំចេញសម្លៀកបំពាក់ក៏ដោយ។

### *តារាងទី ៩. ការនាំចេញរបស់កម្ពុជា ឆ្នាំ២០០២-២០០៧*

| | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ |
|---|---|---|---|---|---|---|
| ការនាំចេញសរុប (គិតជាលានដុល្លារ) | ១.៧៧០ | ២.០៨៧ | ២.៥៨៩ | ២.៩១០ | ៣.៦៩៤ | ៤.០៨៩ |
| ការនាំចេញសម្លៀកបំពាក់ (គិតជាលានដុល្លារ ជាភាគរយនៃការនាំចេញសរុប) | ១.៣៤៣ (៧៥,៩%) | ១.៦០៩ (៧៧,១%) | ១.៩៨២ (៧៦,៦%) | ២.១៩០ (៧៥,៣%) | ២.៦៥១ (៧១,៨%) | ២.៨៦៦ (៧០,១%) |
| ឈើមូល និងឈើអារ (លានដុល្លារ) | ៣៨ | ២០ | ១៦ | ១៦ | ១៨ | ២១ |
| ត្រី (លានដុល្លារ) | ៧៣ | ៧៦ | ៦៩ | ៧៦ | ៩០ | ១០៥ |
| កៅស៊ូ (លានដុល្លារ) | ៦៣ | ៩៨ | ១១៥ | ១១៩ | ១៧៥ | ១៥៧ |
| អង្ករ (លានដុល្លារ) | ២៨ | ៩៤ | ១១៤ | ១៧៧ | ៣៣២ | ៤១១ |

*ប្រភព : IMF និង MoC*

តារាងទី ១០ និងរូបទី ១១ ខាងក្រោមបង្ហាញថា ថ្លៃផលិតផលកសិកម្មសំខាន់ៗ បានធ្លាក់ចុះជាច្រើននៅដើមឆ្នាំ២០០៩ ធៀបនឹងខែឧសភា និងកក្កដា ឆ្នាំ២០០៨ នៅពេលដែលតួលេខឡើងដល់កំពូល។ បើទោះជាថ្លៃនៅពេលថ្មីៗនេះ មានកម្រិតទាបជាងតិចតួចធៀបនឹងអំឡុងពេលមុនឈានដល់កម្រិតកំពូលក៏ដោយ ផលិតករត្រូវចំណាយច្រើនលើការផលិត ដោយសារថ្លៃប្រេងមានកម្រិតខ្ពស់នៅក្នុងអំឡុងពេលមុនខែកក្កដា ឆ្នាំ២០០៨។ ប្រការនេះបាននាំឱ្យមានកំណើនជាច្រើននៃថ្លៃចំណាយលើគ្រឿងយន្ត ជីគីមី និងសម្ភារៈផ្សេងទៀត និងលើការដឹកជញ្ជូន។ ដោយសារតែថ្លៃស្បៀងឡើងខ្ពស់នៅក្នុងឆ្នាំ២០០៨ ថ្លៃចំណាយលើកម្លាំងពលកម្មក៏បានកើនឡើងប្រមាណជា ៥០% ផងដែរ។ អ្នកផលិតជាច្រើនអាចត្រូវខាតបង់ ឬទទួលបានផលចំណេញតិចតួច ពីការផលិតនៅក្នុងឆ្នាំទៅ។ នៅពេលដែលថ្លៃ និងផលចំណូលបានធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩ ប្រាក់កម្រៃបានធ្លាក់ចុះប្រមាណ ១០% ដែលឆ្លុះបញ្ចាំងអំពីកម្រិតនៃការធ្លាក់ចុះយឺតយ៉ាវ។[៣៤]

យោងតាមក្រុមហ៊ុននាំចេញកៅស៊ូមួយ ថ្លៃកៅស៊ូស្ងួតបានកើនឡើងដល់កំពូលមិនធ្លាប់មានពីមុនមក គឺ ៣.២៥០ ដុល្លារអាមេរិកក្នុងមួយតោន នៅក្នុងខែសីហា ឆ្នាំ២០០៨។ ថ្លៃជាមធ្យមនៅក្នុងខែនោះ មានជិត ៣.០០០ ដុល្លារក្នុងមួយតោន ធៀបនឹងប្រមាណ ២.០០០ ដុល្លារក្នុងមួយតោន កាលពីឆ្នាំទៅ។ កំណើនថ្លៃកៅស៊ូ បានកើតចេញពីកំណើនសេដ្ឋកិច្ចពិភពលោក ដែលនាំឱ្យមានកំណើនតម្រូវការរថយន្ត និងកង់រថយន្ត និងកំណើនថ្លៃប្រេង ដែលបាននាំឱ្យមានកំណើនថ្លៃកៅស៊ូសំយោគ។[៣៥] ប្រទេសចិន ដែលជាអ្នកប្រើប្រាស់កៅស៊ូធំជាងគេមួយ សម្រាប់តម្រូវការក្នុងស្រុក និងសម្រាប់ផលិតកង់រថយន្តសម្រាប់នាំចេញ ទាមទារឱ្យមានបរិមាណយ៉ាងច្រើននៃកៅស៊ូមកពីតំបន់អាស៊ីអាគ្នេយ៍។

---

[៣៤] នៅក្នុងសេដ្ឋកិច្ច ការធ្លាក់ចុះយឺតយ៉ាវសំដៅលើប្រការដែលថា គេងាយស្រួលក្នុងការបង្កើនប្រាក់កម្រៃនៅពេលអតិផរណាកំពុងកើនឡើង ជាងបញ្ចុះកម្រិតប្រាក់កម្រៃនៅពេលដែលអតិផរណាកំពុងធ្លាក់ចុះ។

[៣៥] ការសិក្សារួមគ្នាមួយ ស្តីពីការផលិត និងពាណិជ្ជកម្មកៅស៊ូ និងដំឡូងមី នៅក្នុងបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ បានធ្វើឡើងនៅក្នុងឆ្នាំ២០០៧ និង ២០០៨, ដែលជាផ្នែកមួយនៃបណ្តាញវិភាគអភិវឌ្ឍន៍ដែលសម្របសម្រួលដោយ CDRI។ សព្វថ្ងៃលទ្ធផលនេះ កំពុងត្រូវបានចាត់ចែងបោះពុម្ព។

### *តារាងទី ១០. ការប្រែប្រួលថ្លៃនៃផលិតផលកសិកម្មសំខាន់ៗ (រៀល/ គក្រ លើកលែងតែកៅស៊ូ)*

| ការលក់រាយ * | 0៦ កក្កដា ២00៨ | 0៦ កក្កដា ២00៩ | % ដែលផ្លាស់ប្តូរ |
|---|---|---|---|
| អង្ករ | ៣.២00 | ២.៥00 | -២២ |
| ត្រី | ១៤.៥00 | ១៣.000 | -១0 |
| សាច់គោ | ២៤.៥00 | ២២.៣00 | -៩ |
| សាច់ជ្រូក | ១៧.៥00 | ១៥.៣00 | -១៣ |
| សាច់មាន់ | ១៥.៥00 | ១៥.000 | -៣ |
| ការលក់ដុំ ** | 0៩ ឧសភា ២00៨ | 0៩ ឧសភា ២00៩ | % ដែលផ្លាស់ប្តូរ |
| ម្រេចខ្មៅ (កំពង់ចាម) | ១៣.៧៥0 | ៧.២៦៧ | -៤៧ |
| គ្រាប់ស្វាយចន្ទី (កំពង់ចាម) | ៣.១៤២ | ២.៩៧១ | -៥ |
| ដំឡូងមី (ចំណិតស្ងួត កំពង់ចាម) | ៧២៥ | ៤១៣ | -៤៣ |
| ពោត (ភ្នំពេញ) | ១.២៤៨ | ១.0៨៣ | -១៣ |
| ស្រូវ (ក្រោកពង់ កំពង់ចាម) | ១.៦00 | ៩៥0 | -៤១ |
| សណ្តែកសៀង (កំពង់ចាម) | ៣.១២៣ | ២.២៤២ | -២៨ |
| កៅស៊ូ (កំពង់ចាម) *** (ដុល្លារ/តោន) | ២.៥៦0 | ១.៤៤0 | -៤៤ |

*ប្រភព : *ការអង្កេតដោយ EIC នៅតាមទីផ្សារក្នុងក្រុងភ្នំពេញ*
*** MAFF*
**** ការសម្មាស*

### *រូបទី ១១. និន្នាការថ្លៃស្រូវ កៅស៊ូ និងពោតនៅក្នុងប្រទេសថៃ (ទីផ្សារមួយសម្រាប់ផលិតផលកសិកម្មពីកម្ពុជា)*




*ប្រភព : នាយកដ្ឋានគយនៃប្រទេសថៃ*

កំណើនយ៉ាងឆាប់រហ័សនៃថ្លៃកៅស៊ូ បានធ្វើឱ្យផលិតផលកៅស៊ូ បានទទួលផលចំណេញខ្ពស់ និងទាក់ទាញឱ្យមានចំណាប់អារម្មណ៍នៅក្នុងការវិនិយោគលើចំការកៅស៊ូនៅក្នុងឆ្នាំ២០០៨។ ទោះជាយ៉ាងណាក៏ដោយ មកទល់ចុងឆ្នាំ២០០៨ បន្ទាប់ពីមានការធ្លាក់ចុះនៃឧស្សាហកម្មរថយន្ត និងការថយចុះនៃថ្លៃប្រេង និងកៅស៊ូសំយោគថ្លៃកៅស៊ូធម្មជាតិនៅកម្ពុជា បានធ្លាក់ចុះពីកម្រិតកំពូលខ្ពស់ជាង ៣.០០០ ដុល្លារក្នុងមួយតោន នៅក្នុងអំឡុងពាក់កណ្តាលឆ្នាំ២០០៨ មកក្រោម ៩០០ ដុល្លារក្នុងមួយតោន នៅដើមឆ្នាំ២០០៩។ នៅក្រោយស្ថិតក្នុងតម្លៃទាបអស់រយៈពេលប៉ុន្មានខែមកនេះ ជាបណ្តើរៗថ្លៃនេះបានកើនឡើងមកដល់ប្រមាណ ១.៤០០ ដុល្លារក្នុងមួយតោន នៅក្នុងត្រីមាសទីពីរនៃឆ្នាំ២០០៩ ដែលផ្តល់ផលចំណេញបន្តិចបន្តួចដល់ម្ចាស់ចំការកៅស៊ូនានា។ ដំឡូងមី ក៏បានឆ្លងកាត់និន្នាការដូចគ្នានេះដែរ។ ថ្លៃស្រូវបានប្រែប្រួលតាមទម្រង់ដូចគ្នានេះមួយផ្នែកផងដែរ។ ផលប៉ះពាល់នៃការប្រែប្រួលថ្លៃផលកសិផលទាំងនេះ មកលើកសិករមានពិភាក្សានៅក្នុងផ្នែកទី ៤។

## ៣.៤ ទីផ្សារអចលនទ្រព្យ និងវិស័យសំណង់

ការសាងសង់ គឺជាវិស័យមួយក្នុងចំណោមវិស័យនានាដែលរងការប៉ះទង្គិចធ្ងន់ធ្ងរជាងគេ ដោយសារទំនាក់ទំនងជិតស្និទ្ធរបស់វិស័យនេះជាមួយ FDI។ ដូចមានពិភាក្សាខាងលើ ទាំងការវិនិយោគពេលបច្ចុប្បន្ន និងការវិនិយោគដែលអាចមានទៅអនាគតពីប្រទេសជឿនលឿនមួយចំនួន បានរងផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិនេះ ដែលធ្វើឱ្យមានការធ្លាក់ចុះយ៉ាងច្រើននូវមូលដ្ឋាននៃដើមទុនរបស់ពួកគេ ដែលជាការកំហិតលើការរំពឹងទុករបស់ពួកគេ ក្នុងការវិនិយោគនៅក្នុងទីផ្សារដែលទើបលេចឡើងថ្មី ដូចជា កម្ពុជាផងដែរ។ ជាលទ្ធផល គម្រោងសាងសង់ធំៗជាច្រើន ត្រូវបានព្យួរទុក។ ក្រុមហ៊ុនសំណង់ដែលបានផ្តល់ការសម្ភាសបានរាយការណ៍ អំពីការថយចុះជាខ្លាំងនៃចំនួនកិច្ចសន្យា ដែលពួកគេមានសម្រាប់ការងារទៅអនាគត។ Kang et al (២០០៩)[៣៦] បានប៉ាន់ប្រមាណថា FDI ផ្សំដោយ ៧៥% នៃដើមទុនសម្រាប់ការងារសំណង់ភាគច្រើន និងថា ៣០% នៃការងារនៅក្នុងវិស័យសំណង់ ត្រូវបានបាត់បង់ចាប់តាំងពីខែមករា ឆ្នាំ២០០៩ មក។

យោងតាមក្រុមហ៊ុនសំណង់នានា ពួកគេនៅត្រូវការកម្មករជាច្រើន ដើម្បីបង្ហើយគម្រោងចាស់ និងថ្មី រហូតដល់ដើមឆ្នាំ២០០៩។ ប៉ុន្តែក្រោយពេលដែលគម្រោងទាំងនេះបានបញ្ចប់ កម្មករជាច្រើនអាចនឹងត្រូវបាត់បង់ការងារ ដោយសារតែក្រុមហ៊ុនសំណង់ទទួលបានត្រឹមតែប្រមាណ ៣០-៥០% នៃបរិមាណការងារដែលពួកគេមាននៅក្នុងឆ្នាំទៅប៉ុណ្ណោះ។ នៅក្នុងខែខ្លះ កម្មករមួយចំនួនបានរងឥទ្ធិពលតិចតួចប៉ុណ្ណោះ ដោយសារភាពគ្មានការងារធ្វើជាបណ្តោះអាសន្ន អាចឱ្យពួកគេផ្តោតលើការរៀបចំដីសម្រាប់ធ្វើស្រែ និងស្ទូងស្រូវ នៅក្នុងដើមរដូវវស្សា (ខែឧសភា-តុលា)។ តាមធម្មតា ក្រោយពីស្ទូងស្រូវរួចហើយ ពួកគេនៅទំនេររហូតដល់ពេលត្រូវប្រមូលផលនៅក្នុងរយៈពេលបួន ឬប្រាំខែក្រោយមក (នៅក្នុងខែវិច្ឆិកា-ធ្នូ) ហើយពួកគេទំនងជាមកភ្នំពេញ ឬទីប្រជុំជនដទៃទៀត ដើម្បីធ្វើការតាមរដូវនៅក្នុងខែកក្កដា-តុលា។ ប្រសិនបើការរំពឹងទុកសម្រាប់ការសាងសង់ និងការបង្កើតការងារ មិនបានកែលម្អទេនោះ ពលករធ្វើការតាមរដូវជាច្រើននាក់ នឹងប្រឈមជាមួយការលំបាកក្នុងការទ្រទ្រង់គ្រួសាររបស់ពួកគេ។ ប្រការសំខាន់ គឺត្រូវធ្វើការតាមដានភាពគ្មានការងារធ្វើឱ្យបានទៀងទាត់ នៅក្នុងរយៈពេលជាច្រើនខែខាងមុខ។

វិបត្តិសេដ្ឋកិច្ច មានផលប៉ះពាល់មកលើថ្លៃអចលនទ្រព្យ។ ថ្លៃដីធ្លីនៅក្រុងភ្នំពេញ ត្រូវបានរាយការណ៍ថា បានធ្លាក់ចុះ ៥០% ជាមធ្យមធៀបនឹងរយៈពេលមួយឆ្នាំមុន។ យោងតាមក្រុមហ៊ុនអចលនទ្រព្យនាំមុខមួយ ឈ្មោះថា ប៊ុណ្ណា រៀលធី គ្រុប ថ្លៃផ្ទះ និងថ្លៃជួល ក៏បានធ្លាក់ចុះយ៉ាងច្រើនផងដែរ។ ប្រការនេះបានធ្វើឱ្យតម្លៃទ្រព្យទាំងនោះធ្លាក់ចុះ រួមទាំង ប្រាក់ចំណូលរបស់គ្រួសារនានា និងអាជីវកម្មនានាក៏ធ្លាក់ចុះផងដែរ ដែលបើពុំមានការធ្លាក់ចុះបែបនេះទេ ពួកគេនឹងអាចប្រើប្រាស់សម្រាប់ពង្រីកអាជីវកម្ម ឬវិនិយោគ ដែលជួយពង្រឹងកំណើនសេដ្ឋកិច្ច។ ការធ្លាក់ចុះនៃទីផ្សារអលនទ្រព្យរបស់កម្ពុជា មានភាពដូចគ្នានឹងស្ថានភាពនៅក្នុង ស.រ.អា ឬទីផ្សារផ្សេងទៀតផងដែរ ដែលកើតឡើងនៅក្រោយការឈានឡើងដល់កំពូល នៅក្នុងឆ្នាំ២០០៦ និង ២០០៧។

[៣៦] Kang, et al. "Rapid assessment of the impacts of the economic crisis on Cambodian households: component 2-informal risk management and safety net practices" (working title). Phnom Penh: CDRI, 2009 (forthcoming).

គួរកត់សំគាល់ផងដែរថា ជាទូទៅ ការអនុម័តលើគម្រោងសាងសង់ក្នុងក្រុងភ្នំពេញ មានតួលេខខ្ពស់នៅរវាងខែសីហា និងមករា ឆ្នាំ២០០៩ (សូមមើលរូបទី ១២)។ ស្ថានភាពនេះ កើតឡើងដោយសារគម្រោងសាងសង់មួយចំនួនផ្សេងពីសំណង់ភូមិគ្រឹះ ផ្ទះធម្មតា និង ផ្ទះល្វែង។ វាស្ថិតនៅក្នុងគម្រោងប្រភេទថ្មី ដែលហៅថា "គម្រោងផ្សេងៗ" រួមមាន គម្រោងអចលនទ្រព្យខ្នាតធំ ដូចជា អាគារខ្ពស់ៗ អាគារផ្ទះល្វែង និងសណ្ឋាគារ។ គម្រោងទាំងនេះ ដូចជា FDI ដែលបានអនុម័តហើយដែរ។ ជាក់ស្តែង វា គឺផ្នែកមួយនៃ FDI ដែលធ្វើការ សាងសង់គម្រោងទេសចរណ៏ខ្នាតធំ និងរោងចក្រនានា។ យោងតាមក្រុមហ៊ុនអភិវឌ្ឍន៏ អចលនទ្រព្យ គេត្រូវការពេលប្រមាណប្រាំមួយខែ ដើម្បីអាចទទួលបានការអនុញ្ញាតសាងសង់។ ពាក្យសុំអាចត្រូវបានដាក់ជូននៅក្នុងអំឡុងពេល ដែលមានការរីកចម្រើនដល់កម្រិតខ្ពស់បំផុត ប៉ុន្តែគេត្រូវការរយៈពេលជាច្រើនខែ ទើបអាចទទួលបានលិខិតអនុញ្ញាត។ បន្ទាប់មក ការអនុវត្តជាក់ស្តែងអាចនឹងត្រូវពន្យរទុកសិន។

*រូបទី ១២. ការអនុម័តលើគម្រោងសាងសង់*




*ប្រភព៖ សាលាក្រុងភ្នំពេញ*

# IV ផលប៉ះពាល់មកលើប្រជាជន



ផ្នែកនេះប៉ុនប៉ងធ្វើការពិនិត្យមើលពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក មកលើក្រុមខុសៗគ្នានៃប្រជាពលរដ្ឋ ជាពិសេស អ្នកក្រ អ្នកជិតធ្លាក់ក្នុងភាពក្រីក្រ និងអ្នកដែលងាយរងគ្រោះចំពោះការប៉ះទង្គិចនានា។ រលកនៃផលប៉ះពាល់ដំបូងមួយ សំដៅលើអ្នកដែលទទួលការប៉ះទង្គិចដោយផ្ទាល់ ដូចជា កម្មករនៅក្នុងឧស្សាហកម្មនានា ដែលរងឥទ្ធិពល ឬដែលពឹងផ្អែកលើទីផ្សារពីខាងក្រៅប្រទេស។ ភាគច្រើន នេះជាករណីដែលកើតមានចំពោះកសិករដែលផលិតសម្រាប់ការនាំចេញ។

រលកទីពីរនៃផលប៉ះពាល់មានឥទ្ធិពលមកលើប្រជាជន ដែលពឹងផ្អែកលើបុគ្គលនានា ដែលរងគ្រោះដោយផ្ទាល់ ឬដោយប្រយោល និងគ្រួសារនានា ដែលនឹងត្រូវផ្តល់ការគាំទ្រដល់កម្មករដែលបាត់បង់ការងារធ្វើ និងជនចំណាកស្រុកដែលវិលត្រឡប់មកផ្ទះវិញ។ ផ្នែកនេះពិភាក្សាអំពីថា តើផលប៉ះពាល់នេះ កំពុងមានឥទ្ធិពលបែបណា មកលើក្រុមប្រជាជនខុសៗគ្នានៅក្នុងដំណាក់កាលខុសៗគ្នា។

### *ស្ថានភាពនៃក្រុមងាយរងគ្រោះនៅកម្ពុជា*

| ក្រុមនានា | ចំនួន / ភាគរយ |
|---|---|
| យុវជនដល់វ័យធ្វើការ | ២៥០.០០០/១,៧% នៃចំនួនប្រជាជនសរុប[៣៧] |
| កុមារអាយុក្រោម ៥ ឆ្នាំ | ១,៣ លាន នាក់/៩,៧% នៃចំនួនប្រជាជនសរុប (CSES 2006-7) |
| កុមារដែលបាត់បង់ជីវិតដោយសារជម្ងឺដែលអាចចៀសវាងបាន | ៣០.០០០ (០,២% នៃចំនួនប្រជាជនសរុប) |
| អ្នកដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ | ១០,៥ លាននាក់ ៧៤,៦% (CSES 2006-7) |
| អ្នកគ្មានដីធ្លី | ២១,១% នៃគ្រួសារទាំងអស់នៅជនបទ CDRI[៣៨] |
| កសិករដែលមានដីធ្លីតិចជាង ០,៥ ហិកតា | ២៣,៤% នៃគ្រួសារទាំងអស់នៅជនបទ (CDRI) |
| ជនពិការ | ៨៥៤.០០០/៦,១% (CSES 2006-7) |
| ក្រុមជនជាតិភាគតិច | ៣០៨.០០០/២,២% (CSES 2006-7) |
| ជនរងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍ | ១,៣២ per ១០០០ (CSES 2006-7) |
| អសន្តិសុខស្បៀង | ១,៧ លាន (CDRI 2008)/១២,១% |
| កម្មកររោងចក្រកាត់ដេរដែលបាត់បង់ការងារ | ៦៣.០០០ ចាប់តាំងពីខែសីហា ឆ្នាំ២០០៨ (ក្រសួងពាណិជ្ជកម្ម) (១៤% នៃកម្មករកាត់ដេរ) |
| កម្មកររកស៊ីផ្លូវភេទ | ៣២.០០០ (ដោយផ្ទាល់ និងប្រយោល) ២០០៦ MoH |
| កម្មកររោងចក្រកាត់ដេរ | ៣០១.០០០ (ក្រសួងពាណិជ្ជកម្ម - សូមមើលក្រាហ្វិក) |
| ពលករចំណាកស្រុកទៅក្រៅប្រទេស | ៣៤៨.០០០/២,៥% of population (World Bank Migration Factbook – exact figures difficult to estimate due to informal nature of migration) |

[៣៧] យុវជនអាយុ ១៥–២៤ ឆ្នាំ តំណាងឱ្យ ២២% នៃចំនួនប្រជាជនសរុបនៅឆ្នាំ២០០៤។ ប្រភព : សង្ខេបគោលនយោបាយអំពីអត្រាការងាររបស់យុវជននៅកម្ពុជា របស់អង្គការ ILO. http://www.ilo.org/wcmsp5/groups/public/---asia/---ro bangkok/documents/publication/wcms_bk_pb_141_en.pdf

[៣៨] ការអង្កេតថ្នាក់ជាតិលើ ២.២៣៥ គ្រួសារ នៅក្នុងខែមិថុនា ឆ្នាំ២០០៨ ដែលបានធ្វើឡើងដោយ CDRI

## ៤.១ ជនរងគ្រោះនៅលំដាប់ទីមួយ

ជនរងគ្រោះនៅលំដាប់ទីមួយ រួមមាន កម្មករកាត់ដេរ កម្មករសំណង់ កម្មករឧស្សាហកម្មទេសចរណ៍ កសិករ និងកម្មករចំណាកស្រុក។ ការពិភាក្សាបន្តបានធ្វើឡើងដោយផ្អែកលើទិន្នន័យរបស់រដ្ឋាភិបាលអំពីឧស្សាហកម្មនេះទាំងមូល និងការយល់ឃើញតាមរយៈចុះទៅយកព័ត៌មាននៅមូលដ្ឋាន និងការសម្ភាស នៅក្នុងអំឡុងពេលនៃការសិក្សានេះ ក៏ដូចជាការអង្កេតដែលពាក់ព័ន្ធផ្សេងទៀតផងដែរ។

### ៤.១.១ កម្មករកាត់ដេរ

យោងតាមក្រសួងពាណិជ្ជកម្ម (MoC) ចំនួនសរុបនៃកម្មករក្នុងឧស្សាហកម្មកាត់ដេរ បានថយចុះពី ៣៥២.៩៥៥ នាក់ នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ ដែលភាគច្រើនជាកម្មការិនីពេញម៉ោង ដល់ ២៩០.៤៣៩ នាក់ នៅក្នុងខែឧសភា ឆ្នាំ២០០៩។ នេះមានន័យថាកម្មការិនីជាច្រើនដល់ទៅ៦៣.០០០នាក់ឬត្រូវជា១៨% នៃពលករសរុប បានបាត់បង់ការងារនៅក្នុងឆ្នាំកន្លងទៅ។លើសពីនេះ អ្នកដទៃទៀតជាច្រើនត្រូវបានព្យួរការងារជាបណ្ដោះអាសន្ន ឬមិនអាចធ្វើការថែមម៉ោងដូចមុនបាន។ ដោយសារកម្មករកាត់ដេរភាគច្រើន គឺជាស្ត្រីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក ភាគច្រើនមានឥទ្ធិពលមកលើស្ត្រី។ នៅក្នុងអំឡុងពេលនេះ មានសេចក្ដីរាយការណ៍ថា រោងចក្រចំនួន ៧០ បានបិទទ្វារ ប៉ុន្តែក្នុងនោះ រោងចក្រចំនួន ២០ នៅបើកទ្វារនៅឡើយ ដែលនាំឱ្យមានការបិទទ្វារជាក់ស្តែងចំនួន ៥០ រោងចក្រ។ ការបាត់បង់ប្រាក់បៀវត្សរ៍ ត្រូវបានប៉ាន់ប្រមាណថាមាន ៦,២ លានដុល្លារ ក្នុងមួយខែ។ តួលេខនេះ មិនបានរាប់បញ្ចូលនូវការធ្លាក់ចុះប្រាក់ចំណូលសម្រាប់កម្មករមួយចំនួន ដែលកំពុងនៅធ្វើការនោះទេ។ ការអង្កេតថ្មីៗលើសំណាកតូចមួយ ដែលបានធ្វើឡើងដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (CDRI) បានរកឃើញថា ប្រាក់ចំណូលរបស់កម្មករដែលនៅមានការងារធ្វើជាក់ស្តែងបានធ្លាក់ចុះ ១៨% រវាងខែឧសភា ឆ្នាំ២០០៨ និងខែឧសភា ឆ្នាំ២០០៩ ហើយប្រាក់ដែលផ្ញើទៅផ្ទះនៅជនបទបានធ្លាក់ចុះ ៦%។[៣៩] រោងចក្រមួយចំនួនតូចបានបិទទ្វារ និងបានបើកទ្វារឡើងវិញ ដើម្បីទាញយកផលចំណេញពីការអនុគ្រោះពន្ធ។ ប្រការនេះអាចធ្វើឱ្យកាន់តែលំបាក ដើម្បីធ្វើការគណនាឱ្យបានសុក្រឹត្យ អំពីចំនួនកម្មករដែលបានបាត់បង់ការងារជាក់ស្តែង។

ការបាត់បង់ការងារជាចំនួនច្រើននៅក្នុងឧស្សាហកម្មកាត់ដេរ បានផ្ដល់ជាភេរវសញ្ញាដល់អ្នកកសាងគោលនយោបាយ និងភាគីពាក់ព័ន្ធនានា។ រដ្ឋាភិបាលបានឆ្លើយតបដោយការផ្ដល់ ៧,៥ លានដុល្លារ ដើម្បីបណ្ដុះបណ្ដាលកម្មករដែលបាត់បង់ការងារទាំងនោះដែលរួមទាំងកម្មករកាត់ដេរ សម្រាប់រយៈពេលពីមួយទៅបួនខែ និងផ្ដល់មីក្រូឥណទាន ដើម្បីបង្កើតជំនួញខ្នាតតូច នៅក្រោយពេលបានទទួលការបណ្ដុះបណ្ដាល។ រដ្ឋាភិបាលក៏កំពុងលើកទឹកចិត្តឱ្យមានការវិនិយោគកាន់តែច្រើនផងដែរ នៅក្នុងវិស័យកសិកម្ម ដើម្បីសម្រួលដល់ការស្រូបយកកម្មករនៅក្នុងសហគមន៏ជនបទ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនកម្មករដែលបាត់បង់ការងារទាំងអស់ សុទ្ធតែវិលត្រឡប់ទៅជនបទវិញនោះទេ។ កម្មករជាច្រើនបន្តរស់នៅក្នុងក្រុងភ្នំពេញ ដើម្បីស្វែងរកការងារផ្សេងទៀត ឬស្នាក់នៅជាមួយសហព័ទ្ធ ឬដៃគូរបស់ពួកគេ។ ពុំមានការអង្កេត ឬការសិក្សា ដែលអាចបញ្ជាក់បានជាក់លាក់អំពីថា តើមានកម្មករបាត់បង់ការងារប៉ុន្មាននាក់ដែលវិលត្រឡប់ទៅជនបទវិញនោះឡើយ តើប៉ុន្មាននាក់បានរកការងារផ្សេងធ្វើ និងតើមានប៉ុន្មាននាក់ដែលបានបន្តស្នាក់នៅក្នុងទីក្រុងដើម្បីស្វែងរកការងារធ្វើ។ ការសិក្សាមួយបានគ្រោងឡើងដោយ UNDP និងអង្គការពលកម្មអន្តរជាតិ (ILO) ដើម្បីឆ្លើយនឹងសំណួរទាំងនេះក្នុងចំណោមសំណួរផ្សេងៗទៀត។

[៣៩] Hang, Saing Chan. "Impacts of global economic crisis on garment workers and remittances in Cambodia". Public Forum on the Impact of the Global Economic Downturn and the Need for Policy Responses. Cambodia-Japan Cooperation Center. 14 July 2009. Presentation.

## ប្រអប់ទី ២. កម្មករកាត់ដេរដែលបាត់បង់ការងារ

ការសម្ភាសមួយចំនួន បានធ្វើឡើងជាមួយកម្មករដែលបាត់បង់ការងារ ដែលបានវិលត្រឡប់ទៅជនបទវិញ និងអ្នកដែលបន្តស្នាក់នៅក្រុងភ្នំពេញ។ កម្មករសរុបចំនួន ៣៣ នាក់ ដែលមានស្រុកកំណើតក្នុងក្រុងភ្នំពេញ ខេត្តកណ្ដាល កំពង់ស្ពឺ កំពង់ធំ កំពង់ចាម និងព្រៃវែង ត្រូវបានស្នើសុំឱ្យផ្ដល់ការសម្ភាស ដើម្បីស្វែងយល់អំពីបញ្ហានានាជាច្រើនដែលពួកគេបានប្រឈម។ អ្នកដែលបានផ្ដល់ការសម្ភាសទាំងអស់សុទ្ធតែជាស្ត្រី ដែលឆ្លុះបញ្ចាំងអំពីស្ត្រីភាគច្រើនបំផុតនៅក្នុងពលកររោងចក្រកាត់ដេរ។ ជាមធ្យម ពួកគេមានអាយុ ២៥ ឆ្នាំ និងបានបញ្ចប់ការសិក្សាត្រឹម ៦,២ ឆ្នាំ។ បើទោះជាពួកគេនៅជាយុវជនក៏ដោយ ពួកគេម្នាក់ៗ ត្រូវទ្រទ្រង់មនុស្សក្នុងបន្ទុកជាមធ្យមបួននាក់។ ពួកគេទាំងអស់បានបាត់បង់ការងារសម្រាប់រយៈពេលពីមួយខែទៅប្រាំពីរខែ បន្ទាប់ពីបានធ្វើការនៅក្នុងវិស័យនេះអស់រយៈពេល ២,៩ ឆ្នាំ ជាមធ្យម។ ប្រាក់ចំណូលប្រែប្រួលក្នុងរវាងពី ៦០-១២០ ដុល្លារក្នុងមួយខែ។ ពួកគេម្នាក់ៗ អាចសន្សំប្រាក់បានជាមធ្យម ៣៤,៤ ដុល្លារ ជារៀងរាល់ខែ ដើម្បីជួយទ្រទ្រង់គ្រួសាររបស់ពួកគេ។ តួលេខនេះស្របគ្នាជាមួយការអង្កេតទ្រង់ទ្រាយធំជាងនេះ ដែលបានធ្វើឡើងប្រចាំត្រីមាសនៅក្នុងខែឧសភា ឆ្នាំ២០០៩ ដោយ CDRI។

### វ៉ា វឌ្ឍា:

វ៉ា វឌ្ឍា ជានារីអាយុ ២៦ ឆ្នាំ ដែលបានរៀបការរួចហើយ មកពីភូមិស្ពឺ ឃុំជ័យយោ ស្រុកចំការលើ ខេត្តកំពង់ចាម បានធ្វើការនៅក្នុងខេត្តកណ្ដាលអស់រយៈពេលបួនឆ្នាំ ប៉ុន្តែការងាររបស់គាត់បានបញ្ចប់នៅខែមីនា ឆ្នាំ២០០៩។ គាត់បានវិលត្រឡប់មកផ្ទះវិញដើម្បីរស់នៅជាមួយស្វាមី ដោយសារគាត់មិនអាចរកការងារធ្វើនៅរោងចក្រផ្សេងបាន។

សូម្បីតែនៅពេល វឌ្ឍា អាចរកប្រាក់បាន ១២០ ដុល្លារ នៅខេត្តកណ្ដាលក៏ដោយ គាត់មិនអាចសន្សំប្រាក់បានឡើយ ដោយសារគាត់ត្រូវចំណាយអស់ ៧០ ដុល្លារ ទៅលើអាហារ ការស្នាក់នៅ និងការចំណាយផ្ទាល់ខ្លួនដទៃទៀតរបស់គាត់ ហើយគាត់បានផ្ញើប្រាក់នៅសល់ចំនួន ៥០ ដុល្លារ ទៅផ្ទះ ដើម្បីចំណាយសម្រាប់ការរស់នៅ និងការសិក្សារបស់កូនពីរនាក់របស់គាត់។ សព្វថ្ងៃនេះ វឌ្ឍា ត្រូវពឹងផ្អែកលើប្រាក់ចំណូលរបស់ស្វាមីទាំងស្រុង ដើម្បីទ្រទ្រង់កូនទាំងពីរនាក់។

វឌ្ឍា ចង់បើកកន្លែងលក់គ្រឿងទេសមួយ ប៉ុន្តែគាត់មិនមានដើមទុនសោះ។ គាត់អាចខ្ចីប្រាក់ពីអ្នករកស៊ីចងការប្រាក់ ប៉ុន្តែគាត់មិនចង់ប្រថុយឡើយ ដោយសារគាត់មើលឃើញថា មានអ្នកទិញតិចតួចតែប៉ុណ្ណោះនៅក្នុងទីផ្សារ។ វឌ្ឍា គិតថារដ្ឋាភិបាលគួរតែបង្កើតការងារឱ្យបានច្រើន សម្រាប់កម្មកររោងចក្រដែលបាត់បង់ការងារ ជាពិសេស ធ្វើឱ្យរោងចក្រនៅដំណើរការ ដោយសាររោងចក្រទាំងនោះ ផ្ដល់ការងារដល់ស្ត្រីមកពីជនបទ ដែលមានការអប់រំតិចតួច។

### អ៊ាន ចិន:

អ៊ាន ចិន មានអាយុ ១៩ ឆ្នាំ នៅលីវ រស់នៅក្នុងខេត្តកំពង់ស្ពឺ និងធ្លាប់បានធ្វើការជាកម្មករកាត់ដេរ ចាប់តាំងពីចុងឆ្នាំ២០០៦មក។ នាងរកបាន ៨០ ដុល្លារ ក្នុងមួយខែ ដែលក្នុងនោះ ៤០ ដុល្លារ ត្រូវបានបែងចែកសម្រាប់ទ្រទ្រង់គ្រួសាររបស់នាងដែលមានសមាជិកប្រាំនាក់ ហើយនាងចំណាយប្រាក់ដែលនៅសល់សម្រាប់អាហារ និងការធ្វើដំណើរទៅធ្វើការ និងចំនួនតិចតួចសម្រាប់ការចំណាយផ្សេងៗ។ នៅខែធ្នូ ឆ្នាំ២០០៨ នាងបានបាត់បង់ការងារជាបណ្ដោះអាសន្ននៅពេលដែលរោងចក្រ ដែលនាងធ្វើការមិនបានទទួលការបញ្ជាទិញ។ ចិន បានដាក់ពាក្យសុំធ្វើការនៅរោងចក្រចំនួនពីរផ្សេងទៀត ប៉ុន្តែមិនបានទទួលឱ្យធ្វើការនៅក្នុងរោងចក្រណាមួយឡើយ។ចិននិងគ្រួសាររបស់នាង មានការលំបាកខាងស្ថានភាពហិរញ្ញវត្ថុ ក្នុងពេលដែលចិនគ្មានការងារធ្វើ ដោយសារទាំងចិន និងគ្រួសាររបស់នាង មិនមានប្រាក់សន្សំឡើយ។

ចិន ត្រូវបានរោងចក្រហៅឱ្យវិលត្រឡប់ទៅធ្វើការវិញនៅក្នុងខែមេសា ឆ្នាំ២០០៩ ប៉ុន្តែមានការផ្តល់កិច្ចសន្យាសម្រាប់តែរយៈពេលមួយខែម្តងៗប៉ុណ្ណោះ។ កិច្ចសន្យាអាចបន្តបានជារៀងរាល់ខែ តាមការចាំបាច់ពីនិយោជក។ និយោជកនឹងមិនផ្តល់សំណងណាមួយឡើយ ប្រសិនបើត្រូវសម្រេចបណ្តេញ ឬមិនបន្តកិច្ចសន្យាដល់និយោជិតណាម្នាក់។ សូម្បីតែ ចិន ត្រូវខំប្រឹងប្រែងធ្វើការខ្លាំង ហើយជូនកាលនិយោជករបស់នាងធ្វើមិនល្អចំពោះរូបនាងក៏ដោយ នាងនៅតែចង់ធ្វើជាកម្មករកាត់ដេរ ដោយសារនាងមិនមានជំនាញណាផ្សេងទៀតឡើយ។ ចិន ចង់ឱ្យរដ្ឋាភិបាលការពារកម្មករពីការកេងប្រវ័ញ្ច និងជួយកម្មករឱ្យចរចាដើម្បីបានប្រាក់បៀវត្សរ៍ប្រសើរជាងនេះ ពោល គឺរវាង ៩០-១០០ ដុល្លារ ដើម្បីពួកគេអាចរស់នៅក្នុងលក្ខខណ្ឌបានសមរម្យ។

**នេត្រ សុផល :**

នេត្រ សុផល ជាកម្មករកាត់ដេរដែលបាត់បង់ការងារ នៅក្នុងខែមីនា ឆ្នាំ២០០៩ ក្រោយពេលដែលបានធ្វើការនៅរោងចក្រកាត់ដេរមួយអស់រយៈពេលបីឆ្នាំកន្លះរួចមក។ ជាសំណាងល្អ សុផល មានជំនាញអ៊ុតសក់ ដូច្នេះនាងមានការងារធ្វើនៅក្នុងហាងអ៊ុតសក់មួយ ក្រោយពេលដែលនាងមិនអាចរកការងារធ្វើនៅក្នុងរោងចក្រដទៃទៀតបាន។

កាលនៅជាកម្មកររោងចក្រកាត់ដេរ សុផល មានប្រាក់ចំណូល ៨៥ ដុល្លារក្នុងមួយខែ។ បើទោះជានាងមិនអាចសន្សំប្រាក់បានក៏ដោយ នាងនៅតែអាចបញ្ជូនទៅផ្ទះបាន ៣០ ដុល្លារក្នុងមួយខែ ដើម្បីបំពេញបន្ថែមលើប្រាក់ចំណូលរបស់គ្រួសារនាង។

នាងអាចរកប្រាក់បានត្រឹមតែ ៣៥ ដុល្លារប៉ុណ្ណោះ ក្នុងមួយខែ នៅពេលធ្វើការជាអ្នកអ៊ុតសក់។ ចំនួននេះស្ទើរតែមិនគ្រប់សម្រាប់ចំណាយលើចំណីអាហារ និងកន្លែងស្នាក់នៅផង។ គ្រួសាររបស់នាង ក៏បានជារងគ្រោះដែរ។

សុផល រំពឹងថានឹងអាចទៅធ្វើការនៅរោងចក្រកាត់ដេរវិញ ប៉ុន្តែនាងមិនដឹងថា នៅពេលណាដែលរោងចក្រនឹងបើកទ្វារឡើងវិញឡើយ។ សុផល អាចបើកកន្លែងអ៊ុតសក់មួយដោយខ្លួនឯងបាន ប៉ុន្តែនៅក្នុងបរិយាកាសសេដ្ឋកិច្ចសព្វថ្ងៃនេះ នាងបារម្ភថា នេះមិនមែនជាពេលល្អ ដើម្បីចាប់ផ្តើមរបរថ្មីមួយឡើយ។ នាងសង្ឃឹមថា នឹងមានរោងចក្រកាន់តែច្រើន ដើម្បីផ្តល់ការងារសម្រាប់នារី និងស្ត្រីក្រីក្រដែលមិនបានសិក្សា ដោយសារពួកគេមិនមានជម្រើសច្រើនឡើយ។ ទោះជាយ៉ាងណាក៏ដោយ នាងគិតថា ប្រាក់បៀវត្សរ៍របស់កម្មកររោងចក្រ គួរតែមានពី ៨០-១០០ ដុល្លារ។

*ប្រភព : ការសម្ភាសដោយ UNDP នៅថ្ងៃទី ១២-១៨ ខែឧសភា ឆ្នាំ២០០៩*

### ៤.១.២ កម្មករសំណង់

គេពុំមានតួលេខស្ថិតិច្បាស់លាស់អំពីថា តើកម្មករសំណង់ប៉ុន្មាននាក់បានបង់ការងារឡើយ ដោយសារឧស្សាហកម្មនេះផ្តល់ការងារក្រៅផ្លូវការជាច្រើន។ ឧស្សាហកម្មសំណង់ផ្តល់ការងារប្រមាណ ៣,៦% ឬ ២៧0,000 ការងារនៃចំនួនការងារសរុប។ នេះជាវិស័យមួយដែលបានរងឥទ្ធិពលដោយផ្ទាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក និងការកាត់បន្ថយនូវការចំណាយលើគម្រោង FDI និងពីក្រុមហ៊ុនក្នុងស្រុក។ ការងារជាច្រើនពាន់ ត្រូវបានប៉ាន់ប្រមាណថា បានបាត់បង់នៅក្នុងរយៈពេលប្រាំបីខែមុននេះ។[៤០]

[៤០] Chandararot, Kang, Sok Sina, and Liv Dannet . Rapid Assessment of the Impact of the Financial Crisis in Cambodia. Bangkok: ILO Subregional Office for East Asia, 2009.

## ប្រអប់ទី ៣. កម្មករសំណង់ដែលបាត់បង់ការងារ

ការសម្ភាសជាមួយកម្មករសំណង់ចំនួនដប់នាក់ ដែលមានអាយុក្នុងរវាងពី ២១ ដល់ ២៩ ឆ្នាំ បានបង្ហាញថា ពួកគេធ្លាប់រកប្រាក់ចំណូលបានក្នុងរវាង ៤០ និង ១៨០ ដុល្លារ ដែលមានកម្រិតខ្ពស់ច្រើន ធៀបនឹងកម្មករកាត់ដេរ។ អ្នកទាំងនោះភាគច្រើនបានទទួលប្រាក់កម្រៃប្រចាំថ្ងៃ។ពួកគេអាចសន្សំបាន ៤៤ ដុល្លារក្នុងមួយខែ ដើម្បីទ្រទ្រង់គ្រួសាររបស់ពួកគេ ដែលជាបរិមាណច្រើននៅក្នុងប្រទេសមួយដែលខ្សែបន្ទាត់នៃភាពក្រីក្រ គឺប្រាក់ចំណូលកន្លះដុល្លារក្នុងមួយថ្ងៃ។

ប្រាំមួយនាក់ ក្នុងចំណោមកម្មករបាត់បង់ការងារធ្វើទាំង ១០ នាក់ រកបានការងារផ្សេងទៀតដែលអាចផ្តល់ប្រាក់កម្រៃនៅក្រោយពួកគេបានបាត់បង់ការងារ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេរកប្រាក់ចំណូលបានតិចជាងមុន។ អ្នកដែលនៅសល់ពីនោះបានធ្វើការដែលគ្មានប្រាក់កម្រៃសម្រាប់គ្រួសាររបស់ខ្លួន ឬមិនមានការងារធ្វើ និងបន្តស្វែងរកការងារធ្វើ។ អ្នកទាំងនោះ ភាគច្រើនរស់នៅជាមួយគ្រួសារនៅតាមផ្ទះជួល។ អ្នកទាំងអស់មានការព្រួយបារម្ភថា ប្រសិនបើពួកគេ ឬគ្រួសាររបស់ពួកគេធ្លាក់ខ្លួនឈឺ ពួកគេនឹងគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ព្យាបាលជម្ងឺឡើយ។

ពួកគេបានលើកឡើង អំពីបញ្ហានៃការមិនទទួលបានប្រាក់កម្រៃពេញលេញពីគម្រោងដែលពួកគេធ្លាប់បានធ្វើ។ អ្នកខ្លះមិនបានទទួលប្រាក់កម្រៃទាល់តែសោះ។ នៅពេលសួរថា តើពួកគេចង់បានជំនួយអ្វីខ្លះពីរដ្ឋាភិបាល និងសង្គមស៊ីវិល អ្នកទាំងនោះភាគច្រើនបានអំពាវនាវដល់រដ្ឋាភិបាលឱ្យព្យាយាមទាក់ទាញឱ្យមានគម្រោងសាងសង់ច្រើនថែមទៀត និងឱ្យមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចជា ជួសជុលប្រព័ន្ធទឹក អគ្គិសនី និងជំនាញសាងសង់ផ្សេងទៀត។

*ប្រភព : ការសម្ភាសដោយ UNDP នៅថ្ងៃទី ១២-១៨ ខែឧសភា ឆ្នាំ២០០៩*

### ៤.១.៣ កម្មករឧស្សាហកម្មទេសចរណ៍

ការប៉ាន់ប្រមាណរហ័សមួយ ដែលបានធ្វើឡើងដោយអង្គការ ILO នៅក្នុងខែមីនា ឆ្នាំ២០០៩ បានរាយការណ៍ថា ក្នុងខណៈដែលគ្មានការបញ្ឈប់ការងារយ៉ាងច្រើនភ្លាមៗ នៅក្នុងវិស័យទេសចរណ៍ក៏ដោយ ករណីគ្មានការងារធ្វើបានកើនឡើង រីឯប្រាក់ចំណូល ក៏នឹងអាចថយចុះផងដែរ។[៤១] កម្មករនៅក្នុងឧស្សាហកម្មទេសចរណ៍ ដែលរួមទាំងអ្នកធ្វើការនៅក្នុងសណ្ឋាគារ ផ្ទះសំណាក់ ទីភ្នាក់ងារទេសចរ និងប្រតិបត្តិករទេសចរ មគ្គុទេសក៍ភ្ញៀវទេសចរ ភោជនីយដ្ឋាន ហាងម៉ាស្សា ហាងលក់វត្ថុ អនុស្សាវរីយ៍ និង កម្មករខាងផ្នែកដឹកជញ្ជូន នៅតែមានការងារធ្វើនៅឡើយ ប៉ុន្តែការធ្វើការងារដើម្បីខ្លួនឯង អាចរកប្រាក់បានតិចជាងមុន។ ចាប់តាំងពីខែមេសា ឆ្នាំ២០០៩ មកស្ថានភាពនេះបានធ្លាក់ចុះកាន់តែអាក្រក់ ដោយសារមិនត្រឹមតែរងការប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារការភ័យខ្លាចពីការឆ្លងជម្ងឺផ្តាសាយ A(H1N1) ផងដែរ។ យោបល់ដែលទទួលបានពីការសម្ភាសមិនដូចគ្នាឡើយ អំពីទំហំដែលផលប៉ះពាល់នៃជម្ងឺផ្តាសាយ A(H1N1) បង្កឱ្យមានការធ្លាក់ចុះចំនួនភ្ញៀវទេសចរនាពេលថ្មីៗនេះ។

ការថយចុះយ៉ាងគំហុកនៅពេលថ្មីៗនេះនៃសកម្មភាពអាជីវកម្មបានលេចឡើងច្បាស់នៅក្នុងខេត្តសៀមរាបដែលជាទីក្រុងទេសចរណ៍ធំជាងគេនៅក្នុងប្រទេសកម្ពុជា ដោយសារតែវាសម្បូរទៅដោយប្រាសាទបុរាណ។ យោងតាមមន្ត្រីនៃសមាគមសណ្ឋាគារ អត្រាស្នាក់នៅក្នុងសណ្ឋាគារក្នុងត្រីមាសទីមួយ ឆ្នាំ២០០៩ បានធ្លាក់ចុះ ៤០% ដែលនាំឱ្យសណ្ឋាគារមួយចំនួនបិទទ្វារជាបណ្តោះអាសន្ន។ ការថយចុះដ៏ធ្ងន់ធ្ងរនេះ ដែលត្រូវបានរាយការណ៍ថា បានចាប់ផ្តើមនៅក្រោយថ្ងៃចូលឆ្នាំថ្មី នៅពាក់កណ្តាលខែមេសា ឆ្នាំ២០០៩ ដែលត្រូវបានចាត់ទុកថាកើតឡើងដោយសារមូលហេតុមួយចំនួនរួមគ្នា : (i) វិបត្តិសេដ្ឋកិច្ចពិភពលោក (ii) ការភ័យខ្លាចឆ្លងជម្ងឺផ្តាសាយ A(H1N1) (iii) ជារដូវដែលមានភ្ញៀវតិច និង (iv) ព្រឹត្តិការណ៍ដោយឡែករបស់កម្ពុជា ដូចជា ការសម្រេចរបស់រដ្ឋាភិបាលឱ្យបិទអាជីវកម្មក្លឹបល្បែងស៊ីសង

[៤១] Chandararot, Kang, Sok Sina, and Liv Dannet. Rapid Assessment of the Impact of the Financial Crisis in Cambodia. Bangkok: ILO Subregional Office for East Asia, 2009.

និងក្រុមហ៊ុនភ្នាល់ចាក់បាល់។ មូលហេតុទាំងនេះ ត្រូវបានចង្អុលបញ្ជាក់ដោយម្ចាស់អាជីវកម្មខ្នាតតូចនានា ដូចជា ភោជនីយដ្ឋាន ម៉ូតូឌុប និងម្ចាស់តូបលក់អាហារ ថាបានរួមចំណែកធ្វើឱ្យមានការធ្លាក់ចុះនៃចំនួនអតិថិជន។ នៅឆ្នាំ២០០៨ ការថយចុះតាមរដូវនៃចំនួនភ្ញៀវដែលមកដល់តាមព្រលានយន្តហោះ មានអត្រាខ្ពស់រហូតដល់ ៥០% នៅរវាងខែឧសភា និងមករា (សូមមើលរូបទី ១០)។

## ប្រអប់ទី ៤. អ្នកលក់នៅខេត្តសៀមរាប

អ្នកលក់វត្ថុអនុស្សាវរីយ៍ម្នាក់នៅសៀមរាប បានរាយការណ៍ថា គាត់លក់បានត្រឹមតែ ៣០% នៃបរិមាណដែលគាត់លក់បានកាលពីឆ្នាំទៅ។ គាត់បានបន្ទោសវិបត្តិសេដ្ឋកិច្ចពិភពលោក និងការប្រកួតប្រជែងនៃអ្នកជំនួញវត្ថុអនុស្សាវរីយ៍កូរ៉េ ជាមូលហេតុនៃការធ្លាក់ចុះនេះ។ ជាលទ្ធផល គ្រួសារនេះបានកាត់បន្ថយការចំណាយ និងបានខ្ចីប្រាក់ពីសាច់ញាតិ ដែលមិនទាមទារការប្រាក់ពីគាត់ឡើយ។

អ្នកលក់ផ្លែឈើបានពោលអំពីដំណើររឿងប្រហាក់ប្រហែលគ្នានេះ។ អាជីវករដែលផ្តល់ការសម្ភាសបានរាយការណ៍ថា ប្រាក់ចំណូលបានធ្លាក់ចុះច្រើនជាង ៥០% ធៀបនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំទៅ។ សម្រាប់អ្នកដែលបានប្រឹងប្រែងសន្សំប្រាក់កាសខ្លះនៅមុនមានវិបត្តិនេះ ពួកគេអាចមិនសូវប្រឈមនឹងការលំបាកខ្លាំងពេកទេ ប៉ុន្តែអ្នកក្រនឹងត្រូវប្រឈមការលំបាកជាបន្ថែមទៀតក្នុងពេលឆាប់ៗខាងមុខនេះ ប្រសិនបើស្ថានភាពនេះមិនកែលម្អទេនោះ។ មិនដូចឧស្សាហកម្មកាត់ដេរឡើយ ដែលភាគច្រើនមានកម្មការិនី និងឧស្សាហកម្មសំណង់ដែលភាគច្រើនជាបុរស កម្មករនានានៅក្នុងជំនួញដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍មានទាំងបុរស និងនារី។

*ប្រភព : ការសម្ភាសដោយ UNDP នៅថ្ងៃទី ១២-១៨ ខែឧសភា ឆ្នាំ២០០៩*

### ៤.១.៤ កសិករ

ការវាយតម្លៃដោយឆាប់រហ័សរបស់អង្គការ ILO នៅខែមីនា ឆ្នាំ២០០៩ បានរកឃើញអំពីកំណើនជារួមនៃការងារធ្វើនៅក្នុងវិស័យកសិកម្ម បើទោះជាមានការធ្លាក់ចុះនៃប្រាក់ចំណូលក្នុងម្នាក់ៗក៏ដោយ។ កំណើនការងារធ្វើនេះ គឺដោយសារការស្រូបយកកម្មករដែលបាត់បង់ការងារពីវិស័យផ្សេងទៀត។ ប្រាក់ចំណូលបានធ្លាក់ចុះ ដោយសារកំណើនការផ្គត់ផ្គង់ពលករ។ លើសពីនេះ កសិករជាច្រើនធ្វើការវិនិយោគនៅក្នុងអំឡុងពេលនៃអតិផរណានៅក្នុងឆ្នាំទៅ នៅពេលដែលថ្លៃទំនិញនានាមានកម្រិតខ្ពស់ ហើយការធ្លាក់ចុះជាសកលនៃថ្លៃទំនិញនៅឆ្នាំនេះ នឹងនាំឱ្យផលចំណូលថយចុះ។[៤២]

ការអង្កេតគ្រួសារនានា ជាតំណាងនៅទូទាំងប្រទេស ដើម្បីប៉ាន់ប្រមាណអំពីផលប៉ះពាល់នៃកំណើនថ្លៃអាហារកាលពីឆ្នាំទៅ បានរកឃើញថា ថ្លៃកម្លាំងពលកម្មបានកើនឡើង ៤៧% ហើយថ្លៃផលិតផលកសិកម្ម បានឡើងខ្ពស់ពី ៣០-៥០% មួយផ្នែក ដោយសារកំណើនបីដងនៃថ្លៃជី និងកំណើន ៥០% នៃថ្លៃប្រេងម៉ាហ្សូត និងប្រេងសាំង (CDRI, ២០០៨)។ កសិករកម្ពុជាបានរំពឹងថា ថ្លៃទំនិញនឹងនៅតែបន្តមានកម្រិតខ្ពស់ និងបានខ្ចីប្រាក់ ដើម្បីទិញសម្ភារៈកសិកម្ម។ ជាសំណាងអាក្រក់ ថ្លៃផលដំណាំទាំងនេះបានធ្លាក់ចុះជាខ្លាំង ហើយកសិករជាច្រើនបានចាប់ផ្តើមខាតបង់។ វិបត្តិសេដ្ឋកិច្ចកំពុងតែប៉ះពាល់ដល់កសិករ និងកម្មករនៅក្នុងវិស័យកសិកម្ម ដែលធ្វើឱ្យមានការជាប់បំណុល និងខកបំណងដែលរំពឹងទុកថាកសិផលនឹងមានថ្លៃខ្ពស់។

យោងតាមស្ថិតិដែលប្រមូលបានដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងធចប ផ្ទៃដីដាំដំឡូងមីសរុបនៅកម្ពុជា បានកើនឡើងពីមួយលាន ទៅពីរលានហិកតា នៅរវាងឆ្នាំ២០០៧ និង២០០៨។ ប្រការនេះបានកើតឡើង ដោយសារកំណើនថ្លៃដំឡូងមីនៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០០៨។ ការឆ្លើយតបយ៉ាងច្រើនបែបនេះបង្ហាញថា កម្ពុជាមានសក្តានុពលក្នុងការបង្វែរដីដែលនៅទំនេរ ឱ្យទៅជា

---

[៤២] Chandararot, Kang, Sok Sina and Liv Dannet. Rapid Assessment of the Impact of the Financial Crisis in Cambodia. Bangkok: ILO Subregional Office for East Asia, 2009.

ដីផលិតកម្ម។ បើទោះជាមានការធ្លាក់ចុះគំហុកនៃថ្លៃដំឡូវមីនៅក្នុងឆមាសទីពីរឆ្នាំ២០០៨ ក៏ដោយ កសិករជាច្រើនដែលមានដីតិចតួច នៅតែបន្តដាំដំណាំនេះ នៅក្នុងត្រីមាសទីពីរឆ្នាំ២០០៩ ដោយសារថ្លៃដំឡូងមីបានកើនឡើងមកវិញបន្តិចម្តងៗមកដល់ប្រមាណ ៦០% នៃ កម្រិតថ្លៃនៅក្នុងខែឧសភាឆ្នាំ២០០៨។

កសិករដាំកៅស៊ូ កំពុងជួបប្រទះនូវផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច។ ក្រោយពីបានទទួលផលចំណេញនៅក្នុងរយៈពេលប្រាំបីខែដំបូង នៃឆ្នាំ២០០៨ នៅពេលដែលថ្លៃកៅស៊ូកើនឡើងជាខ្លាំង កសិករដាំកៅស៊ូបានរងការប៉ះទង្គិច ចាប់តាំងពីពេលនោះមក ដោយសារការធ្លាក់ចុះជាគំហុកនៃថ្លៃកៅស៊ូពីខ្ពស់ជាង ៣.០០០ ដុល្លារក្នុងមួយតោន មកត្រឹមទាបជាង ៩០០ ដុល្លារក្នុងមួយតោន។ នៅឆ្នាំ២០០៩ អ្នកផលិតបានចាប់ផ្តើមទទួលផលចំណេញតែកាលណាថ្លៃលក់ បានវិលមកប្រមាណ ១.៥០០ ដុល្លារក្នុងមួយតោន ប៉ុណ្ណោះ ដែលជាថ្លៃត្រឹមពាក់កណ្តាលនៃថ្លៃនៅឆ្នាំមុន។

កសិករជាច្រើនដែលធ្វើស្រែប្រាំងកំពុងបង់ខាត តាមទម្រង់ដូចគ្នានឹងកសិករដាំដំឡូងមី និងកៅស៊ូដែរ។ ពួកគេបានចំណាយខ្ពស់សម្រាប់ការផលិត ប៉ុន្តែអាចលក់ផលិតផលរបស់ពួកគេបានក្នុងតម្លៃទាប។ ការអង្កេតនៅតំបន់តូចមួយក្នុងខេត្តកំពង់ធំបានរកឃើញថា កសិករភាគច្រើន ដែលធ្វើស្រែប្រាំងនៅក្នុងទំនាបលិចទឹកបឹងទន្លេសាប ក៏ខាតបង់ផងដែរនៅឆ្នាំ២០០៩។[៤៣]

## ប្រអប់ទី ៩. អ្នកដាំដំឡូងមី

គារ មានអាយុ ៤០ ឆ្នាំ និងរស់នៅក្នុងភូមិពន្លឺថ្មី ឃុំអូរអោម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ នៅក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ គាត់បានដាំដំឡូងមីនៅលើផ្ទៃដីប្រាំមួយហិកតា។ ផលចំណូលពីដំឡូងមី បានជួយគាត់ឱ្យរក្សាជីវភាពគ្រួសារនេះ នៅក្នុងកម្រិតសមរម្យមួយ ដោយអាចសន្សំប្រាក់បានខ្លះៗជារៀងរាល់ឆ្នាំ ក៏ដូចជាទុកបម្រុងដើមទុនខ្លះសម្រាប់ចំការដំឡូងមីផងដែរ។

នៅពេលដែលថ្លៃចំណិតដំឡូងមីធ្លាក់ចុះពី ៧៣០ រៀល ក្នុងមួយគីឡូក្រាម នៅឆ្នាំ២០០៧ មកត្រឹម ២៥០ រៀល នៅចុងឆ្នាំ២០០៨ វាបានធ្វើឱ្យគាត់បាត់បង់ប្រាក់ចំណេញទាំងអស់ ដោយអាចបំពេញបានត្រឹមតែថ្លៃផលិតតែប៉ុណ្ណោះ។ ចាប់ពីឆ្នាំ២០០៨ មកទល់នឹងដើមឆ្នាំ២០០៩ គ្រួសារនេះបានរស់នៅដោយពឹងផ្អែកលើប្រាក់ ដែលគាត់បានសន្សំពីមុនមក។

បញ្ហា គឺស្ថិតលើការចំណាយសម្រាប់ការដាំដុះសាឡើងវិញ។ ដើម្បីដាំនៅលើដីនោះ គារ ត្រូវបង្ខំចិត្តចងការប្រាក់។ គាត់បានខ្ចីប្រាក់ពីធនាគារអេស៊ីលីដា ប៉ុន្តែគាត់អាចខ្ចីត្រឹមតែគ្រប់គ្រាន់សម្រាប់តម្លៃនៃវត្ថុដែលគាត់អាចបញ្ចាំប៉ុណ្ណោះ ដែលអាចគ្រប់គ្រាន់សម្រាប់ដាំដុះលើផ្ទៃដីបីហិកតាតែប៉ុណ្ណោះ។ គាត់បានជួលដីដែលនៅសល់បីហិកតាទៅអ្នកភូមិម្នាក់ទៀត ជាថ្នូរនឹងប្រាក់មួយលានរៀល។

គាត់ពោលថា គាត់នឹងបន្តដាំដំឡូងមី ដោយសង្ឃឹមថាថ្លៃដំឡូងនឹងកើនឡើងវិញ នៅពេលដែលសេដ្ឋកិច្ចពិភពលោកងើបឡើងវិញ។ គាត់គិតថា រដ្ឋាភិបាលគួរតែប្រឹងប្រែងបន្ថែមទៀត ក្នុងការរក្សាថ្លៃផលិតផលកសិកម្មឱ្យនៅខ្ពស់ ដើម្បីការពារកសិករ។

*ប្រភព : ការសម្ភាសដោយ UNDP នៅថ្ងៃទី ១២-១៨ ខែឧសភា ឆ្នាំ២០០៩*

[៤៣] Does large-scale agricultural investment benefit the poor? Phnom Penh: Cambodian Economic Association (forthcoming).

### ៤.១.៥ កម្មករចំណាកស្រុកកម្ពុជា

វិបត្តិសេដ្ឋកិច្ចសព្វថ្ងៃនេះ ទំនងជាធ្វើឱ្យមានកំណើនចំណាកស្រុកនៅក្នុងប្រទេស ដោយសារតែចំនួនច្រើននៃការបាត់បង់ការងារ។ ដូចបានពិភាក្សានៅក្នុងផ្នែក ៤.២.១ កម្មករចំណាកស្រុក បានផ្តល់ប្រាក់ចំណូលទៅជនបទតាមរយៈប្រាក់ដែលផ្ញើទៅផ្ទះ។ ប៉ុន្តែ លំហូរប្រាក់ទាំងនេះនឹងធ្លាក់ចុះ ស្របជាមួយកំណើនភាពគ្មានការងារធ្វើ និងកម្មករទទួលប្រាក់កម្រៃកាន់តែទាប។

## ការធ្វើចំណាកស្រុកនៅក្នុងប្រទេស

ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ដោយស្ថិតក្រោមការទាក់ទាញពីការរំពឹងថា នឹងទទួលបានការងារដែលផ្តល់ប្រាក់កម្រៃខ្ពស់ និងរបៀបរស់នៅប្រសើរក្នុងទីប្រជុំជននានា និងសម្រួលដោយអវត្តមានការងារពេញមួយឆ្នាំនៅក្នុងភូមិកំណើតយុវជនកម្ពុជាបានផ្លាស់ទីមកក្រុងភ្នំពេញ និងទីក្រុងដទៃទៀត ដើម្បីធ្វើការនៅក្នុងរោងចក្រកាត់ដេរដែលរីកដុះដាលជាបន្តបន្ទាប់ ការដ្ឋានសំណង់ដែលលូតលាស់យ៉ាងខ្លាំង និងឧស្សាហកម្មដែលទាក់ទងនឹងទេសចរណ៍។ នៅមុនពេលដែលវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោកប៉ះទង្គិចលើកម្ពុជា កម្មករប្រមាណ ៣៦០.០០០ នាក់ ដែលភាគច្រើនជាយុវតី បានធ្វើការនៅក្នុងរោងចក្រកាត់ដេរនៅជុំវិញក្រុងភ្នំពេញ កម្មករ ២៧០.០០០នាក់ ដែលភាគច្រើនជាយុវជនក្មេងៗ បានទទួលប្រាក់ចំណូលពីការដ្ឋានសំណង់នៅទូទាំងប្រទេស និង ៧០.០០០ នាក់ ផ្សេងទៀតបានចូលធ្វើការនៅក្នុងឧស្សាហកម្មដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍។ គេពុំមានតួលេខជាក់លាក់អំពីថា តើកម្មករចំណាកស្រុកទាំងនេះប៉ុន្មាននាក់ ដែលបានផ្ញើប្រាក់ទៅផ្ទះជារៀងរាល់ខែនោះទេ ប៉ុន្តែការសិក្សាមួយ ដោយ CDRI បានរកឃើញថា ពួកគេចំនួន ៩៣% បានផ្ញើប្រាក់ទៅផ្ទះ។[៤៤] មានការប៉ាន់ប្រមាណថា ជាមធ្យម កម្មករចំណាកស្រុកម្នាក់ ផ្ញើប្រាក់ទៅផ្ទះប្រមាណ ២០ ដុល្លារក្នុងមួយខែ។

ផ្អែកតាមតួលេខទាំងនេះ កម្មករចំណាកស្រុកក្នុងប្រទេស បញ្ជូនទៅផ្ទះប្រមាណ ១៥០ លានដុល្លារក្នុងមួយឆ្នាំ ទៅទីជនបទកម្ពុជា ឬប្រមាណ ៨% នៃប្រាក់ចំណូលសរុបរបស់គ្រួសារនៅជនបទ។ ដោយសារវិបត្តិនេះ ប្រាក់ដែលបញ្ជូនទៅផ្ទះបានធ្លាក់ចុះ។ មានការប៉ាន់ប្រមាណថា កម្មករដែលបាត់បង់ការងារប្រមាណពី ២០-៣០% នៅក្នុងរោងចក្រកាត់ដេរ ការដ្ឋានសំណង់ និងឧស្សាហកម្មទេសចរណ៍ កំពុងធ្វើឱ្យខាតបង់រវាង ៣០-៤៥ លានដុល្លារ ដែលជាប្រាក់ផ្ញើទៅគ្រួសារនៅជនបទ។

## ការធ្វើចំណាកស្រុកទៅបរទេស

ដូចជាការធ្វើចំណាកស្រុកនៅក្នុងប្រទេសដែរ ជនកម្ពុជាយ៉ាងច្រើនធ្វើចំណាកស្រុកទៅប្រទេសថៃ ម៉ាឡេស៊ី និងកូរ៉េ។ ប្រទេសថៃគឺជាទីដៅដែលពេញនិយមជាងគេសម្រាប់ជនចំណាកស្រុកកម្ពុជា ដែលគ្មានឯកសារត្រឹមត្រូវ ដោយសារការត្រួតពិនិត្យនៅតាមព្រំដែនដែលមានភាពធូររលុង ឬដែលគ្មានការត្រួតពិនិត្យ។ កម្មករចំណាកស្រុកពីកម្ពុជាដែលគ្មានឯកសារត្រឹមត្រូវ នៅក្រៅប្រទេស និងដែលត្រូវបានប៉ាន់ស្មានថាមានចំនួនពី ២០០.០០០-២២០.០០០ នាក់ បានផ្ញើប្រាក់ប្រមាណ ៣០០ លានដុល្លារ[៤៥] មកកម្ពុជាក្នុងមួយឆ្នាំៗ។ គេមានការព្រួយបារម្ភជាលើកដំបូងថា អ្នកទាំងនោះភាគច្រើន ត្រូវបានបង្ខំឱ្យវិលត្រឡប់មកផ្ទះវិញ ដោយសារតែផលវិបាកដោយផ្ទាល់នៃវិបត្តិនេះ ដើម្បីផ្តល់ការងារដល់កម្មករថៃនៅក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT), មានតែភាគរយតិចតួចនៃអ្នកទាំងនោះប៉ុណ្ណោះ ដែលកំពុងវិលត្រឡប់មកផ្ទះវិញ ដោយសារតែពួកគេតាមធម្មតា ធ្វើការនៅក្នុងអ្វីដែលគេហៅថាការងារ '3D' (លំបាក គ្រោះថ្នាក់ និងប្រកបដោយគ្រោះថ្នាក់) ដែលភាគច្រើនកម្មករថៃមិនធ្វើទេ។ សូម្បីតែមានកម្មករត្រឹមមួយចំនួនតូច កំពុងវិលត្រឡប់មកផ្ទះវិញក៏ដោយ ប្រាក់ដែលផ្ញើមកពីប្រទេសថៃ ត្រូវបានរំពឹងថានឹងថយចុះ ដោយសារអ្នកដែលបន្តធ្វើការនៅក្នុងប្រទេសថៃ នឹងរកប្រាក់ចំណូលបានតិចជាងមុន។ ជនចំណាកស្រុកនានា ក៏ទំនងជានឹងចាប់ផ្តើមវិលត្រឡប់មកវិញផងដែរ ដោយសាររដ្ឋាភិបាលនៅក្នុងតំបន់នេះ ផ្តោតលើការជួលពលករក្នុងស្រុក។

---

៤៤ Lim, Sovannara. "Youth Migration and Urbanization in Cambodia" (Working Paper 36). Phnom Penh: CDRI, 2007, 27.

៤៥ Ratha, Dilip and Zhimei Xu, eds. *Migration and Remittances Factbook 2008*. Washington, DC: World Bank, 2008. http://siteresources.worldbank.org/INTPROSPECTS/Resources/334934-1199807908806/Cambodia.pdf, 19 March 2008. Web. 1 June 2009.

*តារាងទី ១១. កម្មករចំណាកស្រុកពីកម្ពុជា ដែលបានបញ្ជូនជាផ្លូវការទៅក្រៅប្រទេសចាប់ពីឆ្នាំ១៩៩៨*

| | ម៉ាឡេស៊ី | | | កូរ៉េ | | | ថៃ[៤៦] | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ប | ស | សរុប | ប | ស | សរុប | ប | ស | សរុប | ប | ស |
| ១៩៩៨ | ១២០ | ០ | ១២០ | .. | .. | .. | .. | .. | .. | ១២០ | ០ | ១២០ |
| ១៩៩៩ | ៨៦ | ០ | ៨៦ | .. | .. | .. | .. | .. | .. | ៨៦ | ០ | ៨៦ |
| ២០០០ | ៥០២ | ៣០៧ | ១៩៥ | .. | .. | .. | .. | .. | .. | ៥០២ | ៣០៧ | ១៩៥ |
| ២០០១ | ៨៤៦ | ៣៤២ | ៥០៤ | .. | .. | .. | .. | .. | .. | ៨៤៦ | ៣៤២ | ៥០៤ |
| ២០០២ | ១.០៤៩ | ២៤៦ | ៨០៣ | .. | .. | .. | .. | .. | .. | ១.០៤៩ | ២៤៦ | ៨០៣ |
| ២០០៣ | ៥៧៣ | ៧៣ | ៥០០ | ៧៥៦ | ៦៣៨ | ១១៨ | .. | .. | .. | ១.៣២៩ | ៧១១ | ៦១៨ |
| ២០០៤ | ៨០៩ | ១០៥ | ៧០៤ | ៦៧៥ | ៥១៩ | ១៥៥ | .. | .. | .. | ១.៤៨៣ | ៦២៤ | ៨៥៩ |
| ២០០៥ | ១.៧៧៦ | ៤៦៧ | ១.៣០៩ | ៤៦៨ | ៤៣២ | ៣៦ | .. | .. | .. | ២.២៤៤ | ៨៩៩ | ១.៣៤៥ |
| ២០០៦ | ១.៦៩០ | ២៣១ | ១.៤៥៩ | ១.៥០១ | ១.៣៤១ | ១៦០ | ៤៤៥ | ២២៦ | ២១៩ | ៣.៦៣៦ | ១.៧៩១ | ១.៨៤៥ |
| ២០០៧ | ៣.២១៩ | ១៧៤ | ៣.០៤៥ | ៥៨៤ | ៤៩៩ | ៨៥ | ៥.៦៧០ | ៣.៩៣៥ | ១.៧៣៥ | ៩.៤៧៣ | ៤.៦០៨ | ៤.៨៦៥ |
| ២០០៨ | ២.៦៥៤ | ៥៣ | ២.៦០១ | .. | .. | .. | ២.១១៦ | ១.៤២៥ | ៦៩១ | ៤.៧៧០ | ១.៤៧៨ | ៣.២៩២ |
| សរុប | ១៣.៣២៤ | ១៩៩៨ | ១១.៣២៦ | ៣.៩៨៤ | ៣.៤២៩ | ៥៥៤ | ៨.២៣១ | ៥.៥៨៦ | ២.៦៤៥ | ២៥.៥៣៨ | ១១.០១៣ | ១៤.៥២៥ |

*ប្រភព : MoLVT*

ការធ្វើចំណាកស្រុកទៅក្រៅប្រទេស មានកម្រិតតិចតួចនៅក្នុងឆ្នាំ២០០៩ នេះ ដោយសារប្រទេសជាទីដៅកំពុងស្ថិតក្រោមសម្ពាធឱ្យបង្កើតការងារធ្វើសម្រាប់កម្មករនៅក្នុងស្រុករបស់ខ្លួន ។ ការធ្វើការងារបន្ថែមម៉ោងនៅក្នុងរោងចក្រ ដែលជាប្រភពបឋមនៃប្រាក់ចំណូលបន្ថែមសម្រាប់ជនចំណាកស្រុក ត្រូវបានរាយការណ៍ថាបានថយចុះជាច្រើន ។ សន្តិសុខ និងបរិយាកាសខាងផ្លូវច្បាប់ កាន់តែមានភាពតឹងរឹងសម្រាប់ជនចំណាកស្រុក ដែលចូលទៅក្នុងប្រទេសថៃដោយល្មើសច្បាប់ ។ រហូតដល់ខែធ្នូ ឆ្នាំ២០០៨ មានតែកម្មករចំណាកស្រុកចំនួន ៨.២៣១ ប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនជាផ្លូវការទៅក្នុងប្រទេសថៃ ក្នុងខណៈដែលប្រមាណ ១៨០.០០០ នាក់ ចូលទៅក្នុងប្រទេសថៃដោយល្មើសច្បាប់ ។

នៅដើមឆ្នាំ២០០៩ ចំនួនកម្មករដែលបានបញ្ចប់កិច្ចសន្យាការងារ ឬដែលផុតសុពលភាពទិដ្ឋាការ និងដែលត្រូវតែវិលត្រឡប់មកពីប្រទេសម៉ាឡេស៊ីវិញ មានចំនួន ៦.០០០ នាក់ កូរ៉េខាងត្បូង ចំនួន ៣.៥០០ នាក់ និងថៃ ៣.០០០ នាក់ ។ តាមធម្មតា មានការបញ្ជូនកម្មករចំណាកស្រុកថ្មីៗទៅប្រទេសទាំងនេះ ប៉ុន្តែប្រការនេះមិនបានកើតឡើងឡើយនៅក្នុងឆ្នាំនេះ ។ ដូច្នេះ ការរំពឹងទុកអំពីការងារនៅក្រៅប្រទេស និងប្រាក់ផ្ញើមកផ្ទះវិញនៅឆ្នាំ២០០៩ មិនមានសញ្ញាវិជ្ជមានឡើយ ។

## ៤.២ ជនរងគ្រោះលំដាប់ទីពីរ

ជនរងគ្រោះនៅលំដាប់ទីពីរ សំដៅលើអ្នកដែលរងផលប៉ះពាល់បណ្តាលពីការពឹងផ្អែកលើអ្នកដែលរងគ្រោះដោយផ្ទាល់ពីវិបត្តិ និងអ្នកដែលមានភារៈត្រូវផ្តល់ការគាំទ្រដល់ជនរងគ្រោះនៅលំដាប់ទីមួយ ។ តាមរយៈមេគុណ និងឥទ្ធិពលនៃការពឹងផ្អែកលើគ្នាទៅវិញទៅមក ផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច បានបន្តពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។ ផលប៉ះពាល់ដោយផ្ទាល់មកលើក្រុមប្រជាពលរដ្ឋដែលរងគ្រោះនៅលំដាប់ទីមួយ ធ្វើឱ្យការចិញ្ចឹមជីវិតរបស់អ្នកដែលពឹងផ្អែកលើពួកគេកាន់តែយ៉ាប់យ៉ឺន ។ ជាក់ស្តែង កម្មកររោងចក្រកាត់ដេរដែលបាត់បង់ការងារ គឺជាជនរងគ្រោះនៅលំដាប់ទីមួយពីវិបត្តិសេដ្ឋកិច្ច ចំណែកគ្រួសាររបស់ពួកគេដែលទទួលប្រាក់មកពីអ្នកទាំងនោះ ឬដែល

[៤៦] គួរកត់សំគាល់ថា កម្មករជាច្រើននាក់ពុំមានឯកសារសំគាល់ខ្លួនឡើយ ហើយតួលេខពិតប្រាកដអាចមានជិតដល់ ១៨០.០០០ នាក់ ចាប់ពីឆ្នាំ១៩៩៨ មក ។

ឥឡូវនេះ ត្រូវទំនុងបម្រុងអ្នកទាំងនោះថែមទៀត ក៏រងផលប៉ះពាល់អវិជ្ជមានផងដែរ ដែលជាផលវិបាកមួយ និងត្រូវបានចាត់ទុកថាជាជនរងគ្រោះនៅលំដាប់ទីពីរ ។ មួយភាគធំនៃការប៉ាន់ប្រមាណដូចខាងក្រោមនេះ គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ តែមិនមែនជាការសន្និដ្ឋានអ្វីឡើយ ។

### ៤.២.១ គ្រួសារកសិករដែលទទួលប្រាក់ផ្ញើមកផ្ទះតិចជាងមុន និងជនចំណាកស្រុកដែលវិលត្រឡប់មកផ្ទះវិញ

ការថយចុះនៃបរិមាណប្រាក់ផ្ញើមកផ្ទះដែលបញ្ជូនពីទីក្រុងមកជនបទ ដោយសារតែវិបត្តិសេដ្ឋកិច្ច អាចមានន័យថា ជាការថយចុះនៃការវិនិយោគលើសម្ភារៈនៅក្នុងផលិតកម្មកសិកម្មដូចជាជី ។នៅពេលដែលកសិករមិនទំនងជាប្រើប្រាស់ជី ផលិតផលកសិកម្មរបស់ពួកគេក៏នឹងអាចធ្លាក់ចុះផងដែរ ។ លើសពីនេះ អត្រានៃការប្រើប្រាស់ក៏ទំនងជាធ្លាក់ចុះផងដែរ ។ ដោយកម្មកររោងចក្រកាត់ដេរភាគច្រើនបានផ្ញើប្រាក់មកផ្ទះជាមធ្យមរវាង ២០-៤០ ដុល្លារក្នុងមួយខែ ដើម្បីជួយទ្រទ្រង់គ្រួសារនៅក្នុងភូមិតាមជនបទ សព្វថ្ងៃនេះ គ្រួសារជាច្រើននឹងត្រូវរស់នៅដោយគ្មានការផ្គត់ផ្គង់ខាងផ្នែកហិរញ្ញវត្ថុបែបនេះឡើយ ។ របាយការណ៍ពីអង្គការមិនមែនរដ្ឋាភិបាល (NGOs) និងMFIs នានាបង្ហាញថា គ្រួសារជាច្រើនកំពុងស្នើសុំពន្យារពេលក្នុងការសងបំណុល ហើយ NPLs បានកើនឡើងពីកម្រិតទាបបំផុតរហូតដល់ ២,៥% ។ ប្រសិនបើស្ថានភាពនេះមិនប្រសើរឡើងនៅក្នុងពេលឆាប់ៗខាងមុខទេនោះ ការជាប់បំណុលនឹងបង្កើតឱ្យមានសម្ពាធកាន់តែខ្លាំងឡើងមកលើគ្រួសារនានានៅជនបទ ហើយ MFIs នឹងប្រឈមជាមួយការលំបាកយ៉ាងខ្លាំងខាងហិរញ្ញវត្ថុ ។ អង្គការ សេដាក ដែលជា NGO កម្ពុជាមួយ ដែលជួយបង្កើតក្រុមកសិករ ៥.000 គ្រួសារ បានរាយការណ៍ថា គ្រួសារកសិករមួយចំនួនបានប្រឈមនឹងកង្វះមូលនិធិដើម្បីបង្កើតជំនួញខ្នាតតូច ដោយសារប្រាក់ដែលសមាជិកគ្រួសាររបស់ពួកគេដែលធ្វើការនៅក្រុងភ្នំពេញត្រូវផ្ញើមកឱ្យនោះ លែងមានជាបន្តទៀតហើយ ។

ការប្រឈមមួយផ្សេងទៀត គឺការវិលត្រឡប់នៃកម្មករដែលបាត់បង់ការងារមកភូមិកំណើតនៅជនបទវិញ ។ សំណាងល្អ ជនចំណាកស្រុកកម្ពុជានៅក្នុងប្រទេសថៃបន្តធ្វើការជាធម្មតា ដូច្នេះជាការកំហិតលើផលប៉ះពាល់នៃវិបត្តិនេះបានមួយកម្រិត ។ ទោះជាយ៉ាងណាក៏ដោយ ជនចំណាកស្រុកកំពុងប្រឈមនឹងការលំបាកច្រើនឡើងៗ ដូចជាការព័ទ្ធចាប់ដោយនគរបាលថៃលើការធ្វើចំណាកស្រុកល្មើសច្បាប់ និងការថយចុះវត្តមាននៃការងារបន្ថែមម៉ោង ។

### ៤.២.២ កុមារក្នុងគ្រួសារក្រីក្រ

វិបត្តិស្បៀង និងឥន្ធនៈកាលពីឆ្នាំទៅ គួបផ្សំនឹងវិបត្តិសេដ្ឋកិច្ចសព្វថ្ងៃ បាននាំឱ្យមានផលប៉ះពាល់មកលើកុមារក្នុងគ្រួសារក្រីក្រភាគច្រើនតាមរយៈការប្រែប្រួលរបបអាហារូបត្ថម្ភការចូលរៀន និងការទទួលយកយុទ្ធសាស្ត្រដោះស្រាយផលអវិជ្ជមានពីសំណាក់គ្រួសារនានាដូចជា ពលកម្មកុមារ និងការលក់ទ្រព្យ ដែលជាមធ្យោបាយផលិតកម្ម ។ នៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង វាអាចមានឥទ្ធិពលអវិជ្ជមានមកលើពលកម្មកុមារ ។

ការសិក្សាមនុស្សមាត្រនៅកម្ពុជាក្នុងពេលថ្មីៗនេះ (CAS) ដែលបានធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២00៨ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រោមការគាំទ្រពី UNICEF និង UNDP បង្ហាញថា ថ្លៃស្បៀងខ្ពស់នៅក្នុងឆ្នាំ២00៨ មានឥទ្ធិពលយ៉ាងច្រើនមកលើរបបអាហារូបត្ថម្ភរបស់កុមារ ។ ជាក់ស្តែង ការសិក្សារបស់ CAS បានរកឃើញថា អត្រាសុខភាពខ្សោយ ក្នុងចំណោមកុមារក្រីក្រនៅទីក្រុងមានកម្រិតខ្ពស់ "ប្រកាសអាសន្ន" និងបានកើនឡើងច្រើនជាង ៦% ដែលជាកំណើនពី ៩,៦% នៅឆ្នាំ២00៥ ដល់ ១៥,៩% នៅក្នុងឆ្នាំ២00៨ ពោល គឺកំណើនហួសកម្រិតមូលដ្ឋាន ១៥% នៃអត្រាសុខភាពខ្សោយរបស់កុមារសម្រាប់ "ការប្រកាសអាសន្នខាងមនុស្សធម៌" និងទាមទារឱ្យមានការឆ្លើយតបជាបន្ទាន់នៅក្នុងទីក្រុងនានា ។ ការសិក្សានេះ បានរាយការណ៍អំពីអវត្តមាន កំណែលម្អអត្រាទូទៅនៃអត្រាសុខភាពខ្សោយរបស់កុមារ និងកុមារមិនគ្រប់ទម្ងន់នៅក្នុងរវាងឆ្នាំ២00៥ និង ២00៨ ។

បើទោះជាភាពក្រីក្រត្រូវបានគូសបញ្ជាក់ថា ជាកត្តាហានិភ័យសំខាន់មួយនៃកង្វះអាហារូបត្ថម្ភ ហើយភាគរយនៃកុមារស្គម មិនគ្រប់ទម្ងន់ និងតឿ មានកម្រិតខុសៗគ្នាទៅតាមកម្រិតទ្រព្យធននៃគ្រួសារក៏ដោយ ក្នុងចំណោមក្រុមគ្រួសារអ្នកមានធនធានច្រើនជាងគេ ក៏បានប្រទះឃើញមានកំណើនអត្រាកង្វះអាហារូបត្ថម្ភផងដែរ សម្រាប់គ្រប់សូចនាករទាំងបីអំពីកង្វះ អាហារូបត្ថម្ភ។ នៅពេលប្រៀបធៀបទៅនឹងកម្រិតរំពឹងទុកនៃក្រុមប្រជាពលរដ្ឋដែលមានសុខភាពល្អ ក្រុមអ្នកមានធនធានច្រើនជាងគេចំនួន ២0% នៃជនកម្ពុជា មានកុមារតឿក្នុងអត្រាច្រើនជាងដប់ពីរដង ខ្ពស់ជាងអត្រាធម្មតា (២៨,៦%) ច្រើនជាងប្រាំបីដង ជាកុមារដែលមិនគ្រប់ទម្ងន់ (១៩,៣%) និងអត្រាបួនដង ច្រើនជាងជាកុមារស្គម (៨,៩%)។ ប្រការនេះបង្ហាញថា ប្រាក់កាស ឬសមត្ថភាពដើម្បីទិញអាហារ មិនមែនជាកត្តាសំខាន់តែមួយគត់នៃអាហារូបត្ថម្ភនោះទេ។ កត្តាសំខាន់ៗផ្សេងទៀត ដែលមានឥទ្ធិពលមកលើកង្វះអាហារូបត្ថម្ភ រួមមាន របៀបនៃការផ្ដល់អាហារដល់កុមារ និងការថែទាំកុមារផងដែរ។

យុទ្ធសាស្ត្រដោះស្រាយដែលគ្រួសារនានាប្រកាន់យក គឺជាមូលហេតុនៃការព្រួយបារម្ភ។ ការកាត់បន្ថយថ្លៃចំណាយសម្រាប់ការថែទាំសុខភាព និងលើការអប់រំ អាចមានផលវិបាករយៈពេលវែងលើការលូតលាស់របស់កុមារ និងសក្ដានុពលរបស់មនុស្ស។ យុទ្ធសាស្ត្រដែលអនុវត្តទូទៅជាងគេ ទំនងជាពាក់ព័ន្ធបំផុតជាមួយស្បៀងអាហារ។ គ្រួសារចំនួនពីរក្នុងចំណោមបីគ្រួសារបានរាយការណ៍ថា ពឹងផ្អែកលើអាហារដែលមិនសូវថ្លៃ និងមិនសូវជាទីចូលចិត្ត។ យុទ្ធសាស្ត្រផ្សេងទៀត រួមបញ្ចូលការកាត់បន្ថយចំនួនពេលញ៉ាំអាហារក្នុងមួយថ្ងៃ ការដាក់កំហិតបរិមាណអាហារសម្រាប់មនុស្សពេញវ័យ និងការទិញជំពាក់។ ក្រៅពីយុទ្ធសាស្ត្រដែលទាក់ទងនឹងស្បៀងអាហារ យុទ្ធសាស្ត្រដែលមានអនុវត្តទូទៅជាងគេ ដែលមិនទាក់ទងនឹងស្បៀងអាហារ គឺការកាត់បន្ថយចំណាយលើសុខភាព និងការអប់រំ ការស្វែងរកការងារជំនួស ការបញ្ជូនកូនទៅធ្វើការ និងការលក់ទ្រព្យសកម្មរបស់គ្រួសារ។ យុទ្ធសាស្ត្រទាំងនេះ អាចបង្កជាឥទ្ធិពលប្រកបដោយគ្រោះថ្នាក់មកលើសុខុមាលភាពរបស់កុមារ តាមរយៈការប្រែប្រួលអវិជ្ជមាននៃអាហារូបត្ថម្ភ កំណើនអត្រាបោះបង់ចោលសាលារៀន និងការងាយធ្លាក់ខ្លួនឈឺ។ ផលប៉ះពាល់បែបនេះមកលើសុខភាព និងអាហារូបត្ថម្ភរបស់កុមារ អាចមានរយៈពេលវែង ដែលជាការរារាំងដល់ការលូតលាស់របស់ពួកគេ និងសក្ដានុពលសម្រាប់ជាមូលធនមនុស្សទៅអនាគត។

## ៤.២.៣ ជនក្រីក្រ និងជិតក្រីក្រ ដែលមានសព្វថ្ងៃនៅតាមទីក្រុង

ជនក្រីក្រ និងជនជិតធ្លាក់ខ្លួនក្រ បាន និងកំពុងរងផលប៉ះពាល់អវិជ្ជមានបណ្ដាលពីការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅកម្ពុជា។ ជនក្រីក្រ និងជនដែលជិតធ្លាក់ខ្លួនក្រមួយចំនួននៅក្នុងទីក្រុង គឺជាអ្នកលក់បាយ និងអាហារផ្សេងទៀតទៅដល់កម្មករកាត់ដេរ។ ដោយសារស្ថានភាពជាក់ស្ដែងដែលមានរោងចក្រចំនួន៥0 បានបិទទ្វារបណ្ដាលពីវិបត្តិនេះ មុខជំនួញតូចៗជាច្រើនដែលលក់ចំណីអាហារសម្រាប់កម្មករទាំងនោះ បានរងគ្រោះយ៉ាងធ្ងន់ធ្ងរ។ នៅក្នុងខេត្តសៀមរាប ដែលពឹងផ្អែកជាខ្លាំងលើអ្នកទេសចរណ៍ ផលប៉ះពាល់ដោយផ្ទាល់មកលើជនក្រីក្រ និងក្រុមជនជិតធ្លាក់ខ្លួនក្រីក្រនៅទីក្រុង បានបង្ហាញឃើញយ៉ាងច្បាស់។ អ្នករត់រឺម៉ក អ្នករត់ ម៉ូតូឌុប និងអ្នកលក់ចំណីតាមរទេះរុញបានរាយការណ៍អំពីការធ្លាក់ចុះយ៉ាងច្រើននូវប្រាក់ចំណូលរបស់ខ្លួន។ ផលប៉ះពាល់អវិជ្ជមាននេះ ក៏ត្រូវបានរកឃើញក្នុងចំណោមអ្នករុញរទេះដែលជាទូទៅជាជនក្រីក្រនៅប៉ោយប៉ែត ដែលជាទីក្រុងពាណិជ្ជកម្មធំជាងគេ នៅតាមព្រំដែនកម្ពុជាជាមួយប្រទេសថៃផងដែរ។ ពួកគេបានរាយការណ៍អំពីការធ្លាក់ចុះយ៉ាងច្រើននូវផលិតផលនាំចូល ដែលអាចត្រូវការដឹកជញ្ជូនតាមរទេះ។ ពាណិជ្ជករនៅក្នុងទីក្រុងនេះបានអះអាងថា ពួកគេលក់ដូរត្រឹមតែក្នុងកម្រិត ៥0% នៃអ្វីដែលពួកគេធ្វើកាលពីមួយឆ្នាំមុនតែប៉ុណ្ណោះ។ អ្នកតំណាងមួយរូបមកពីក្រុមហ៊ុនលក់ផលិតផលសំអាងដែលមានមូលដ្ឋាននៅក្នុងក្រុងភ្នំពេញ ដែលបានធ្វើដំណើរឆ្លងកាត់ទីក្រុងពាណិជ្ជកម្មនេះ ក៏បានអធិប្បាយអំពីការធ្លាក់ចុះ ៥0% នៃផលិតផលនាំចូល និងការលក់ទំនិញផងដែរ។ ភាពងាយរងគ្រោះនៃកុមារនៅក្នុងគ្រួសារទាំងនេះ ក្នុងការបោះបង់ចោលសាលារៀន និងចាប់ផ្ដើមស្វែងរកការងារធ្វើ ក៏មានកម្រិតខ្ពស់ផងដែរ។

## ប្រអប់ទី ៦. កម្មករនៅទីក្រុង

ក្នុងពេលដែលរោងចក្រនៅក្បែរខាងបានបិទទ្វារ ហើយកម្មករខ្លះបានចាកចេញ យុវតីអាយុ ១៩ ឆ្នាំ មួយរូបឈ្មោះ ស្រី នាង ដែលលក់ផលិតផលសំអាងទៅឱ្យកម្មការិនីរោងចក្រនៅក្នុងឃុំដង្កោ ក្រុងភ្នំពេញ អាចរកប្រាក់ចំណូលត្រឹមតែ ៤០% នៃអ្វីដែលនាងធ្លាប់រកបានកាលពីឆ្នាំទៅ។ មុខរបររបស់នាងបានត្រឹមតែមួយគ្រប់៧ប៉ុណ្ណោះ។ ជាលទ្ធផល នាងត្រូវតែកាត់បន្ថយការចំណាយសម្រាប់គ្រួសារ។ ដោយព្រួយបារម្ភថាមិនអាចបង់ថ្លៃជួលទៅអនាគត នាងបានអំពាវនាវឱ្យមានការបើកទ្វាររោងចក្រឡើងវិញ។

ស្ត្រីអាយុ ២៦ ឆ្នាំ មួយរូប ដែលលក់ផ្លែឈើនៅមុខរោងចក្រមួយ ដែលសព្វថ្ងៃមានកម្មករតិចជាងមុនកំពុងធ្វើការបានរាយការណ៍អំពីការលក់ដែលមានត្រឹមតែ ៦០% នៃអ្វីដែលគាត់បានលក់កាលពីមួយឆ្នាំមុន។ គាត់ត្រូវកាត់បន្ថយការចំណាយប្រចាំគ្រួសារ និងបានសុំឱ្យសមាជិកដទៃទៀតក្នុងគ្រួសារស្វែងរកការងារធ្វើ ដោយសារគាត់អាចរកប្រាក់ចំណេញបានតិចតួចពេក។ គាត់ចង់ប្តូរទៅលក់គ្រឿងទេស ប៉ុន្តែបានពោលថា កង្វះដើមទុនគឺជាឧបសគ្គ។

*ប្រភព : ការសម្ភាសដោយ UNDP នៅថ្ងៃទី ១២-១៨ ខែឧសភា ឆ្នាំ២០០៩*

### ៤.២.៤ គ្រួសារដែលគ្មានដីធ្លី

គ្រួសារដែលគ្មានដីធ្លីដែលមានប្រមាណ២០% នៃគ្រួសារនៅជនបទមានភាពងាយរងគ្រោះដោយសារពួកគេពុំមានដីធ្លីដើម្បីដាំដំណាំ និងជាញឹកញាប់ ពុំមានប្រាក់ដើម្បីជួលដីសម្រាប់ដាំដំណាំឡើយ។ ក្នុងខណៈដែលពួកគេធ្វើចំណាកស្រុក និងអាចរកប្រាក់កម្រៃប្រចាំថ្ងៃ ពួកគេកំពុងព្រួយមទឹងតម្រូវការពលករដែលកាន់តែតិចជាងមុនជាខ្លាំង ឧទាហរណ៍ ស៊ីឈ្នួលរានដី។ អ្នកគ្មានដីធ្លីនៅជនបទ ត្រូវតែពឹងផ្អែកលើសកម្មភាពជាច្រើនសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន។ ដោយសារតែសកម្មភាពសេដ្ឋកិច្ចបាន ធ្លាក់ចុះជាច្រើននៅក្នុងឆ្នាំ២០០៩ ឱកាសរបស់ពួកគេក្នុងការរកប្រាក់ចំណូល ដើម្បីទិញអាហារកាន់តែមានកម្រិតកំណត់។ ជម្រើសចុងក្រោយមួយគឺការធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីរកការងារធ្វើ។ ប៉ុន្តែ វត្តមានការងារធ្វើនៅក្នុងប្រទេសថៃ មិនទំនងជានឹងកើនឡើងឡើយ។ អាស្រ័យហេតុនេះ ប្រជាពលរដ្ឋទំនងជាបំពេញបន្ថែមលើប្រាក់ចំណូលទាបរបស់ពួកគេ ដោយប្រើប្រាស់ប្រាក់ដែលពួកគេសន្សំបាន រហូតដល់ពេលដែលសេដ្ឋកិច្ចចាប់ផ្តើមរីកចម្រើនឡើងវិញ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងតំបន់ដទៃទៀតនៃប្រទេសកម្ពុជា ដែលមានដីសំបូរជីជាតិ និងដែលទើបតែបើកចំហសម្រាប់ផលិតកម្ម តម្រូវការកម្លាំងពលកម្មមិនបានធ្លាក់ចុះឡើយ បើទោះជាមានត្រឹមតែតាមរដូវក្តី ដែលដោយសារតែមានប្រព័ន្ធស្រោចស្រក្នុងកម្រិតកំណត់។ កន្លែងដែលនៅតែត្រូវការកម្លាំងពលករនៅឡើយ រួមមាន ខេត្តមណ្ឌលគិរីនៅជិតប្រទេសវៀតណាម និងទីរួមស្រុកនានានៅក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ នៅជិតប្រទេសថៃ។

ផ្នែកខ្លះៗនៃខេត្តមណ្ឌលគិរី គឺជាតំបន់ដីក្រហម សំបូរដោយជីជាតិ និងសម្រាប់ដំណាំជាច្រើនមុខ។ ដោយសារកង្វះកម្លាំងពលករ (យោងតាមការជំរឿនប្រជាជនឆ្នាំ២០០៨ ខេត្តមណ្ឌលគិរីមានដង់ស៊ីតេប្រជាជនទាបជាងគេនៅកម្ពុជា ដោយមានត្រឹមតែ ៤ នាក់ប៉ុណ្ណោះក្នុងមួយគីឡូម៉ែត្រការ៉េ) ពលករដែលគ្មានជំនាញអាចរកប្រាក់បានដល់ ៥ ដុល្លារ ក្នុងមួយថ្ងៃ ធៀបនឹង ៣ ដុល្លារ ដែលជាកម្រិតចំណូលរកបាននៅក្នុងតំបន់ភាគច្រើនក្នុងប្រទេសកម្ពុជា (យោងតាមការសិក្សានៅតាមមូលដ្ឋាន ដែលបានធ្វើឡើងសម្រាប់ការសិក្សានេះ និងតាមរយៈការអង្កេតមួយនៅថ្នាក់ជាតិអំពីគ្រួសារនានា)។[៤៧] កម្មករនៅក្នុងខេត្តមណ្ឌលគិរី ភាគច្រើនជាអ្នកមកពីខេត្តដទៃ ដែលរួមទាំងខេត្តព្រៃវែង កំពង់ចាម និងស្វាយរៀង ដែលជាខេត្តសំបូរកម្លាំងពលករជាបង្គួរ។ ទោះជាយ៉ាងណាក៏ដោយលំហូរ ឬការធ្វើចំណាកស្រុកបែបនេះនៃកម្លាំងពលកម្ម ត្រូវជួបឧបសគ្គដោយសារកង្វះការចែករំលែកព័ត៌មាន ដែលមានការចាត់ចែងត្រឹមត្រូវ។ បណ្តាញមិនផ្លូវការ និងការបន្តព័ត៌មានពីមាត់មួយទៅមាត់មួយ នៅតែជាមធ្យោបាយដ៏មានសារៈសំខាន់ សម្រាប់ការប្រាស្រ័យឆ្លើយឆ្លងអំពីទីផ្សារពលកម្មនៅជនបទ។

[៤៧] Chan, Sophal. "The Impact of High Food Prices". Annual Development Review 2008-09. Phnom Penh: CDRI, 2009.

## ៤.៣ កាត់បន្ថយផលប៉ះពាល់មកលើប្រជាពលរដ្ឋ តាមរយៈកិច្ចការពារសង្គម

កិច្ចការសង្គម ដែលរួមទាំងបណ្តាញសុវត្ថិភាពសង្គម ផ្តល់នូវការគាំទ្រយ៉ាងសំខាន់ដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះ និងដែលកំពុងប្រឈមជាមួយការប៉ះទង្គិចខ្លាំងក្លា ដូចជា វិបត្តិសេដ្ឋកិច្ចពិភពលោក។ គោលគំនិតអំពីកិច្ចការពារសង្គម ដែលរួមទាំងបណ្តាញសុវត្ថិភាពសង្គម មិនមែនជារឿងថ្មីឡើយនៅកម្ពុជា។ អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ បណ្តាញសុវត្ថិភាពសង្គម ភាគច្រើនមានវត្តមានតាមរយៈសហគមន៍ គ្រួសារ និងវត្តអារាម ដែលជួយកាត់បន្ថយផលប៉ះពាល់បណ្តាលពីការប៉ះទង្គិចជាច្រើន។ នៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ទាំងនៅក្នុងស្រុក និងអន្តរជាតិ បានអនុវត្តកម្មវិធីបណ្តាញសុវត្ថិភាពសង្គមកាន់តែច្រើនឡើង។ បើគិតអំពីវិធានការជាផ្លូវការ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត ច្បាប់ស្តីពីសន្តិសុខសង្គម នៅក្នុងឆ្នាំ២០០២ និងនៅឆ្នាំ២០០៨ បានបង្កើតមូលនិធិជាតិសន្តិសុខសង្គម (NSSF) ដែលមានគោលដៅ ផ្តល់ ដូចជាប្រាក់សោធននិវត្តន៍ដល់មន្ត្រីស៊ីវិល និងនៅពេលថ្មីៗជាងនេះទៀត ការផ្តល់ប្រាក់សម្រាប់អ្នករងរបួសនៅក្នុងពេលធ្វើការ ប្រាក់សោធនសម្រាប់ការបាត់បង់សមត្ថភាពពលកម្ម និងសម្រាប់ការបណ្តុះបណ្តាល។ ទោះជាយ៉ាងណាក៏ដោយ វិធានការផ្លូវការនៅមានកម្រិតកំណត់នៅឡើយ ហើយវិធានការមិនផ្លូវការ មានដាច់ដោយដុំតែប៉ុណ្ណោះ។ ទាក់ទងនឹងយន្តការដោះស្រាយ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកនេះ ជាពិសេស សម្រាប់ជនរងគ្រោះនៅលំដាប់ទីមួយ និងទីពីរ ដែលបានធ្វើអត្តសញ្ញាណនៅក្នុងផ្នែក ៤.១ និង ៤.២ កម្ពុជាមានសក្តានុពល ដើម្បីទទួលផលពីប្រព័ន្ធការពារសង្គមមួយ ដែលមានលក្ខណៈរួមបញ្ចូល និងកាន់តែអភិវឌ្ឍជាងមុន។

កិច្ចការពារសង្គម នៅក្នុងន័យទូលាយ ត្រូវបានឱ្យនិយមន័យថាជា ការចាត់ចែង និងបរិធានមួយឈុត ដែលអាចឱ្យប្រជាជនគ្រប់គ្រងហានិភ័យ និងការប៉ះទង្គិចនានា និងធានាឱ្យមានការប្រើប្រាស់នៅកម្រិតជាមូលដ្ឋាន។ បរិធាននានា ត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ និងដើម្បីសម្រួលឱ្យមានកំណើនសេដ្ឋកិច្ច។ នៅក្នុងក្របខ័ណ្ឌធំទូលាយនេះ មានផ្នែករងចំនួនបួនដែលរួមមាន :

i) ការផ្ទេរក្នុងក្របខ័ណ្ឌសង្គមទៅឱ្យអ្នកក្រ និងក្រុមជនងាយរងគ្រោះ (បណ្តាញសុវត្ថិភាពសង្គម ដែលមិនទាមទារឱ្យមានវិភាគទាន) ដូចជា សាច់ប្រាក់នៅក្រោមលក្ខខណ្ឌ ប្រព័ន្ធការងារសាធារណៈដែលផ្អែកលើពលកម្ម និងស្បៀងពលកម្ម។

ii) វិធានការជាផ្លូវការខាងសន្តិសុខសង្គម (តាមធម្មតាដែលតម្រូវឱ្យបង់វិភាគទាន) ដូចជា ប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីស៊ីវិល និងការធានារ៉ាប់រងសុខភាព។

iii) បទប្បញ្ញត្តិ និងច្បាប់នានា ដែលពាក់ព័ន្ធនឹងកិច្ចការពារសង្គម (ដូចជា បទប្បញ្ញត្តិអំពីទីផ្សារពលកម្ម) និង

iv) យន្តការមិនផ្លូវការលើកិច្ចការពារ/សាមគ្គីភាពក្នុងសង្គម (ផ្អែកលើគ្រួសារ សហគមន៍ និង/ឬវត្តអារាម)។

### ៤.៣.១ វិធានការដែលមានស្រាប់

យោងតាមរបាយការណ៍របស់ ADB ស្តីពីកិច្ចការពារសង្គមសម្រាប់ប្តេជ្ញាកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋប្រមាណ ២ លាននាក់ បានទទួលផលពីជំនួយផ្នែកសង្គម (បណ្តាញសុវត្ថិភាពសង្គម) នៅកម្ពុជា ក្នុងឆ្នាំ២០០៧។ តារាងខាងក្រោមនេះ ផ្តល់ជាទិដ្ឋភាពរួមអំពីគម្រោងធំៗ ដែលភាគច្រើនមានចែងអំពីបណ្តាញសុវត្ថិភាពសង្គម ប៉ុន្តែក៏មានផងដែរអំពីកិច្ចការពារសង្គម ដែលរួមទាំងការធានារ៉ាប់រងខាងសុខភាព និង NSSF។ ការធ្វើសារពើភ័ណ្ឌដែលមានលក្ខណៈទូលំទូលាយជាងនេះ អំពីវិធានការនានាដែលមានស្រាប់ត្រូវបានចុះផ្សាយដោយក្រុមការងារបណ្តោះអាសន្នមួយ ស្តីពីបណ្តាញសុវត្ថិភាពសង្គមក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ តារាងនេះបង្ហាញថា មានកម្មវិធីជាច្រើនដែលកំពុងអនុវត្ត ប៉ុន្តែការគិតគូរអំពីផ្នែកនេះ នៅតែមានដាច់ដោយដុំតែប៉ុណ្ណោះ។

*តារាងទី ១២. សារពើភ័ណ្ឌនៃគម្រោងការពារសង្គម*

| កម្មវិធីការពារសង្គម | ក្រសួងរបស់រដ្ឋាភិបាល/ដៃគូអភិវឌ្ឍន៍ | ការផ្តល់មូលនិធិ (ក្នុងករណីមានតួលេខ) | ចំណុចដៅ |
|---|---|---|---|
| គម្រោងជំនួយស្បៀងបន្ទាន់ | MEF, ADB | ៤០ លានដុល្លារ (ប្រមាណជាពាក់កណ្តាលសម្រាប់វិធានការការពារសង្គម) ២០០៨-២០១០ | ៧ ខេត្ត នៅជុំវិញបឹងទន្លេសាប (ពីដំបូង) រួមមានការផ្តល់អង្ករដោយឥតគិតថ្លៃអាហារសម្រាប់សិស្ស ប្រាក់កម្រៃពលកម្ម ស្បៀងពលកម្ម ឧបត្ថម្ភធនដល់សម្ភារៈកសិកម្ម |
| ស្បៀងពលកម្ម | WFP, MRD, MoWRAM (និង ADB) | ៣,៧ លានដុល្លារ (WFP) | អង្ករ ៣.៥០០ តោនផ្តល់ឱ្យ ១១៣.៨០៨ គ្រួសារ |
| អាហារសម្រាប់សិស្ស | WFP, MoEYS | ៨,៩ លានដុល្លារ | កុមារ ៤៧០.៧០៩ នាក់ |
| មូលនិធិសមធមិសម្រាប់ការថែទាំសុខភាព | MoH, NGOs ក្នុងស្រុក | ៦ លានដុល្លារ (រដ្ឋាភិបាល)<br>៧ លានដុល្លារ (ដៃគូអភិវឌ្ឍន៍) | មណ្ឌលសុខភាពចំនួន ៤៧ ត្រូវបានធ្វើអត្តសញ្ញាណតាមរយៈការធ្វើអត្តសញ្ញាណជនក្រីក្រ (IDPoor) |
| ការធានារ៉ាប់រងសុខភាពតាមរយៈសហគមន៍ (CBHI) | NGOs ចំនួន ៥ និង MoH | - | អ្នកទទួលផលចំនួន ៧៥.០០០ នាក់ នៅក្នុងខេត្តចំនួន ៦ |
| ប្រព័ន្ធសុខភាពមាតា និងកុមារ | WFP, MoH | ២,៧ លានដុល្លារ | អ្នកទទួលផល ៥៧.៣០៦ នាក់ |
| កម្មវិធីកុមារមានជីវិត | UNICEF | ៣,៦ លានដុល្លារ | - |
| អាហារូបករណ៍សម្រាប់សិស្សក្រីក្រ | MoEYS, WFP | - | កុមារថ្នាក់មធ្យមសិក្សាចំនួន ២១.៤៥៩ នាក់ ជាពិសេស កុមារី ដោយ MoEYS និងអាហារយកទៅផ្ទះ ដោយ WFP (៥៥.០០០ នាក់) |
| មូលនិធិជាតិសន្តិសុខសង្គម | MoSAVY, MoLVT | - | សម្រាប់គ្រោះថ្នាក់ក្នុងការងារ ការធានារ៉ាប់រងសុខភាព សោធននិវត្តន៍។ មន្ត្រីស៊ីវិលចូលនិវត្តន៍ចំនួន ២២.០០០ នាក់ |
| មូលនិធិជាតិបណ្តុះបណ្តាលវិជ្ជាជីវៈ | MoLVT | ៦,៥ លានដុល្លារ (២០០៩) | សំដៅជាបឋម ប៉ុន្តែមិនមែនសម្រាប់តែកម្មករកាត់ដេរ ដែលបាត់បង់ការងារទេ (សរុបចំនួន ៤០.០០០ នាក់)* |
| ពលកម្មកុមារ | ILO, MLVT, និយោជក, សហជីពកម្មករ | ៤,៥១ លានដុល្លារ (ILO) សម្រាប់រយៈពេលពីខែកញ្ញា ២០០៤ ដល់ខែកញ្ញា ២០០៨ និង ៤,៣១ លានដុល្លារ បន្ថែម (ILO) សម្រាប់រយៈពេលពីខែកញ្ញា ២០០៨ ដល់ខែកញ្ញា ២០១២ | ១៥ ខេត្ត ដែលផ្តោតលើពលកម្មកុមារ និងគ្រួសាររបស់ពួកគេ ក៏ដូចជាកសាងសមត្ថភាព តស៊ូមតិ កសាងចំណេះដឹង ។ល។ |
| ប្រាក់កម្រៃការងារ | ILO, ADB | ៤,៨ លានដុល្លារ (ILO) រវាងឆ្នាំ២០០៦-២០០៨ | ហេដ្ឋារចនាសម្ព័ន្ធជនបទ "អ្នកគ្មានដីធ្លី និងកសិករនៅរដូវខ្វះខាត" |

*UNDP Cambodia 2009 ។ តួលេខនេះសម្រាប់ឆ្នាំ២០០៨ លើកលែងតែមានការបញ្ជាក់ ។*

*ប្រភព : សង្ខេបដោយអ្នកនិពន្ធ (សូមមើលឧបសម្ព័ន្ធ ៣)*

* *ភ្ជាប់ជាមួយប្រការនេះ គឺកិច្ចផ្តួចផ្តើម UN-MoLVT នៅពេលខាងមុខ ដើម្បីបង្កើតបណ្តាញមជ្ឈមណ្ឌលការងារនៅទូទាំងប្រទេសកម្ពុជា ។ បណ្តាញនេះនឹងត្រូវបង្កើតឡើងដើម្បីជួយដោះស្រាយតម្រូវការជាបន្ទាន់លើបញ្ហាការងារ និងការបណ្តុះបណ្តាល នៅក្នុងអំឡុងពេលមានវិបត្តិ និងការប្រឈមខាងរចនាសម្ព័ន្ធសម្រាប់រយៈពេលវែង នៅក្នុងទីផ្សារពលកម្ម ដែលរួមទាំង ភាពដាច់គ្នារវាងតម្រូវការ និងការផ្គត់ផ្គង់ជំនាញ និងភាពមិនគ្រប់គ្រាន់នៃសេវាកម្មការងារដែលមានស្រាប់ ។*

## ៤.៣.២ ការចំណាយរបស់រដ្ឋាភិបាលលើបណ្តាញសុវត្ថិភាពសង្គម

ការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើបណ្តាញសុវត្ថិភាពសង្គមមានកម្រិតទាបបំផុត ក្នុងចំណោមប្រទេសនានានៅក្នុងតំបន់ ពោល គឺតិចជាង ១% នៃ GDP ។ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅក្នុងតំបន់ មានអត្រានៃការចំណាយ រវាង ១ និង ២% នៃ GDP ។

ទាក់ទងនឹងការចំណាយលើកិច្ចការសង្គមទូទៅ និងមិនត្រឹមតែការចំណាយលើបណ្តាញសុវត្ថិភាពសង្គមប៉ុណ្ណោះទេ ក្រសួងដែលមានចំណាយច្រើនជាងគេចំនួនពីរ គឺក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSAVY) និង MoLVT ។ ទោះជាយ៉ាងណាក៏ដោយ ស្ទើរតែគ្រប់ស្ថាប័នរបស់រដ្ឋាភិបាលមានការចំណាយខ្លះៗ លើវិស័យដែលទាក់ទងនឹងកិច្ចការពារសង្គម ។ ថវិកាសម្រាប់ការចំណាយសរុបរបស់ក្រសួងសង្គមកិច្ចលើកិច្ចការសង្គម បានកើនឡើង ០,៥% នៅរវាងឆ្នាំ២០០៤ និង ២០០៩ ដល់ ៣,១% នៃ GDP ។ ការទទួលបានតួលេខពិតប្រាកដស្តីពីការចំណាយរបស់រដ្ឋាភិបាល និងអំពីកិច្ចការពារសង្គម និងជាពិសេស អំពីបណ្តាញសុវត្ថិភាពសង្គម និងការប្រៀបធៀបនៅកម្រិតតំបន់មានការលំបាក ដោយសារការចំណាយបែបនេះ មាននៅទូទាំងក្រសួងខុសៗគ្នា ក៏ដូចជាការប្រែប្រួលទៅតាមរចនាសម្ព័ន្ធថវិកាសព្វថ្ងៃ និងការប្រឈមក្នុងការកំណត់ អំពីអ្វីគួរតែគិតបញ្ចូល និងអ្វីដែលមិនគួរគិតបញ្ចូលផងដែរ ។

*រូបទី ១៣. និន្នាការនៃការចំណាយរួមសម្រាប់វិស័យសង្គម (ភាគរយនៃ GDP)*




*ប្រភព : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសូចនាករអភិវឌ្ឍន៍ពិភពលោក*

## ៤.៣.៣ ការប្រឈមនៅក្នុងកិច្ចការពារសង្គម

ដើម្បីប្រើប្រាស់កិច្ចការពារសង្គម ដែលរួមទាំងបណ្តាញសុវត្ថិភាពសង្គម ដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងដើម្បីសម្រេចផលប្រយោជន៍រយៈពេលវែង កម្ពុជាបានប្រឈមនឹងការលំបាកជាបឋមចំនួនពីរ គឺ i) ការប្រឈមលើនិរន្តរភាពនៃហិរញ្ញប្បទាន និងធនធាន និង ii) ការប្រឈមខាងប្រតិបត្តិការ ដែលរួមទាំងសមត្ថភាពខាងសារពើពន្ធ ដែលមានកម្រិតកំណត់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ជាពិសេស ការប្រឈម រួមមាន ការធ្វើអត្តសញ្ញាណ និងការផ្តោតឱ្យចំអ្នកទទួលផលជាក់លាក់ ការធ្វើឱ្យដៃគូនានាចូលរួមនៅក្នុងចំណោមមហាជន ការលេចធ្លាយដែលអាចកើតមាននៅក្នុងប្រព័ន្ធនេះ ការសម្រេចបាននូវវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស ការតាមដាននិងវាយតម្លៃលទ្ធផលនានា និងការផ្តល់សេវាកម្មប្រកបដោយគុណភាព ដូចជា ការអប់រំ និងសុខភាព ។

បើគិតអំពីការផ្ទេរសាច់ប្រាក់ទៅតាមលក្ខខណ្ឌវិញ ដែលអ្នកទទួលផលទទួលបានសាច់ប្រាក់ ទៅតាមលក្ខខណ្ឌនៃការបំពេញតាមការតម្រូវខ្លះៗ ប្រព័ន្ធធនាគាររបស់កម្ពុជា នៅមានភាពទន់ខ្សោយនៅឡើយ។ សាច់ប្រាក់ត្រូវតែអាចផ្ទេរបានដោយងាយស្រួល ហើយបញ្ហាសន្តិសុខត្រូវតែធានាឱ្យបាន។ លក្ខខណ្ឌនានា ត្រូវតែមានភាពយុត្តិធម៌ និងសមហេតុផល ងាយស្រួលតាមដាន និងទាមទារឱ្យមានការផ្តល់នូវសេវាកម្មប្រកបដោយគុណភាពខ្ពស់ក្នុងពេលជាមួយគ្នាផងដែរ។ គេអាចរៀនសូត្របានពីការអនុវត្តល្អៗនៅកម្រិតអន្តរជាតិ ដែលរួមទាំង Opportunidades នៅប្រទេសម៉ិកស៊ិក និង Red de Proteccion Social នៅប្រទេសនីការ៉ាហ្គា ផងដែរ។

ស្បៀងពលកម្ម ឬប្រាក់កម្រៃពលកម្ម (ប្រាក់កម្រៃការងារ) ត្រូវតែផ្តល់ឱ្យទៅតាមអត្រាប្រាក់ឈ្នួលសមស្រប ដែលត្រូវកំណត់ឱ្យទាបជាងអត្រាប្រាក់ឈ្នួលនៅលើទីផ្សារ។ ប្រព័ន្ធប្រាក់កម្រៃការងារនេះ ផ្តោតលើការងារដែលផ្តល់ផលកម្រៃដល់អ្នកដែលអនុវត្តសម្រាប់ជាប្រយោជន៍ខ្លួនឯងផ្ទាល់ និងដែលផ្តល់ផលក្នុងកម្រិតខ្ពស់ ប៉ុន្តែក៏អាចមិនបង្កលទ្ធភាពឱ្យក្រុមងាយរងគ្រោះមួយចំនួនបានចូលរួមផងដែរ ដូចជា ក្រុមដែលមិនមានសុខភាពមាំមួន ឬដែលបាត់បង់សមត្ថភាពពលកម្ម។ ក្រុមទាំងនេះ គួរតែជាគោលដៅសម្រាប់ការប្រើប្រាស់ប្រព័ន្ធជំនួសវិញ។ ក្នុងពេលដែលដោះស្រាយដោយផ្ទាល់ ចំពោះការប្រឈមនានានៃកង្វះអាហារូបត្ថម្ភនៅកម្ពុជា ការផ្តល់ស្បៀងជួបនឹងការប្រឈមនៃការប្រែប្រួលថ្លៃអាហារ ដូចបានឃើញច្បាស់នៅពេលមានវិបត្តិថ្លៃអាហារក្នុងឆ្នាំ២០០៨។ ការផ្តល់ស្បៀងអាចថាមានការលំបាកខ្លាំង និងក៏ជួបបញ្ហានានា ដែលទាក់ទងនឹងនិរន្តរភាព និងការផ្តោតឱ្យចំគោលដៅផងដែរ។

# V កាត់បន្ថយផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ច



មានយុទ្ធសាស្ត្រចំបង១ចំនួនបី ដែលអ្នកកសាងគោលនយោបាយអាចពិចារណា ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅកម្ពុជា ពោល គឺ i) **ការបង្កើតប្រព័ន្ធចម្រុះរបស់ជាតិ**សម្រាប់ការពារសង្គម ii) ការធ្វើអត្តសញ្ញាណ**កម្មវិធីចំណាយសម្រាប់វិស័យសាធារណៈប្រកបដោយប្រសិទ្ធភាព** ដោយផ្តោតលើសមធម៌នៃការទទួល និង iii) **កំណែទម្រង់រចនាសម្ព័ន្ធ**នៅក្នុងវិស័យនានា ដូចជា សមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច ការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច និងកសិកម្ម ដោយផ្តោតលើការស្តារឡើងវិញរយៈពេលវែង និងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ។ ការពិចារណាខាងគោលនយោបាយទាំងនេះ ត្រូវបានដកស្រង់ចេញពីការវិភាគពីមុន១មក និងអាទិភាពនៃការអភិវឌ្ឍ ដែលមានការចងក្រងបានច្បាស់លាស់រួចមកហើយ។

## ៥.១ ការបង្កើតប្រព័ន្ធចម្រុះមួយរបស់ជាតិសម្រាប់ការពារសង្គម

ផ្នែក ៤.៣ បានបង្ហាញអំពីថា តើកម្មវិធីការពារសង្គមមានអត្ថិភាពដោយរបៀបណា និងដែលមានដាច់ដោយដុំ ព្រមទាំងមិនសុទ្ធតែមានការសម្របសម្រួលបានល្អឡើយ។ ដើម្បីកែលម្អគោលនយោបាយការពារសង្គម សព្វថ្ងៃនេះ កម្ពុជាកំពុងបង្កើតប្រព័ន្ធចម្រុះមួយរបស់ជាតិនៃបណ្តាញសុវត្ថិភាពសង្គម និងសន្តិសុខសង្គម តាមរយៈដំណើរការផ្លូវការមួយ ដែលបានផ្តួចផ្តើមនៅដើមឆ្នាំ២០០៩ តាមការស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅខែកក្កដា ឆ្នាំ២០០៩ វេទិកាពិគ្រោះយោបល់មួយ ត្រូវបានរៀបចំឡើង និងមានការចូលរួមពីអ្នកពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលនាំឱ្យមានការពិភាក្សាទូលាយមួយជាមួយស្ថាប័នពាក់ព័ន្ធនានា ដែលរួមទាំងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនផងដែរ។ នៅក្នុងវេទិកានោះ មានការឯកភាពគ្នា ដើម្បីឱ្យដាក់បញ្ចូលកិច្ចការពារសង្គម ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់ឆ្នាំ២០០៩-២០១៣ ដែលជាការបង្ហាញពីអាទិភាពខ្ពស់ ដែលរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចំពោះគោលនយោបាយការពារសង្គម ជាការឆ្លើយតបទៅនឹងវិបត្តិ និងដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គមសម្រាប់រយៈពេលវែង។

រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងបង្កើតយុទ្ធសាស្ត្រមួយនៅចុងឆ្នាំ២០០៩ ដែលគួរតែនាំទៅរកការអភិវឌ្ឍប្រព័ន្ធចម្រុះមួយរបស់ជាតិសម្រាប់ការពារសង្គម នៅក្នុងប្រទេសកម្ពុជា។ នេះជាឱកាសដ៏មានប្រយោជន៍ ដើម្បីរួមចំណែកស្តារសេដ្ឋកិច្ច និងស្ថិរភាពសម្រាប់រយៈពេលវែង និងដើម្បីកែលម្អសូចនាករអភិវឌ្ឍន៍មនុស្ស ដូចជាការកាត់បន្ថយភាពក្រីក្រ ការអប់រំ សុខភាព និងយេនឌ័រ និងការរីកចម្រើនឈានទៅ CMDGs រហូតដល់ឆ្នាំ២០១៥។

ប្រព័ន្ធបណ្តាញសុវត្ថិភាពសង្គមដែលបង្កើតបានល្អ អាចកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច មកលើជនរងគ្រោះនៅលំដាប់ទីមួយ និងលំដាប់ទីពីរ បណ្តាលពីវិបត្តិ ដូចដែលបានធ្វើអត្តសញ្ញាណនៅក្នុងផ្នែកទី៤។ ជនរងគ្រោះនៅលំដាប់ទីមួយ ដែលជាកម្មករបាត់បង់ការងារ រួមទាំង កម្មករកាត់ដេរ កម្មករសំណង់ និងកម្មករក្នុងឧស្សាហកម្មទេសចរណ៍ ក៏ដូចជាអ្នកដែលនៅកំពុងមានការងារធ្វើនៅឡើយ ប៉ុន្តែរកបានប្រាក់ចំណូលតិចជាងមុន អាចទទួលផលពីប្រព័ន្ធមួយ ដែលធានាឱ្យមានស្តង់ដារជាមូលដ្ឋាននៃការរស់នៅ កែលម្អសន្តិសុខខាងប្រាក់ចំណូល និងសន្តិសុខស្បៀង និងអាចឱ្យប្រជាពលរដ្ឋពុះពារចំពោះហានិភ័យបាន។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចដែលផ្តល់ដោយ MoLVT គឺជាឧទាហរណ៍មួយនៃជំនួយដោយផ្ទាល់ដល់កម្មករដែលបាត់បង់ការងារ និងដែលផ្តល់ប្រយោជន៍ភ្លាម១ ទៅឱ្យជនរងគ្រោះនៅលំដាប់ទីមួយ និងអាចបង្កើតឡើងនៅក្នុងប្រព័ន្ធចម្រុះផ្លូវការមួយ ដែលមានវិសាលភាពគ្របដណ្តប់នៅទូទាំងប្រទេស។ ការសិក្សារបស់ UNIAP ដែលអង្កេតលើកម្មករក្នុងវិស័យ សេវាកម្មកំសាន្តចំនួន ៣៥៧ នាក់ បានបង្ហាញថា ពួកគេមានជម្រើសការងារកាន់តែតិចជាងមុន ហើយការជាប់បំណុលក៏កាន់តែមានច្រើនផងដែរ ក្នុងចំណោមមនុស្សនៅក្នុងក្រុមនេះ។ វិធានការសម្រាប់ការពារសង្គម

ក៏អាចយកមកប្រើប្រាស់ជាយន្តការមួយ ដើម្បីផ្តល់ជម្រើសដល់ប្រជាពលរដ្ឋផងដែរ ក្នុងពេលដែលជម្រើសនានា កំពុងតែរួមតូចដោយសារតែវិបត្តិនេះ។

ចំពោះជនរងគ្រោះនៅលំដាប់ទីពីរ ដែលបានធ្វើអត្តសញ្ញាណនៅក្នុងរបាយការណ៍នេះថា ជាអ្នកដែលពឹងផ្អែកលើប្រាក់ផ្ញើមកផ្ទះ ដូចជា កុមារ ជនក្រីក្រ និងអ្នកក្របណ្តោះអាសន្ន និងគ្រួសារដែលគ្មានដីធ្លី ពួកគេអាចនឹងកាត់បន្ថយការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយអវិជ្ជមាននានា ប្រសិនបើមានប្រព័ន្ធបណ្តាញសុវត្ថិភាពសង្គមមួយល្អ។ ឧទាហរណ៍នានា អំពីយុទ្ធសាស្ត្រប្រកបដោយគ្រោះថ្នាក់ទាំងនេះ រួមមាន ការលក់ទ្រព្យសកម្មសម្រាប់ការផលិត ការបញ្ឈប់កូនពីសាលា និងការខ្ចីបំណុល ក៏ដូចជាការធ្វើឱ្យខ្លួនឯងកាន់តែងាយរងគ្រោះពីការជួញដូរមនុស្សផងដែរ។ កំណើនយុទ្ធសាស្ត្រដោះស្រាយអវិជ្ជមានដែលទាក់ទងនឹងស្បៀងអាហារ ត្រូវបានធ្វើអត្តសញ្ញាណដោយ CAS ដែលរួមទាំងការកាត់បន្ថយបរិមាណអាហារ និងការបរិភោគអាហារដែលមិនសូវថ្លៃ និងដែលជាអាហារខ្លួនមិនសូវចូលចិត្ត។ លើសពីនេះ កំណើនភាពស្គមស្គាំងក្នុងចំណោមកុមារក្រីក្រនៅទីក្រុង គឺជាមូលហេតុធ្ងន់ធ្ងរដែលគួរឱ្យព្រួយបារម្ភ។ កំណើនអសន្តិសុខស្បៀងជាពិសេស សម្រាប់កុមារ អ្នកក្របណ្តោះអាសន្ន និងគ្រួសារគ្មានដីធ្លី ដែលពុំមានលទ្ធភាពប្រើប្រាស់ដីធ្លីសម្រាប់ជាបណ្តាញសុវត្ថិភាព បានបង្ហាញពីតម្រូវការជាបន្ទាន់ឱ្យដោះស្រាយភាពងាយរងគ្រោះ និងហានិភ័យនានា តាមរយៈវិធានការនៃកិច្ចការពារសង្គម ដូចជាការផ្ទេរសាច់ប្រាក់ ការផ្ទេរជំនួយមិនមែនសាច់ប្រាក់ និងប្រាក់កម្រៃពលកម្ម។

ដើម្បីដោះស្រាយបានទូលំទូលាយ និងដោយសមធម៌ នូវបណ្តាញនៃភាពងាយរងគ្រោះ និងការប្រឈមនានា អ.ស.ប នៅកម្ពុជាសូមធ្វើការគាំទ្រឱ្យមានប្រព័ន្ធចម្រុះ និងពេញលេញមួយរបស់ជាតិសម្រាប់ការពារសង្គម។ ដើម្បីឱ្យប្រព័ន្ធបែបនេះ បានទទួលជោគជ័យ អ្នកកសាងគោលនយោបាយនានា ត្រូវតែដោះស្រាយការប្រឈមនានា ដូចមានចែងនៅក្នុងផ្នែក ៤.៣។ លើសពីនេះ :

- ត្រូវប្រកាន់ខ្ជាប់ជាប្រចាំនូវ**ការប្តេជ្ញា និងការដឹកនាំម៉ឺងម៉ាត់** ប្រសិនបើចង់ឱ្យប្រព័ន្ធនោះ មាននិរន្តរភាពខាងហិរញ្ញវត្ថុ និងបង្កើតឡើងតាមទម្រង់ដែលស៊ីចង្វាក់គ្នា។
- ដោយសារកម្មវិធីនានាដែលមានស្រាប់ មានលក្ខណៈដាច់ពីគ្នាដោយដុំ គេគួរតែបង្កើតឱ្យមាន**ជនបង្គោល និងទីភ្នាក់ងារកណ្តាល**ដែលមានអាណត្តិច្បាស់លាស់ ដើម្បីសម្របសម្រួលរវាងក្រសួងនានា។

## ៥.២ កម្មវិធីចំណាយសម្រាប់វិស័យសាធារណៈប្រកបដោយប្រសិទ្ធភាព និងផ្តោតលើសមធម៌

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការឆ្លើយតបយ៉ាងឆាប់រហ័ស ទៅនឹងផលប៉ះពាល់អវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ចពិភពលោក។ បើគិតអំពីគោលនយោបាយសារពើពន្ធ រាជរដ្ឋាភិបាលកម្ពុជាកំពុងប្រឈមនឹងឱនភាពថវិកាជាច្រើនរហូតដល់ ៤,៨% នៃ GDP នៅក្នុងឆ្នាំ២០០៩ ហើយបានចាត់ទុកគោលនយោបាយនេះថា ជាទម្រង់មួយនៃកញ្ចប់កិច្ចផ្តួចផ្តើមសម្រាប់ជម្រុញឱ្យមានចំណាត់ការ។ លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជា បានព្យួរទុកនូវការយកពន្ធប្រចាំខែចំនួន ១% ពីការចំណាយរបស់រោងចក្រកាត់ដេរ និងបានពន្យារការអនុគ្រោះពន្ធលើប្រាក់ចំណេញសម្រាប់រោងចក្រនានា ដែលបានបង្កើតឡើងនៅមុនឆ្នាំ២០០៦។ នៅក្នុងខែឧសភា ឆ្នាំ២០០៩ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ រដ្ឋាភិបាលបានផ្តល់សាច់ប្រាក់ចំនួន ១៨ លានដុល្លារ ក្រោមទម្រង់ជាប្រាក់កំចី ទៅរោងម៉ាស៊ីនកិនស្រូវមួយចំនួន ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេក្នុងការទិញ និងកិនស្រូវ។

មានការលើកស្នើថា រដ្ឋាភិបាលគួរតែបន្តប្រើប្រាស់គោលនយោបាយសារពើពន្ធ ជាឧបករណ៍មួយ ដើម្បីដោះស្រាយទាំងភាពងាយរងគ្រោះរយៈពេលខ្លី និងដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចរយៈពេលវែងផងដែរ ដោយផ្តោតលើលទ្ធភាពទទួលបានផលដោយសមធម៌ពីកម្មវិធីចំណាយសម្រាប់វិស័យសាធារណៈ។ រាជរដ្ឋាភិបាលមានប្រាក់សន្សំប្រមាណ ៦០០ លានដុល្លារ ឬត្រូវជា ៦% នៃ GDP ដូច្នេះ វាផ្តល់ឱ្យរដ្ឋាភិបាលនូវលទ្ធភាពយ៉ាងច្រើនក្នុងការលៃលក ដើម្បីបន្តពង្រីកប្រព័ន្ធសារពើពន្ធឱ្យមានសមធម៌។ ក្នុងខណៈដែលមានការព្រួយបារម្ភថា កំណើនការចំណាយសម្រាប់វិស័យសារធារណៈ អាចបង្កឱ្យប្រាក់រៀលធ្លាក់ថ្លៃ និងនាំឱ្យមានអតិផរណាកម្រិតខ្ពស់ផងដែរនោះ ការចំណាយដែលផ្តោតចំគោលដៅ និងដែលផ្តល់ផលបានល្អ វានឹងមិនបង្កឱ្យមានអតិផរណាខ្ពស់ជាងមុនឡើយ។ ការគំរាមកំហែងពីអតិផរណាអាចនឹងកាត់បន្ថយបានជាបន្ថែមទៀត ដោយសារតែកម្ពុជាមានរបបគ្រប់គ្រងសាច់ប្រាក់អណ្តែត (សេរី) ហើយមកទល់ពេលនេះ មានសមត្ថភាពធ្វើអន្តរាគមន៍ ដើម្បីឱ្យអត្រាប្តូរប្រាក់ដុល្លារ-រៀល ស្ថិតនៅក្នុងកម្រិតដែលជាទីចង់បាន។

សិទ្ធិសមធម៌នៃការទទួលផលពីកំណើនកម្មវិធីចំណាយសាធារណៈ មានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិនេះ។ ក្រុមដែលងាយរងគ្រោះ ដែលរួមទាំង ក្រុមជនរងគ្រោះនៅលំដាប់ទីមួយ និងទីពីរ ដែលបានធ្វើអត្តសញ្ញាណនៅក្នុងផ្នែកទី ៤ អាចទទួលផលដោយយុត្តិធម៌ និងប្រកបដោយតម្លាភាពពីរាល់កម្មវិធីបង្កើនការចំណាយ ឬកម្មវិធីចំណាយថ្មីៗបន្ថែមទៀត។ សិទ្ធិសមធម៌ មានន័យថា បុគ្គលនានាមានឱកាសស្មើគ្នា ដើម្បីប្រើប្រាស់សេវានានា ដូចជា សេវាខាងសុខភាព ការអប់រំ និងការបណ្តុះបណ្តាល និងអាចចូលរួមនៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធផងដែរ។ សមធម៌ ក៏មានន័យផងដែរថា លទ្ធភាពទទួលបានព័ត៌មានអំពីថាតើមានសេវាកម្មបន្ថែមអ្វីខ្លះ ឬគម្រោងថ្មីៗអ្វីខ្លះ។ ការចំណាយសាធារណៈប្រកបដោយប្រសិទ្ធភាព គួរតែធានាឱ្យមានការដោះស្រាយបានសមស្របនូវសិទ្ធិសមធម៌។ គេត្រូវចងចាំផងដែរ អំពីឧបសគ្គដែលមានស្រាប់ ដូចជា របាំងខាងភូមិសាស្ត្រ របាំងខាងយេនឌ័រ និងរបាំងខាងការប្រាស្រ័យទាក់ទង។ កម្មវិធីនានាដែលខកខានមិនបានដោះស្រាយ ឧបសគ្គនានាទាំងនេះ អាចមិនផ្តល់ផល និងផ្តល់ផលមិនគ្រប់គ្រាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការបន្ធូរបន្ថយផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច។

អាស្រ័យហេតុនេះ អ.ស.ប នៅកម្ពុជា គាំទ្រដល់ :

- **សិទ្ធិសមធម៌ក្នុងការទទួលផលពីកម្មវិធីចំណាយសាធារណៈ** ដែលផ្តោតយ៉ាងមានប្រសិទ្ធភាពមកលើក្រុមដែលងាយរងគ្រោះបំផុត និងត្រូវបានបង្កើតឡើង តាមទម្រង់ដែលមានគណនេយ្យភាព និងតម្លាភាព ដោយបង្កើនការយល់ដឹង ការផ្សព្វផ្សាយ និងការទទួលបានព័ត៌មានឱ្យបានគ្រប់គ្រាន់។ ការចូលរួមក្នុងអត្រាទាបនៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំពុងអនុវត្តដោយ MoLVT បង្ហាញអំពីការចាំបាច់ឱ្យមានកិច្ចប្រឹងប្រែងផ្សព្វផ្សាយ ជាពិសេស ដើម្បីធានាថា កម្មវិធីចំណាយនានាអាចផ្តល់ទៅដល់ក្រុមអ្នកទទួលផលដែលជាគោលដៅ។
- អ្នកកសាងគោលនយោបាយ ត្រូវតែចងចាំយកចិត្តទុកដាក់លើ **ការកសាងសមត្ថភាពស្ថាប័ន** ដើម្បីធានាថា កំណើនការចំណាយមានឥទ្ធិពលវិជ្ជមាន ដោយពុំបង្កឱ្យមានសម្ពាធជាបន្ថែមទៀតមកលើរចនាសម្ព័ន្ធ ដែលមានស្រាប់នោះឡើយ។ ឧទាហរណ៍ ការចំណាយបន្ថែម អាចទាមទារឱ្យមាននីតិវិធីបន្ថែមសម្រាប់ការជួលបុគ្គលិក និងការធ្វើលទ្ធកម្ម។ គេក៏ត្រូវតែបង្កើតសមត្ថភាព ដើម្បីអនុវត្តកម្មវិធីថ្មីៗ ដែលជាលទ្ធផលពីកំណើនការចំណាយសាធារណៈផងដែរ។

## ៥.៣ កំណែទម្រង់រចនាសម្ព័ន្ធ

ការធ្លាក់ចុះនៃសេដ្ឋកិច្ច បានគូសបញ្ជាក់អំពីកង្វល់ដែលមានស្រាប់ខាងរចនាសម្ព័ន្ធនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ បញ្ហាទាំងនេះ ត្រូវបានចងក្រងជាឯកសារបានយ៉ាងល្អរួចមកហើយ ជាពិសេស អំពីតម្រូវការឱ្យធ្វើពិពិធកម្មខាងសេដ្ឋកិច្ច និងបង្កើនសមត្ថភាពប្រកួតប្រជែង។ កត្តាដែលជម្រុញឱ្យមានកំណើននៅក្នុងទសវត្សរ៍កន្លងទៅ បានទទួលរងឥទ្ធិពលធ្ងន់ធ្ងរ ដូចមានចែងនៅក្នុងផ្នែកទី ២ និង ៣ នៃរបាយការណ៍នេះ ស្តីពីម៉ាក្រូសេដ្ឋកិច្ច និងវិស័យនានារបស់ខ្លួន និងបានបញ្ជាក់ថាមានភាពងាយរងគ្រោះខ្លាំងក្លាបំផុត ចំពោះការប៉ះទង្គិចមកពីខាងក្រៅ។ វិស័យកសិកម្មដែលមិនសូវរងគ្រោះខ្លាំងក្លា ក៏ត្រូវការឱ្យមានកំណែទម្រង់រចនាសម្ព័ន្ធផងដែរ ដោយសារតែចំនួនសាច់ប្រាក់ដែលផ្ញើមកផ្ទះបានថយចុះ ហើយកម្មករដែលបានបាត់បង់ការងារជាច្រើននាក់ បានវិលត្រឡប់មកផ្ទះវិញ។ គេក៏ត្រូវការជាចាំបាច់ឱ្យមានវិធាន ដែលមានការគិតទុកជាមុនផងដែរសម្រាប់កំណែទម្រង់ទាំងនេះ ប្រសិនបើកម្ពុជាត្រូវពង្រឹងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីការស្តារឡើងវិញនូវសេដ្ឋកិច្ច និងកំណើន ប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលវែង។

នៅពេលពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចរបស់កម្ពុជា ប្រការសំខាន់ គឺត្រូវចងចាំថា សេដ្ឋកិច្ចកម្ពុជាកំពុងរងគ្រោះដោយសារទាំងកត្តាពីខាងក្រៅ និងខាងក្នុងផងដែរ។ ការស្រាវជ្រាវពីមុនមក បង្ហាញពីការជាប់ទាក់ទងយ៉ាងច្រើននៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងពេលថ្មីៗនេះ ទៅនឹងមូលដ្ឋានដំបូងរបស់ខ្លួនដែលមានកម្រិតទាប ហើយអ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺកំណើននៅក្នុងវិស័យជាក់លាក់មួយចំនួន ទំនងជាកំពុងតែឈានទៅមុខយឺតៗ តាំងពីមុនមានវិបត្តិនេះមកម្ល៉េះ ដែលរួមទាំង ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ផងដែរ។ នៅពេលដែលឧស្សាហកម្មបានឈានចូលដល់ភាពចាស់ទុំ ការរក្សាអត្រាកំណើនប្រចាំឆ្នាំឱ្យនៅខ្ពស់ គឺជាការប្រឈមសម្រាប់គ្រប់សេដ្ឋកិច្ចទាំងអស់។ ដូច្នេះ ការកែលម្អសមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច គឺជាការប្រឈមដែលមានស្រាប់ និងដែលកាន់តែមានភាពស្មុគស្មាញ ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។

ដោយសារតែ ៩០% នៃជនក្រីក្ររស់នៅជនបទ និងដោយសារតែផលិតភាពទាបនៃដីកសិកម្ម វិស័យកសិកម្មនឹងអាចទទួលផលយ៉ាងច្រើនពីកំណែទម្រង់រចនាសម្ព័ន្ធបែបនេះ។ កសិដ្ឋានរបស់គ្រួសារនានា ត្រូវបានចាត់ទុកថាជាបណ្តាញសុវត្ថិភាពនៅក្នុងពេលមានវិបត្តិ ដូច្នេះប្រការចាំបាច់ ដែលរឹតតែបន្ទាន់ជាងមុនផងនោះ គឺត្រូវធ្វើកំណែទម្រង់លើវិស័យកសិកម្ម។ ដោយសារកម្រិតទាបនៃទិន្នផលដំណាំលើផ្ទៃដីក្នុងមួយហិកតា ដូចជា ស្រូវ ប្រទេសកម្ពុជាមានសក្តានុពលយ៉ាងច្រើន ដើម្បីបង្កើនប្រាក់ចំណូល និងការងារធ្វើនៅក្នុងវិស័យកសិកម្ម តាមរយៈកំណែលម្អកសិ-ពាណិជ្ជកម្ម។ លើសពីនេះ មនុស្សជាច្រើន ដែលរួមទាំងប្រធានធនាគារពាណិជ្ជកម្មផងដែរ លើកស្នើឡើងឱ្យមានការឱ្យពង្រីកនូវការផ្តល់ប័ណ្ណកម្មសិទ្ធិដីដល់កសិករដែលមានដីតិចតួច។ កង្វះប័ណ្ណកម្មសិទ្ធិសម្រាប់ជាវត្ថុបញ្ចាំ គឺជាឧបសគ្គចំបងមួយក្នុងការផ្តល់ហិរញ្ញប្បទាននៅជនបទ។ វិបត្តិសេដ្ឋកិច្ច អាចក្លាយជាការជម្រុញឱ្យមានការផ្លាស់ប្តូរ និងជាឱកាស ដើម្បីឱ្យមានកំណើននៃកំណែទម្រង់រចនាសម្ព័ន្ធ ដែលនឹងផ្តល់ផលដល់ប្រទេសកម្ពុជា និងប្រជាពលរដ្ឋកម្ពុជា និងក្នុងការកាត់បន្ថយភាពងាយរងគ្រោះផងដែរ។

បើគិតអំពីកំណែទម្រង់រចនាសម្ព័ន្ធ អ.ស.ប នៅកម្ពុជា គាំទ្រឱ្យមានកំណើនសមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច ការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច និងវិធានការនានា ដើម្បីកែទម្រង់វិស័យកសិកម្ម សំដៅកែលម្អផលិតភាពកសិកម្ម :

- **កំណើនសមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច :** ការសិក្សាថ្មីៗមួយដែលធ្វើឡើងដោយ UNDP បានគូសបញ្ជាក់ថា កម្ពុជាស្ថិតក្នុងចំណោមប្រទេស ដែលមានសមត្ថភាពប្រកួតប្រជែងទាបជាងគេនៅក្នុងអាស៊ាន អាស្រ័យហេតុនេះ កម្ពុជាមានឱកាសជាច្រើនដើម្បីធ្វើការកែលម្អ។ នៅថ្នាក់ជាតិ ប្រការនេះអាចសម្រេចទៅបាន តាមរយៈគោលនយោបាយធនធានមនុស្សដែលបានគិតទុកជាមុន គោលនយោបាយហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តោតចំគោលដៅបានល្អជាងមុន ការកែលម្អ SEZs និងការអនុវត្តឱ្យកាន់តែមានសង្គតិភាពនូវក្របខ័ណ្ឌច្បាប់។ ការកែលម្អសមត្ថភាពប្រកួតប្រជែង មានសារៈសំខាន់ណាស់ នៅតាមវិស័យនីមួយៗ ដែលរួមទាំង វិស័យកាត់ដេរ ទេសចរណ៍ កសិកម្ម សំណង់ និង ICT ផងដែរ។ កំណែលម្អបែបនេះ នឹងទាមទារឱ្យមានកិច្ចសហការជាប់ជាប្រចាំក្នុងចំណោមរដ្ឋាភិបាល ដៃគូ អភិវឌ្ឍន៍ និងវិស័យឯកជន។
- **ការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច :** កិច្ចផ្តួចផ្តើមនានា ដូចជា អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម គួរតែអាចពង្រីកជាបន្ថែមទៀត ដើម្បីគាំទ្រឱ្យមានការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច តាមរយៈយុទ្ធសាស្ត្រវិភាគសមាហរណកម្ម ពាណិជ្ជកម្មដែលផ្តោតលើទំនិញ និងសេវាកម្មចំនួន ១៩ មុខ ដែលមានសក្តានុពលខ្ពស់បំផុតសម្រាប់ការនាំចេញ និងការ អភិវឌ្ឍមនុស្ស។
- **កំណែទម្រង់រចនាសម្ព័ន្ធនៃវិស័យកសិកម្ម ដែលរួមទាំង សម្បទានដី ការផ្តល់ប័ណ្ណកម្មសិទ្ធិដី និងការបង្កើនផលិតភាព :** ការផ្តល់ដីទៅឱ្យគ្រួសារនានានៅជនបទ ដែលត្រូវការដីធ្លីជាចាំបាច់បំផុត អាចជួយកែលម្អសេដ្ឋកិច្ចនៅជនបទ ជាពិសេស នៅពេលដែលកម្មករជាច្រើនម៉ឺននាក់ត្រូវគេរំពឹងថា នឹងវិលត្រឡប់មកជនបទវិញ។ គេត្រូវតែធ្វើការពិចារណាដោយប្រុងប្រយ័ត្ន អំពីការផ្តល់សម្បទានដីសេដ្ឋកិច្ច ដើម្បីធានាឱ្យមានការប្រើប្រាស់ដី ដែលផ្តល់ជាប្រយោជន៍គាំទ្រដល់ជនក្រីក្រ និងដែលមាននិរន្តរភាព។ កសិករដែលមានចំណែកដីតូចៗ អាចទទួលផលពីកម្មសិទ្ធិដីដែល មានសុវត្ថិភាព។ ប្រការនេះ នឹងកែលម្អសមត្ថភាពសម្រាប់ធ្វើការសម្រេចលើការវិនិយោគរយៈពេលវែង និងជម្រុញឱ្យមានកំណើនសកម្មភាពសេដ្ឋកិច្ចផងដែរ។ ដោយសារសមត្ថភាព និងធនធាន ស្ថិតក្នុងកម្រិតកំណត់ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាដំបូង គួរតែផ្តោតលើតំបន់នានា ដែលអាចផ្តល់ផលប្រយោជន៍ច្រើនបំផុត ដូចជា អតីតដីព្រៃ ដែលមានសក្តានុពលខ្ពស់ខាងផលិត ទន្ទឹមនឹងគោរពតាមច្បាប់ភូមិបាលដែលមានស្រាប់ផងដែរ។

# VI សេចក្តីសន្និដ្ឋាន



វិបត្តិសេដ្ឋកិច្ចពិភពលោកពិតជាមានផលប៉ះពាល់ជាចំបងមកលើកម្ពុជា និងមកលើប្រជាពលរដ្ឋកម្ពុជា ។ សញ្ញាដំបូងនៃផលប៉ះពាល់បានបង្ហាញច្បាស់ហើយ តាមរយៈការថយចុះនៃការនាំចេញនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០០៨ និងអត្រាកំណើនសេដ្ឋកិច្ចទាបជាងមុនដែលមានត្រឹម ៦,៥% បន្ទាប់ពីធ្លាប់មានកំណើនជាតួលេខពីរខ្ទង់ពីឆ្នាំ២០០៤ ដល់ ២០០៧ ។ ស្ថាប័ន ពហុភាគី បានធ្វើការព្យាករណ៍អំពីអត្រាកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០០៩ ថា នឹងធ្លាក់ចុះរហូតដល់ ២,៧៥% ។ ឥឡូវនេះ សំណួរដែលត្រូវដោះស្រាយគឺថា តើធ្វើបែបណា ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចនេះ មកលើក្រុមជនងាយរងគ្រោះ តើធ្វើការបែបណា ដើម្បីឈានទៅស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់រយៈពេលវែង និងតើធ្វើយ៉ាងណា ដើម្បីទាញយកផលពីឱកាស ដែលកើតចេញពីវិបត្តិសេដ្ឋកិច្ច ដើម្បីអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ដែលបានរង់ចាំជាយូរមកហើយនោះ ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏សមស្រប ជាការឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ច ប៉ុន្តែកម្ពុជានៅពុំទាន់បានគេចចេញផុតពីឥទ្ធិពលនៃវិបត្តិនេះនៅឡើយទេ ។ ប្រការនេះភាគច្រើន គឺដោយសារកម្រិតទាបនៃភាពចម្រុះខាងសេដ្ឋកិច្ច និងការពឹងផ្អែកខ្លាំងពេកលើតម្រូវការទីផ្សារ និងមូលធនមកពីក្រៅប្រទេស ។ ឧស្សាហកម្មនាំមុខ ដូចជា វិស័យកាត់ដេរបាននាំចេញ ២២% តិចជាងមុន នៅរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០០៩ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំទៅ ។ FDI និងគម្រោងសាងសង់ជាច្រើន ត្រូវបានព្យួរទុក ហើយកំណើនចំនួនអ្នកទេសចរដែលធ្វើដំណើរមកកម្ពុជាបានធ្លាក់ចុះ ។ មានតែកសិកម្មទេ ដែលត្រូវបានរំពឹងថានឹងបន្តកើនឡើង ។ ការថយចុះនេះ ទំនងជាកាន់តែធ្ងន់ធ្ងរ លើកលែងតែតម្រូវការសម្លៀកបំពាក់ពីកម្ពុជា និងទេសចរណ៍ មានស្ថានភាពល្អប្រសើរឡើងច្រើននៅក្នុងត្រីមាសចុងក្រោយក្នុងឆ្នាំ២០០៩ ដែលគិតពីចុងខែកញ្ញា ហើយរឿងនេះមិនទំនងជាកើតមានឡើយ ។ បញ្ហានេះមានឥទ្ធិពលអវិជ្ជមានមកលើមិនត្រឹមតែកម្មករជាច្រើនម៉ឺននាក់ ដែលបានបាត់បង់ការងាររួចមកហើយប៉ុណ្ណោះទេ ប៉ុន្តែក៏មានផលប៉ះពាល់មកលើស្ត្រីជាពិសេស និងយុវជនច្រើនជាង ២៥០.០០០ នាក់ ផងដែរ ដែលចូលមកក្នុងទីផ្សារពលកម្មជារៀងរាល់ឆ្នាំ ។

ជាលទ្ធផលនៃឥទ្ធិពលបណ្តាលមកពីការចំណាយទាប កំណើនភាពគ្មានការងារធ្វើ ការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ និងការធ្លាក់ចុះនៃថ្លៃទំនិញ សេដ្ឋកិច្ចជាតិកំពុងតែប្រឈមនឹងតម្រូវការ និងការប្រើប្រាស់តិចតួច ។ គ្រួសារនានានៅជនបទ ដែលពឹងផ្អែកលើប្រាក់ចំណូលពីកសិកម្ម និងប្រាក់ផ្ញើមកផ្ទះ កំពុងតែរងគ្រោះដោយសារតែប្រាក់ ដែលបញ្ជូនមកនោះបានបាត់បង់ទៅហើយ ។ កំណើនការជាប់បំណុល និងការលំបាកនៅក្នុងសងបំណុល គឺជាបន្ទុកបន្ថែម ។ គ្រួសារជាច្រើនអាចនឹងសម្រេចចិត្តលក់ទ្រព្យសកម្ម ដើម្បីសងបំណុល ។ ភាគច្រើននៃបំណុលទាំងនេះ បានកើតឡើងដោយសារកំណើនថ្លៃដាំដំណាំនៅក្នុងឆ្នាំ២០០៨ នៅពេលដែលកសិកររំពឹងចង់បានប្រាក់ចំណូលខ្ពស់មកពីថ្លៃខ្ពស់នៃផលដំណាំ ។ ជាលទ្ធផល សុខុមាលភាពរបស់កុមារ ជនក្រីក្រ និងជនជិតក្រីក្រ ទំនងជាកាន់តែអាក្រក់ឡើង ស្របជាមួយកំណើនភាពងាយរងគ្រោះ នៅក្នុងរយៈពេលលំបាកប្រចាំឆ្នាំ គិតចាប់ពីខែកក្កដា ដល់ខែតុលា ។

ដូចដែលចំណងជើងនៃរបាយការណ៍នេះបញ្ជាក់ស្រាប់ ការធ្លាក់ចុះនៃសេដ្ឋកិច្ចអាចចាត់ទុកថាជា វិបត្តិផង និងឱកាសផង ។ វាជាវិបត្តិធ្ងន់ធ្ងរ ដោយសារចំនួនប្រជាជនដែលស្ថិតនៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ ដែលរងគ្រោះពីអសន្តិសុខនៃប្រាក់ចំណូល និងអសន្តិសុខស្បៀង ទំនងជានឹងកើនឡើង ។ វាជាឱកាសមួយ ដោយសារវាផ្តល់ជាចលករមួយ ដើម្បីដោះស្រាយភាពទន់ខ្សោយនៃរចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាដើម្បីជម្រុញដល់កំណែទម្រង់ស្ថាប័ន និងការចំណាយសាធារណៈប្រកបដោយសមធម៌ ដើម្បីកែលម្អសេដ្ឋកិច្ច និងកាត់បន្ថយភាពងាយរងគ្រោះនៅក្នុងរយៈពេលវែងផងដែរ ។

កម្ពុជាមានគម្រោងការពារសង្គមមួយចំនួន ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។ គម្រោងទាំងនេះ កំពុងជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃវិបត្តិសេដ្ឋកិច្ច ។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីដែលមានស្រាប់មិនមានភាពផ្សារភ្ជាប់គ្នា និងនៅដាច់ដោយដុំ និងមិនគ្របដណ្តប់បានគ្រប់គ្រាន់សម្រាប់កំណើនចំនួននៃគ្រួសារ និងបុគ្គលនានា ដែលសព្វថ្ងៃនេះកំពុងត្រូវការរបបចិញ្ចឹមជីវិតបន្ថែមសម្រាប់ជាជំនួយនោះឡើយ ។ ការអភិវឌ្ឍយុទ្ធសាស្ត្រចម្រុះរបស់ជាតិសម្រាប់ការពារសង្គម គឺជាការអភិវឌ្ឍមួយ ដែលគួរឱ្យស្វាគមន៍នៅក្នុងការដោះស្រាយការប្រឈមនេះ ។ ប្រាក់ដែលរដ្ឋាភិបាលសន្សំបាន អាចយកទៅប្រើប្រាស់ជាកត្តាជម្រុញសម្រាប់ការចំណាយលើគម្រោងការពារសង្គម ។ ការធ្វើបែបនេះអាច រួមចំណែកកាត់បន្ថយភាពក្រីក្រ និងកែលម្អផលិតភាព និងសមត្ថភាពប្រកួតប្រជែង ។ កំណើនការចំណាយក្នុងវិស័យសាធារណៈ ក៏នឹងផ្តល់ប្រសិទ្ធភាពផងដែរ ប្រសិនបើវាផ្តោតលើសិទ្ធិសមធម៌ក្នុងការទទួលបានសេវា និងគម្រោងដែលបានផ្តល់ឱ្យ ។

វិបត្តិសេដ្ឋកិច្ចសព្វថ្ងៃនេះ គឺជាការកម្លាំងជម្រុញមួយសម្រាប់បង្កើនល្បឿននៃកំណែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ។ ចំណាត់ការពីដើមដំបូង ស្របជាមួយការប្រមូលផ្តុំកិច្ចប្រឹងប្រែងពីដៃគូអភិវឌ្ឍន៍លើបញ្ហាដែលមានឥទ្ធិពលរយៈពេលវែង មានសារៈសំខាន់ណាស់ប្រសិនបើមិនចង់ឱ្យឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃវិបត្តិនេះកើតឡើងវិញនោះទេ ។ កំណែទម្រង់នានា ដែលផ្តោតលើកំណែលម្អសមត្ថភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច ការធ្វើចម្រុះកម្មមូលដ្ឋានសេដ្ឋកិច្ច និងផលិតភាពកសិកម្ម អាចសម្រួលឱ្យមានការស្តារសេដ្ឋកិច្ចឡើងវិញសម្រាប់រយៈពេលវែង ការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ និងការសម្រេចបាន CMDGs រហូតដល់ឆ្នាំ២០១៥ ។

# ឧបសម្ព័ន្ធ



## ១. វិធីសាស្ត្រ

ការសិក្សានេះបានធ្វើឡើង ក្រោមរូបភាពជាការវាយតម្លៃរហ័សមួយនៅក្នុងរយៈពេលពីរខែ។ ការចុះទៅមូលដ្ឋានបានចំណាយពេលមួយសប្តាហ៍នៅក្នុងខេត្ត និងមួយសប្តាហ៍លើការសម្ភាសនៅក្នុងក្រុងភ្នំពេញ។ ធនធានដែលមានកម្រិតកំណត់មិនអនុញ្ញាតឱ្យមានការប្រមូលទិន្នន័យថ្មី ដែលអាចតំណាងឱ្យទូទាំងប្រទេសបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានេះបានប្រើប្រាស់លទ្ធផលពីការសិក្សានានាដែលមានពីមុនមក និងទិន្នន័យដែលមានស្រាប់ និងដាក់បញ្ចូលជាមួយគ្នានូវទិន្នន័យបន្ថែមថ្មីៗពីមូលដ្ឋាន ក៏ដូចជាទស្សនៈរបស់អ្នកជំនាញការ និងអ្នកទាំងឡាយ ដែលពាក់ព័ន្ធនៅក្នុងការសម្រេចកម្មវត្ថុនៃការសិក្សា។ វិធីសាស្ត្រនេះ រួមមាន :

### ការវិភាគអំពីទិន្នន័យមានស្រាប់ ដែលបានពីការអង្កេតសេដ្ឋកិច្ចសង្គម និងភាពមានការងារធ្វើ/ការចិញ្ចឹមជីវិត

ការអង្កេតសេដ្ឋកិច្ចសង្គមរបស់កម្ពុជា នៅក្នុងឆ្នាំ២០០៤ និង ២០០៧ រួមផ្សំជាមួយការអង្កេតផ្សេងៗទៀត (ដូចជាការអង្កេតដោយ CDRI នៅថ្នាក់ជាតិ អំពីគ្រួសារនានា ដើម្បីប៉ាន់ប្រមាណ អំពីផលប៉ះពាល់នៃកំណើនថ្លៃខ្ពស់នៅឆ្នាំ២០០៨) ត្រូវបានប្រើប្រាស់ទៅតាមកម្រិតអតិបរមាដែលអាចធ្វើបាន ដើម្បីធ្វើអត្តសញ្ញាណក្រុមដែលងាយរងគ្រោះបំផុត និងទម្រង់នៃការចិញ្ចឹមជីវិតរបស់ពួកគេ ក៏ដូចជាភាពងាយរងគ្រោះដែលអាចកើតមាន។

### ពិនិត្យមើលលទ្ធផល និងអនុសាសន៍ដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍សេដ្ឋកិច្ច និងរបាយការណ៍សេដ្ឋកិច្ច-សង្គម ដែលរៀបចំដោយរដ្ឋាភិបាល ទីភ្នាក់ងារ អ.ស.ប និងដៃគូអភិវឌ្ឍន៍ដទៃទៀត

របាយការណ៍ជាច្រើនត្រូវបានរៀបចំនៅពេលថ្មីៗនេះ ដើម្បីធ្វើអត្តសញ្ញាណបញ្ហារចនាសម្ព័ន្ធដែលមានស្រាប់ ក៏ដូចជាផលប៉ះពាល់ដែលកើតមាន និងផលប៉ះពាល់ ដែលអាចនឹងកើតចេញពីវិបត្តិសេដ្ឋកិច្ចមកលើសេដ្ឋកិច្ចកម្ពុជា។ របាយការណ៍ទាំងនេះបង្កើតជាមូលដ្ឋានសម្រាប់បង្កើនការយល់ដឹងទូលាយមួយ អំពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។ ក្រោមកិច្ចសហការជាមួយក្រុមការងាររបស់ UNDP ការពិនិត្យគ្រប់ជ្រុងជ្រោយមួយនូវឯកសារដែលពាក់ព័ន្ធ ត្រូវបានធ្វើឡើងមុននឹងមានចុះទៅការសិក្សានៅមូលដ្ឋាន និងចាប់ផ្តើមសម្ភាស។

### ការសម្ភាសដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងសហគមន៍

ដោយសារការសិក្សានេះផ្តោតលើផលប៉ះពាល់មកលើមនុស្ស ប្រការចាំបាច់ គឺត្រូវប្រមូលព័ត៌មានថ្មីៗពី បុគ្គល គ្រួសារ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលត្រូវបានធ្វើអត្តសញ្ញាណថា ជាគោលដៅបឋមសម្រាប់ការសិក្សានេះ។ ក្រុមស្រាវជ្រាវនេះបានធ្វើការសម្ភាសជាមួយក្រុមប្រជាពលរដ្ឋ ដែលងាយរងគ្រោះទាំងនៅភ្នំពេញ និងនៅជនបទ និងជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលជាមេដឹកនាំក្នុងភូមិ អង្គការសង្គមស៊ីវិល និងគ្រួសាររបស់កម្មករដែលបាត់បង់ការងារ ក៏ដូចជាកម្មករដែលបាត់បង់ការងារផ្ទាល់ និងគ្រួសារនានា ដែលរងការប៉ះពាល់ធ្ងន់ធ្ងរពីការធ្លាក់ចុះនៃសេដ្ឋកិច្ច។ ទីប្រឹក្សាមួយរូប ជំនួយការស្រាវជ្រាវចំនួនបីរូប និងក្រុម

ការងាររបស់ UNDP បានចំណាយរយៈពេលប្រាំមួយថ្ងៃនៅក្នុងខេត្ត និងសហគមន៍នានា ដែលជាគោលដៅ ដូចជា សហគមន៍អ្នកដាំដំឡូងមី ពោត សណ្តែកដី និងកៅស៊ូ ដែលបានលើកស្នើនៅក្នុងការសិក្សាមុនៗថា បានរងឥទ្ធិពលអវិជ្ជមានពីវិបត្តិហិរញ្ញវត្ថុពិភពលោក និងសហគមន៍នានា ដែលត្រូវបានរាយការណ៍ថា បានទទួលកម្មករដែលវិលត្រឡប់មកពីក្រៅប្រទេស ឬពីកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ។ មានការខិតខំប្រឹងប្រែងនៅក្នុងការសម្ភាសកម្មករកាត់ដេរ និងកម្មករសំណង់ ដែលបានបាត់បង់ការងារ និងដែលបានវិលត្រឡប់មកផ្ទះរបស់ខ្លួនវិញ និងអ្នកដែលបានបន្តស្នាក់នៅក្នុងទីក្រុង ។

## សម្ភាសជាមួយមន្ត្រីសំខាន់ៗក្នុងរដ្ឋាភិបាល / អ្នកកសាងគោលនយោបាយ ដៃគូអភិវឌ្ឍន៍ពីខាងក្រៅ និងវិស័យឯកជន

ក្រុមសិក្សានេះបានសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗប្រមាណ ២០ នាក់ មកពីក្រុមខាងលើ ដើម្បីស្នើសុំទស្សនៈ និងយោបល់របស់ពួកគេ ។ មានការយកចិត្តទុកដាក់ជាពិសេសនៅក្នុងការសម្ភាសស្ថាប័ននានា (ទាំងជាមួយរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល) ដែលធ្វើការពាក់ព័ន្ធជាមួយក្រុមជនងាយរងគ្រោះ ។ ជាក់ស្តែង ក្រសួងការងារមានគម្រោងមួយ ដើម្បីបណ្តុះ-បណ្តាលកម្មករបាត់បង់ការងារ ដែលជាវិធីមួយជួយកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចមកលើពួកគេ ។ អង្គការ NGOs មួយចំនួន កំពុងធ្វើការជាមួយកម្មករចំណាកស្រុក និងមានព័ត៌មានចុងក្រោយបំផុត អំពីផលប៉ះពាល់មកលើកម្មករទាំងនោះ ។

## លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសអ្នកផ្តល់ការសម្ភាស និងការជ្រើសរើសទីតាំង

ការជជែកជាមួយមនុស្សម្នា គឺជាផ្នែកសំខាន់បំផុតមួយនៃការសិក្សានេះ ដោយសារវាពាក់ព័ន្ធជាសំខាន់អំពីការប៉ាន់ប្រមាណផលប៉ះពាល់មកលើមនុស្សបណ្តាលពីវិបត្តិពិភពលោក ។ យើងត្រូវការសម្ភាស មិនត្រឹមតែជាមួយអ្នកដែលរងឥទ្ធិពល ដោយផ្ទាល់ពីវិបត្តិនេះប៉ុណ្ណោះទេ ប៉ុន្តែជាមួយអ្នកដែលមានចំណេះដឹងអំពីអ្នកដទៃ និងជាមួយអ្នកដែលមានគំនិតអំពីថា តើត្រូវកាត់បន្ថយផលប៉ះពាល់ដោយរបៀបណាផងដែរ ។ ដូច្នេះមានមនុស្សបួនក្រុម ដែលយើងបានសម្ភាសនៅមូលដ្ឋាន ។

- **កម្មករដែលបាត់បង់ការងារ :** បុគ្គលនានា ដែលត្រូវបានបញ្ឈប់ពីរោងចក្រកាត់ដេរ និងពីគម្រោងសាងសង់ ។ ជាសរុប យើងបានសម្ភាសកម្មករដែលបាត់បង់ការងារចំនួន ៤៣ នាក់ ។
- **គ្រួសារដែលរងឥទ្ធិពលអវិជ្ជមាន :** គ្រួសារសរុបចំនួន ៤៥ ដែលបានរងគ្រោះពីការបាត់បង់ប្រាក់ចំណូល ដែលត្រូវបានធ្វើអត្តសញ្ញាណ និងសម្ភាស ។
- **អ្នកផ្តល់ព័ត៌មានសំខាន់ៗ :** មនុស្សសរុបចំនួន ២០ នាក់ ដែលរួមមាន មេភូមិ មន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ នាយកគ្រប់គ្រងអាជីវកម្ម នាយក/បុគ្គលិក NGO និងអ្នកលក់ដុំ ត្រូវបានសម្ភាស ។
- **អ្នកកសាងគោលនយោបាយ ដៃគូអភិវឌ្ឍន៍ និងតំណាងពីសង្គមស៊ីវិល ត្រូវបានសម្ភាស** ។ ជាសរុប មានការសម្ភាសមនុស្សចំនួន ២៧ នាក់ នៅក្នុងក្រុមនេះ ។

ធនធាន និងពេលវេលាដែលមាន មិនអនុញ្ញាតឱ្យធ្វើការអង្កេតលើសំណាកដែលមានលក្ខណៈជាតំណាងនោះទេ ។ បើគិតពីវិធីសាស្ត្រស្រាវជ្រាវ គោលគំនិតចំបង គឺចង់បង្កើតករណីសិក្សានានា ដើម្បីបំពេញបន្ថែមលើទិន្នភាពរួមដែលបានបង្កើតឡើង នៅក្នុងការសិក្សាដទៃទៀត ឬទិន្នន័យ/សូចនាករនៅកម្រិតជាតិ ។ ជាមួយនឹងធនធាន និងពេលវេលាតិចតួច ក្រុមអ្នកសិក្សាបានប្រមូលភស្តុតាងមកពីកន្លែងនានា ដែលបានទទួលឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ចពិភពលោក ។ អាស្រ័យហេតុនេះ ក្រុមអ្នកសិក្សាបានធ្វើការសម្ភាស និងសង្កេតនៅ (i) ទីក្រុងភ្នំពេញ សៀមរាប និងកណ្តាល ដើម្បីពិនិត្យមើលឥទ្ធិពល នៅក្នុងទីក្រុងធំៗ (ii) ខេត្តកំពង់ចាម និងមណ្ឌលគិរី ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីតំបន់ធ្វើកសិកម្ម ដែលដំណាំនៅក្នុងតំបន់ទាំងនោះបានរងគ្រោះធ្ងន់ធ្ងរ ដោយសារវិបត្តិពិភពលោក (iii) ខេត្តកំពង់ធំ បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីពិនិត្យមើលផលប៉ះពាល់លើការធ្វើចំណាកស្រុករបស់ពលករទៅប្រទេសថៃ និងម៉ាឡេស៊ី និង (iv) ខេត្តកំពង់ស្ពឺ កំពង់ធំ និងភ្នំពេញ ដើម្បីពិនិត្យមើលកម្មករកាត់ដេរ និងកម្មករសំណង់ ដែលត្រូវបានបញ្ឈប់ ដោយសារតែវិបត្តិសេដ្ឋកិច្ច ។

# ២. តារាងឈ្មោះអ្នកផ្តល់ការសម្ភាស និងស្ថាប័នដែលបានពិគ្រោះយោបល់នៅក្នុងការសិក្សានេះ

| | ឈ្មោះ | តំណែង និងស្ថាប័ន | វិស័យចំបងនៃការសម្ភាស |
|---|---|---|---|
| **រដ្ឋាភិបាល** | | | |
| ១. | ឯកឧត្តម<br>បណ្ឌិត ហង់ ជួន ណារ៉ុន | អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>អនុប្រធានអចិន្ត្រៃយ៍នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | គោលនយោបាយម៉ាក្រូ និងយោបល់ទូទៅ |
| ២. | ឯកឧត្តម<br>បណ្ឌិត វង់ សណ្តាប់ | នាយកគម្រោងជាតិ គម្រោងជំនួយស្បៀងបន្ទាន់<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ធនាគារអភិវឌ្ឍន៍អាស៊ី-គម្រោងរបស់រដ្ឋាភិបាល<br>ដើម្បីជួយអ្នកក្រ និងផ្តល់បណ្តាញសុវត្ថិភាពសង្គម |
| ៣. | ឯកឧត្តម សុខ សុភ័ក្ត្រ | អគ្គនាយកក្រសួងពាណិជ្ជកម្ម | បញ្ហាទាក់ទងនឹងពាណិជ្ជកម្ម |
| ៤. | ឯកឧត្តម មាន សុភា | ប្រធាននាយកដ្ឋានពាណិជ្ជកម្មពហុភាគី ក្រសួងពាណិជ្ជកម្ម | បញ្ហាទាក់ទងនឹងពាណិជ្ជកម្ម |
| ៥. | លោក សាន ភិរុណ្ណា | ប្រធាននាយកដ្ឋានពាណិជ្ជកម្មពហុភាគី | បញ្ហាទាក់ទងនឹងពាណិជ្ជកម្ម |
| ៦. | ឯកឧត្តម សេង សក្ដា | អគ្គនាយក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ផលប៉ះពាល់មកលើពលករចំណាកស្រុក |
| ៧. | ឯកឧត្តម<br>បណ្ឌិត ហេង សួរ | អគ្គនាយក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្មករកាត់ដេរ<br>ដែលបានបញ្ឈប់ពីការងារ |
| ៨. | លោក ម៉ក់ សឿន | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សេវាកសិកម្មសម្រាប់កសិករខ្នាតតូច |
| ៩. | លោក ហ៊ត វណ្ណី | មន្ត្រីផ្នែកស្ថិតិ ក្រសួងទេសចរណ៍ | ផលប៉ះពាល់មកលើទេសចរណ៍ |
| **ដៃគូអភិវឌ្ឍន៍ពីខាងក្រៅ** | | | |
| ១០. | លោក នាក់ សមសែន | អ្នកឯកទេសខាងផ្នែកភាពក្រីក្រ ធនាគារពិភពលោក | អន្តរាគមន៍លើប្រជាជនក្រីក្រ |
| ១១. | លោក Stephane Guimbert | អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំប្រទេស ធនាគារពិភពលោក | ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច |
| ១២. | លោក Eric Sidgwick | អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំប្រទេស ធនាគារអភិវឌ្ឍន៍អាស៊ី | ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច |
| ១៣. | លោក Tuomo Poutiainen | ប្រធានទីប្រឹក្សាបច្ចេកទេស, កម្មវិធីរោងចក្រល្អនៅកម្ពុជា<br>នៃអង្គការពលកម្មអន្តរជាតិ | ផលប៉ះពាល់មកលើពលករ |
| ១៤. | លោកស្រី Liu Xuerong | មន្ត្រីកម្មវិធី, កម្មវិធីស្បៀងអាហារពិភពលោក | ការអនុវត្តបណ្តាញសុវត្ថិភាពសង្គម |
| ១៥. | លោក ឃឹម រដ្ឋា | មន្ត្រីកម្មវិធី, កម្មវិធីស្បៀងអាហារពិភពលោក | ការអនុវត្តបណ្តាញសុវត្ថិភាពសង្គម |
| ១៦. | លោក Peter Leth | អ្នកឯកទេសខាងការតាមដាន និងវាយតម្លៃ,<br>មូលនិធិសហប្រជាជាតិដើម្បីកុមារ | ផលប៉ះពាល់មកលើកុមារ |
| ១៧. | លោក ឃួន ប៊ុន្នី | មន្ត្រីជាតិសម្របសម្រួល, មូលនិធិសហប្រជាជាតិដើម្បីស្ត្រី | ពលកម្មចំណាកស្រុក |
| ១៨. | លោក កុកស៊ី ថានិត | មន្ត្រីកម្មវិធី, UNIFEM | ពលកម្មចំណាកស្រុក |
| ១៩. | លោក កាំង ម៉ូនីកា | ប្រធានអភិវឌ្ឍន៍ធុរៈកិច្ច ប្រចាំសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ផលប៉ះពាល់មកលើរោងចក្រកាត់ដេរ |
| ២០. | លោក លូ ម៉េង | សមាគមសណ្ឋាគារកម្ពុជា | ផលប៉ះពាល់លើសណ្ឋាគារ |
| ២១. | លោកស្រី សូ ផុនណារី | នាយករងប្រតិបត្តិ និងប្រធានផ្នែកប្រតិបត្តិការ ប្រចាំធនាគារអេស៊ីលីដា | ផលប៉ះពាល់លើឥណទាន |
| ២២. | លោក វ៉ាន់ ថូ | នាយករង និងអនុប្រធានផ្នែកឥណទាន, ធនាគារអេស៊ីលីដា | ផលប៉ះពាល់លើឥណទាន |
| ២៣. | លោក ម៉ម ជឿន | តំណាងនៃមីក្រូឥណទានអង្គរ កម្ពុជា | ផលប៉ះពាល់លើឥណទាន |
| ២៤. | លោកស្រី Haidy Ear Dupuy | នាយកផ្នែកតស៊ូមតិ និងទំនាក់ទំនង, អង្គការទស្សនៈពិភពលោកកម្ពុជា | ផលប៉ះពាល់លើជនក្រីក្រ |
| ២៥. | បណ្ឌិត យ៉ង សាំងកុមារ | ប្រធានអង្គការមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ផលប៉ះពាល់ និងអន្តរាគមន៍លើកសិករ |
| ២៦. | លោក សូ សុវណ្ណារិទ្ធ | អ្នកស្រាវជ្រាវ, វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | ការសិក្សាអំពីអ្នកក្រ និងផលប៉ះពាល់នៃ GFC |

## ៣. វិធានការការពារខាងសង្គម

### ការអប់រំ

រដ្ឋាភិបាលមានផែនការពង្រីកកម្មវិធីគាំទ្រដល់វិស័យអប់រំឆ្នាំ២០០៦-២០១០ តាមរយៈមូលនិធិកាតាលីករ FTI (កិច្ចផ្តួចផ្តើមផ្តល់របស់) ។ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ បានផ្តល់អាហារូបករណ៍ក្នុងរង្វង់ ២០-៦០ ដុល្លារ ដល់សិស្សចំនួន ៩៥.០០០ នាក់ ចាប់តាំងពីឆ្នាំ២០០៦ មក ។ ក្រសួងអប់រំ កំពុងធ្វើការជាមួយ UNICEF ដើម្បីកែលម្អគុណភាពនៃការអប់រំ តាមរយៈកម្មវិធីសាលាកុមារមេត្រី ។

### មូលនិធិសមធម៌សម្រាប់ការថែទាំសុខភាព (HEFs)

HEFs កំពុងត្រូវបានអនុវត្តនៅក្នុងស្រុកប្រតិបត្តិចំនួន ៥០ និងជាទូទៅ ត្រូវបានចាត់ទុកថាផ្តល់ភាពពេញចិត្តកម្រិតខ្ពស់ដោយបានបង្ហាញច្បាស់តាមរយៈការរីកចម្រើនយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ២០០០ មក ។ HEFs ដំណើរការតាមរយៈភាគីទីបី ដែលផ្តល់ប្រាក់ទៅឱ្យអ្នកផ្តល់សេវា ជាការទូទាត់ទៅនឹងផលចំណូលដែលមិនបានទទួល ដោយសារតែការឱ្យអ្នកជម្ងឺរួចពីការបង់ថ្លៃសេវា ។ មានអ្នកចាំបង់ថ្លៃលើវិក័យប័ត្ររបស់អ្នកជម្ងឺ ដែលភាគច្រើនគឺម្ចាស់ជំនួយដែលជាអ្នកចេញជំនួស ប៉ុន្តែរដ្ឋាភិបាលក៏បានចូលរួមនៅក្នុងការចេញថ្លៃជួសនេះផងដែរ ។ អ្នកប្រើប្រាស់សេវាបានទទួលប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងសម្រាប់ទិញចំណីអាហារ ។ HEFs បានជួបនឹងការប្រឈមនានា ដូចជា គុណភាពនៃសេវា និងលទ្ធភាពទទួលបានសេវា ប៉ុន្តែជារួមត្រូវបានចាត់ទុកថា បានទទួលជោគជ័យ ។

### កិច្ចផ្តួចផ្តើមធានារ៉ាប់រងសុខភាពរបស់សហគមន៍ (CBHI)

មានប្រព័ន្ធស្ម័គ្រចិត្ត ដែលបានផ្តោតលើក្រុមមនុស្សដែលរស់នៅខ្ពស់ជាងខ្សែបន្ទាត់នៃភាពក្រីក្រ ដែលមានលទ្ធភាពក្នុងការរួមចំណែកបង់ថ្លៃក្នុងបរិមាណតិចតួចទៅក្នុងមូលនិធិធានារ៉ាប់រង ។ អ្នកប្រើប្រាស់បង់ថ្លៃក្នុងបរិមាណតិចតួច ដែលមានក្នុងរវាង ១-៣ ដុល្លារក្នុងមួយខែ ។ កម្មវិធីនេះអនុវត្តដោយ NGOs ចំនួនប្រាំ និងបានកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ។ កម្មវិធី HEF និង CBHI រួមគ្នាបង្កើតជាផ្នែករួមមួយនៃការអភិវឌ្ឍផែនការមេ ស្តីពីកិច្ចការពារសុខភាពសង្គម នៅក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រសុខភាពសង្គម ។

### ការបង្កើតការងារធ្វើតាមរយៈកិច្ចការក្នុងវិស័យសាធារណៈ

រដ្ឋាភិបាលបានគាំទ្រឱ្យមានបច្ចេកវិទ្យាសមស្របដែលផ្អែកលើកំលាំងពលកម្ម ដើម្បីបង្កើតការងារតាមរយៈកំណែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅជនបទ ។ ILO និង ADB បានផ្តល់ជំនួយដល់រដ្ឋាភិបាល ក្នុងការអនុវត្តការបញ្ជ្រាបកិច្ចការ ថែទាំផ្លូវថ្នល់ដែលផ្អែកលើពលកម្មទៅក្នុងកម្មវិធីបណ្តាញផ្លូវថ្នល់របស់ជាតិ ។ រវាងឆ្នាំ២០០៦ និង ២០០៨ អង្គការ ILO បានផ្តល់សាច់ប្រាក់ជិត ៤,៨ លានដុល្លារ ដល់គម្រោងនេះ ។ រវាងឆ្នាំ២០០៧ និង ២០០៨ ADB ក៏បានផ្តល់ ៦៩០.៣៩៨ ដុល្លារ ដល់កម្មវិធីនេះផងដែរ ។ គេមានទស្សនៈថា អ្នកទទួលផលមកពីកម្មវិធីនេះ គឺជាបុរស ទោះជាយ៉ាងណាក៏ដោយ ស្ត្រីត្រូវបានបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលដែលកំពុងអនុវត្តដោយក្រសួងការងារផងដែរ ។

### វិធានការនានានៅក្នុងវិស័យផ្លូវការ

ប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីស៊ីវិល និងប្រាក់បំណាច់សម្រាប់អតីតយុទ្ធជន គឺជាកម្មវិធីធំជាងគេចំនួនពីរ នៅក្នុងវិស័យផ្លូវការរបស់រដ្ឋាភិបាលផងដែរ ។ កម្មវិធីទាំងនេះ គ្របដណ្តប់ក្នុងទំហំតូច និងបរិមាណតិច ។ NSSF ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ ដែលមានគោលដៅពង្រីកវិធានការសម្រាប់ការពារសង្គម ដោយគ្របដណ្តប់លើការរងរបួសនៅក្នុងពេលបំពេញការងារ ការធានារ៉ាប់រងសុខភាព និងប្រាក់សោធននិវត្តន៍ ។ នៅក្រោមយុទ្ធសាស្ត្រការពារសុខភាពសង្គម ការធានារ៉ាប់រងសុខភាព នឹងក្លាយជាអាណត្តិសម្រាប់និយោជិតនៅក្នុងវិស័យផ្លូវការ ។ នៅមានទិដ្ឋភាពជាច្រើនដែលអាចពង្រីកវិធានការផ្លូវការ ដើម្បីការពារសង្គម ។

# ឯកសារយោង




"2009 Budget Law Should Favour Farmers" (Budget Brief). Phnom Penh: NGO Forum on Cambodia, 2008.

"80 new flu cases raise total to 1,289". *Bangkok Post,* 28 June 2009. http://www.bangkokpost.com/breakingnews/147331/pm-extends-condolence-to-flu-victims, accessed 10 August 2009.

*Annual Development Review 2006-07.* Phnom Penh: CDRI, 2007.

*Annual Development Review 2008-09.* Phnom Penh: CDRI, 2009.

*The Asia Development Outlook 2009.* Manila: Asian Development Bank, 2009.

"Cambodia: 2008 Article IV Consultation-Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion" (Country Report No. 09/47). Washington, DC: International Monetary Fund, 2009.

*The Cambodia Aid Effectiveness Report 2008.* Phnom Penh: Council for the Development of Cambodia-Cambodian Rehabilitation and Development Board, 2008.

*Cambodia Anthropometrics Survey 2008.* Phnom Penh: National Institute of Statistics/Ministry of Planning, 2009.

*Cambodia Anthropometrics Survey 2008:* English Supplement. Phnom Penh: UNICEF, 2009.

*Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction* (Discussion Paper No. 7). Phnom Penh: UNDP, 2009.

*Cambodia: Exodus to the Sex Trade? Effects of the Global Financial Crisis on Women's Working Conditions and Opportunities.* Phnom Penh: UNIAP, 2009.

*Cambodia: Halving Poverty by 2015?* (Cambodia Poverty Assessment 2006). Phnom Penh: World Bank, 2006.

*Cambodia Human Development Report 2007: Expanding Choices for Rural People. Phnom Penh:* UNDP, 2007.

"Cambodia Statistical Appendix" (IMF Country Report 09/48). Washington, DC: International Monetary Fund, 2009.

"Cambodian Garment Industry: Challenges and Opportunities" (Fact Sheet). Phnom Penh: ILO-Better Factories Cambodia, 2008.

Chan, Sophal. "The Impact of High Food Prices". *Annual Development Review 2008-09.* Phnom Penh: CDRI, 2009.

Chan, Sophal. "The Political Economy of Managing Labour Migration". *Annual Development Review 2007-08.* Phnom Penh: CDRI, 2008.

Chandararot, Kang, Sok Sina, and Liv Dannet. *Rapid Assessment of the Impact of the Financial Crisis in Cambodia.* Bangkok: ILO Subregional Office for East Asia, 2009.

Cheang, S. "Border Resolution Near". *Phnom Penh Post,* 2 March 2009: 3.

Chhun, K. "Real Estate, Real Trust?" *Economics Today,* 16 Dec. 2008: 14.

Chun Sophal. "Garment exports plummet 18pc over first half of year". *Phnom Penh Post,* 17 Aug. 2009: 13.

"Consumer Price Index". Phnom Penh: National Institute of Statistics/Ministry of Planning, 2008. http://www.nis.gov.kh/index.php/statistics/cpi-cost-price-index, accessed 29 July 2009.

Grosh, Margaret, Carlo del Ninno, Emil Tesliuc, and Azedine Ouerghi. *For Protection and Promotion: The Design and Implementation of Effective Safety Nets.* Washington, DC: World Bank, 2008.

Hor, H. and Chun, S. "Inflation Falls for December". *Phnom Penh Post,* 14 Jan. 2009: 13.

"Human Development Reports -Statistical Update (Cambodia)." UNDP, 2008. http://hdrstats.undp.org/2008/countries/country_fact_sheets/cty_fs_KHM.html, accessed 8 Aug. 2009.

*The Impact of the Global Economic Downturn on Communities in Cambodia: Special Study Report of the Cambodian Economic Association.* Phnom Penh: Cambodian Economic Association, 2009 (forthcoming).

*Impact of High Food Prices in Cambodia: Survey Report.* Phnom Penh: CDRI, 2008.

*The Implications of the Global Financial Crisis for Low-Income Countries.* Washington, DC: International Monetary Fund, 2009.

"International Trade Agreements and Cambodia's Garment Industry" (Fact Sheet). Phnom Penh: ILO-Better Factories Cambodia, 2005.

Kurczy, S. "Government Suspends 1% Tax on Garment Factory Expenditures". *Cambodia Daily,* 27 Jan. 2009: 28.

*Land and Human Development in Cambodia* (Discussion Paper No. 5). Phnom Penh: UNDP, 2007.

Lim, Sovannara. "Youth Migration and Urbanization in Cambodia" (Working Paper 36). Phnom Penh: CDRI, 2007.

Maltoni, B. *Review of Labor Migration Dynamics in Cambodia.* Phnom Penh: International Organisation for Migration, 2006.

McLeod, G. "Cambodian Stock Exchange Deal Signed". *Phnom Penh Post,* 24 March 2009: 13.

*National Bank of Cambodia Annual Report 2008.* Phnom Penh: National Bank of Cambodia, 2009.

Nelmes, John. "Global Crisis: Impact, Outlook and Policy Options for Cambodia." Cambodia Outlook Conference. Phnom Penh Hotel. 12 March 2009. Presentation.

Ngy, Chanphal. "Developing Effective and Affordable Social Safety Nets for Cambodia" (Discussion Paper). Phnom Penh: Council for Agriculture and Rural Development, 2009.

"The Preliminary Results of Nation-wide Establishment Listing of Cambodia 2009". National Institute of Statistics/Ministry of Planning, 2009. http://www.nis.gov.kh/index.php/statistics/surveys/el2009, accessed 7 June 2009.

*Raising Rural Incomes in Cambodia: Beyond Sectoral Policy, Towards a Framework for Growth* (Discussion Paper No. 4). Phnom Penh: UNDP, 2007.

"Rapid assessment of the impacts of the economic crisis on Cambodian households: component 2-informal risk management and safety net practices" (working title). Phnom Penh: CDRI, 2009 (forthcoming).

Ravallion, Martin. "Bailing out the world's poorest" (Policy Research Working Paper No. 4763). Washington, DC: World Bank, 2008.

*Second Investment Climate Assessment: A Better Investment Climate to Sustain Growth in Cambodia.* Phnom Penh: World Bank and International Finance Corporation, 2009.

*Sharing growth: equity and development in Cambodia* (Equity Report 2007). Phnom Penh: World Bank, 2007.

"Social protection: the role of cash transfers". *UNDP International Poverty Centre, Poverty in Focus* June 2006.

Sovann, Nguon. "Bank deposits and loans drop". *Phnom Penh Post,* 27 April 2009: 15.

Sovann, Nguon. "Sacombank launches with eye on VN trade". *Phnom Penh Post,* 24 June 2009: 13.

"Statement of an IMF Mission at the Conclusion of the Staff Visit to Cambodia" (Press Release 09/67). IMF: 6 March 2009. http://www.imf.org/external/np/sec/pr/2009/pr0967.htm, accessed 10 August 2009.

*Statistical Yearbook of Cambodia 2008.* Phnom Penh: National Institute of Statistics/Ministry of Planning, 2008.

*Sustaining Rapid Growth in a Challenging Environment* (Cambodia Country Economic Memorandum). Phnom Penh: World Bank, 2009.



# PHOTO CREDITS

| PAGE NUMBER | PHOTO CREDIT |
|---|---|
| Cover | 2008 UNESCAP/Kibae |
| i | 2009 UNDP/Isabelle Lesser |
| ii | 2008 UNDP/Margaret Lamb |
| iii | 2008 UNESCO |
| v | 2008 UNESCAP/Kibae |
| vii | 2008 UNESCAP/Kibae |
| 1 | 2009 UNDP/Isabelle Lesser |
| 4 | 2009 UNDP/Isabelle Lesser |
| 5 | 2008 UNDP/Margaret Lamb |
| 7 | 2009 UNDP/Isabelle Lesser |
| 22 | 2009 UNDP/Isabelle Lesser |
| 23 | 2008 UNESCAP/Kibae |
| 32 | 2008 UNESCAP/Kibae |
| 33 | 2008 UNESCO/Chanthul |
| 46 | 2009 UNDP/Isabelle Lesser |
| 47 | 2007 UNDP |
| 51 | 2009 UNDP |
| 53 | 2009 UNDP |
| 56 | 2008 UNESCO/Chanthul |
| 60 | 2009 UNDP/Isabelle Lesser |

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**
ការិយាល័យសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

ផ្ទះលេខ ៥៣, ផ្លូវប៉ាស្ទ័រ, សង្កាត់បឹងកេងកង, ប្រអប់សំបុត្រលេខ ៨៧៧, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ២៣ ២១៦ ១៦៧ ឬ ២១៧ ១៩៣ / ទូរសារ : (៨៥៥) ២៣ ២១៦ ២៥៧ ឬ ៧២១ ០៤២
អ៊ីម៉ែល : registry.kh@undp.org
គេហទំព័រ : //www.un.org.kh

*Designed by Graphic Roots: www.graphicroots.com.kh*